ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកិច្ចការនារី
MINISTRY OF WOMEN'S AFFAIRS

# គោលការណ៍ណែនាំ
## ស្តីពី
# ដំណើរការទារកដ្ឋាន
# របស់ក្រសួងកិច្ចការនារី









ឆ្នាំ២០២១

# អារម្ភកថា

រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវ**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤** ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាព ក្នុងការកសាងមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។ ស្របនឹងគោលដៅនេះ រាជរដ្ឋាភិបាលបានបញ្ជាក់ពីការយកចិត្តទុកដាក់ខ្ពស់ក្នុងការពង្រឹងសមភាពយេនឌ័រ និងភាពអង់អាចដល់ស្ត្រីនៅគ្រប់វិស័យ និងគ្រប់កម្រិត។

ផ្អែកលើមូលដ្ឋានខាងលើ ក្រសួងកិច្ចការនារី ដែលជាយន្តការថ្នាក់ជាតិ ដឹកនាំ សម្របសម្រួល ជំរុញ និងតាមដាន ការអនុវត្តការបញ្ជ្រាបយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី បានរៀបចំ**ផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ ២០១៩-២០២៣** ដែលក្នុងនោះផ្នែកមួយនៃការបង្កើតបរិយាកាសអំណោយផលដល់មន្ត្រីរាជការ និងបង្ហាញនូវឆន្ទៈពិតប្រាកដសម្រាប់សម្រេចបាននូវសមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី គឺការបង្កើតឱ្យមានទារកដ្ឋាននៅក្នុងស្ថាប័ន។

ក្នុងនាមខ្ញុំផ្ទាល់ដែលជាថ្នាក់ដឹកនាំរបស់ក្រសួងកិច្ចការនារី បានផ្តួចផ្តើមបង្កើតទារកដ្ឋាននៅក្នុងក្រសួងកិច្ចការនារីនេះឡើងនៅឆ្នាំ២០១៨ ដើម្បីជួយសម្រួលដល់មន្ត្រីរាជការរបស់ក្រសួង ក៏ដូចជាដើម្បីឈានទៅរួមចំណែកនូវការសម្រេចបានជោគជ័យក្នុងការអនុវត្ត**ផែនការយុទ្ធសាស្ត្រនារីរតនៈទី៥** ផងដែរ។

ដើម្បីឆ្លើយតបតាមតម្រូវការជាក់ស្តែងរបស់មន្ត្រីរាជការ ព្រមទាំងជំរុញការបង្កើនគុណភាព និងប្រសិទ្ធភាពនៃសេវាទារកដ្ឋានឱ្យកាន់តែល្អប្រសើរបន្ថែមទៀត ក្រសួងកិច្ចការនារី បានផ្តួចផ្តើមរៀបចំគោលការណ៍ណែនាំស្តីពី **"ដំណើរការទារកដ្ឋាន"** ក្នុងគោលបំណងណែនាំអំពីវិធីសាស្ត្រក្នុងការផ្តល់សេវារបស់ទារកដ្ឋានដោយផ្តោតលើគោលការណ៍គន្លឹះមួយចំនួនដូចជា៖ ការថែទាំ និងការអភិវឌ្ឍកុមារតូច សុខភាព និងអនាម័យ អាហារូបត្ថម្ភ និងការអប់រំផ្អែកតាមអាយុរបស់កុមារ។ គោលការណ៍ណែនាំក៏បានផ្តល់នូវគោលការណ៍សំខាន់ៗពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធ ដែលឆ្លើយតបនឹងតម្រូវការរបស់កុមារតូច និងម្តាយផងដែរ ព្រមទាំងបានផ្តល់នូវមគ្គុទេសក៍អប្បបរមា ប្រកបដោយភាពជាក់លាក់ សមស្រប និងបង្កលក្ខណៈងាយស្រួលដល់ក្រសួង ស្ថាប័នដទៃទៀត យកទៅប្រើប្រាស់ផ្អែកតាមលទ្ធភាព និងស្ថានភាពជាក់ស្តែងរបស់ខ្លួន។

ខ្ញុំមានសង្ឃឹមយ៉ាងមុតមាំថា ក្រសួង-ស្ថាប័ន និងដៃគូពាក់ព័ន្ធ រួមទាំងវិស័យឯកជននឹងចូលរួមកិច្ចសហប្រតិបត្តិការទាំងអស់គ្នា ដើម្បីសម្រេចសមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី ប្រកបដោយជោគជ័យ និងប្រសិទ្ធភាពសម្រាប់ជាឧត្តមប្រយោជន៍ដល់សង្គមជាតិទាំងមូល។

ថ្ងៃពុធ ២កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងកិច្ចការនារី**

**អ៊ឹង កន្ថាផាវី**

# សេចក្តីថ្លែងអំណរគុណ

ក្រោមការណែនាំជារួមពី **លោកជំទាវកិត្តិបណ្ឌិតរដ្ឋមន្ត្រី** ក្រសួងកិច្ចការនារី ដែលបានផ្តួចផ្តើមគំនិតបង្កើតទារកដ្ឋានសម្រាប់កុមារកាលពីឆ្នាំ២០១៨ ដើម្បីឱ្យឪពុកម្តាយជាមន្ត្រីរាជការ មានលទ្ធភាពធ្វើការងារប្រកបដោយប្រសិទ្ធភាព ព្រមទាំងកាត់បន្ថយអវត្តមាន និងលើកកម្ពស់តុល្យភាពរវាងជីវិតការងារ និងជីវិតគ្រួសារ ដូចនេះគោលការណ៍ណែនាំស្តីពី "កិច្ចដំណើរការទារកដ្ឋាន" ត្រូវបានរៀបចំឡើង ក្នុងគោលបំណងផ្តល់ការណែនាំអំពីដំណើរការប្រចាំថ្ងៃនៃទារកដ្ឋានរបស់ក្រសួងកិច្ចការនារី។ គោលការណ៍ណែនាំនេះ រៀបចំដោយការិយាល័យអប់រំកុមារតូចនៃនាយកដ្ឋានស្ត្រី និងការអប់រំ ដែលមានការគាំទ្រពីធនាគារពិភពលោក។

យើងខ្ញុំសូមថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំ និងមន្ត្រីក្រសួងកិច្ចការនារី ដែលជួយរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយនឹងថ្នាក់ដឹកនាំ មន្ត្រីនៃនាយកដ្ឋានទទួលបន្ទុក មន្ត្រីនៃនាយកដ្ឋានពាក់ព័ន្ធ ម្តាយ ឪពុក ដែលប្រើប្រាស់ទារកដ្ឋាន ព្រមទាំងអ្នកផ្តល់សេវាថែទាំ ដែលធ្វើការងារនៅក្នុងទារកដ្ឋាននេះ។ ការរៀបចំគោលការណ៍ណែនាំនេះ ត្រូវបានធ្វើឡើង ផ្អែកតាមតម្រូវការរបស់មន្ត្រីក្រសួងកិច្ចការនារី ដំណើរការរបស់ទារកដ្ឋាន និងលក្ខខណ្ឌតម្រូវគុណភាពក្នុងកម្រិតអប្បបរមា និងគោរពទៅតាមក្របខ័ណ្ឌទូទៅថ្នាក់ជាតិស្តីពីការរៀបចំ និងដំណើរការទារកដ្ឋាន នៅតាមសហគ្រាសរបស់កម្ពុជា ដែលរៀបចំឡើងដោយក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសុខាភិបាល ដោយសហការជាមួយនឹងអង្គការ Planète Enfants & Développement *(PE&D)* អង្គការ*គ្រួសារយើង និងទីភ្នាក់ងារអភិវឌ្ឍន៍បារាំង (AFD)*។

អ្នកនិពន្ធឯកសារគោលការណ៍ណែនាំនេះ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ **លោកជំទាវកិត្តិបណ្ឌិតរដ្ឋមន្ត្រី** ថ្នាក់ដឹកនាំ ក្រុមការងារ និងអ្នកផ្តល់សេវាថែទាំរបស់ក្រសួងកិច្ចការនារី ដែលបានផ្តល់អនុសាសន៍ និងចែករំលែកចំណេះដឹង និងបទពិសោធន៍ជាច្រើនក្នុងការរៀបចំឯកសារនេះ។

## មាតិកា


អារម្ភកថា

សេចក្តីថ្លែងអំណរគុណ ........ i

សេចក្តីផ្តើម ........ ១

ផ្នែកទី ១៖ ទិដ្ឋភាពទូទៅ និងវិសាលភាពនៃគោលការណ៍ណែនាំ ........ ៣

១.១. គោលបំណង ........ ៣

១.២. គោលដៅ ........ ៣

១.៣. កុមារដែលមានសិទ្ធិប្រើប្រាស់ទារកដ្ឋាន (**Eligibility**) ........ ៣

១.៤. ការគ្រប់គ្រងទារកដ្ឋាន ........ ៤

១.៥. វិសាលភាពនៃគោលការណ៍ណែនាំ ........ ៤

ផ្នែកទី ២៖ បរិក្ខារនៅក្នុងទារកដ្ឋាន ........ ៥

២.១. អគារ ការរចនាបន្ទប់ បរិក្ខារ និងគ្រឿងសង្ហារិម ........ ៥

២.១.១. ការរចនាបន្ទប់ជាទូទៅ ........ ៥

២.១.២. បរិក្ខារ និងគ្រឿងសង្ហារិមសំខាន់ៗ ........ ៥

២.១.៣. បន្ទប់ ឬបរិវេណបន្ថែមសម្រាប់ពង្រីក ជួសជុលកែលម្អក្នុងទារកដ្ឋាននៃក្រសួងកិច្ចការនារី ........ ៧

២.១.៤. ការរៀបចំ និងគ្រឿងសង្ហារិម ........ ៨

ផ្នែកទី ៣៖ សកម្មភាពដែលអនុវត្តជាប្រចាំនៅក្នុងទារកដ្ឋាន ........ ១១

៣.១. កាលវិភាគប្រចាំថ្ងៃ អំពីសកម្មភាពនៅក្នុងទារកដ្ឋាន ........ ១១

៣.១.១. ការទទួលស្វាគមន៍កុមារ ........ ១១

៣.២. ការថែទាំ និងសកម្មភាពសម្រាប់ទារក និងកុមារតូចៗ ........ ១១

៣.២.១. ការថែទាំ និងសកម្មភាពសម្រាប់ទារក (អាយុ ០-១៨ ខែ) ........ ១១

៣.២.២. ការថែទាំ និងសកម្មភាពសម្រាប់កុមារតូច (អាយុពី ១៨-៣៦ ខែ) ........ ១៣

៣.២.៣. អាហារ និងអាហារសម្រន់ ........ ១៤

៣.២.៤. អាហារសម្រន់ ........ ១៤

៣.២.៥. អាហារថ្ងៃត្រង់ ........ ១៥

៣.២.៦. ការប្តូរខោទឹកនោម ........ ១៦

៣.២.៧. ការលេង ........ ១៦

៣.២.៨ កាលវិភាគគេងទៀងទាត់សម្រាប់ទារក........................................................................................១៧
៣.២.៩. ពេលគេង..........................................................................................................................................១៧
៣.២.១០. ពេលសម្រាប់លេងក្រោយអាហារថ្ងៃត្រង់ ...........................................................................១៨
៣.២.១១. ការមកដល់របស់ម្តាយ ឪពុក ........................................................................................................១៨
ផ្នែកទី ៤៖ សមាសភាគសំខាន់ៗនៃការអភិវឌ្ឍកុមារ ដែលត្រូវអនុវត្តនៅក្នុងទារកដ្ឋាន ...............................២០
៤.១. ការអភិវឌ្ឍកាយសម្បទា ..........................................................................................................................២០
៤.១.១. ការអភិវឌ្ឍបំណិនចលនា ...................................................................................................................២០
៤.១.២. ការអភិវឌ្ឍផ្លូវចិត្ត និងសង្គម ...........................................................................................................២០
៤.១.៣. ការអភិវឌ្ឍបញ្ញាញាណ ភាសា និងបំណិនគិត............................................................................២១
៤.២ អាហារូបត្ថម្ភ និងសុខភាពរបស់កុមារ ......................................................................................................២១
ផ្នែកទី ៥៖ អ្នកគ្រប់គ្រងបុគ្គលិក និងរដ្ឋបាល.................................................................................................២៥
៥.១. អ្នកគ្រប់គ្រងទារកដ្ឋាន ...........................................................................................................................២៥
៥.២. អ្នកថែទាំ ..................................................................................................................................................២៦
៥.២.១. ការជំនួសអ្នកថែទាំ......................................................................................................................... ២៧
៥.២.២. ជំនួយការ ឬអ្នកសម្អាតក្នុងទារកដ្ឋាន.............................................................................................២៨
៥.២.៣. ចំនួនកុមារ/អ្នកថែទាំ និងទំហំក្រុម ....................................................................................................២៨
៥.២.៤. ការដាក់វិន័យ និងការណែនាំ.................................................................................................................២៨
៥.៣. ការទទួលខុសត្រូវរបស់ម្តាយ ឪពុក ........................................................................................................ ៣០
៥.៣.១. សុវត្ថិភាពពេលយកកុមារមកដល់ទារកដ្ឋាន និងពេលមកយកកុមារពីទារកដ្ឋាន.................... ៣០
៥.៤. ឯកសាររបស់កុមារនៅក្នុងទារកដ្ឋាន..................................................................................................... ៣០
៥.៤.១. ប្រភេទឯកសារ................................................................................................................................. ៣០
៥.៥. របាយការណ៍សុខភាពសម្រាប់កុមារនៅក្នុងទារកដ្ឋាន ...........................................................................៣៣
ផ្នែកទី ៦៖ ការរៀបចំរបាយការណ៍ ការតាមដាន និងវាយតម្លៃ.................................................................... ៣៤
ផ្នែកទី ៧៖ ការប្រុងប្រយ័ត្នផ្នែកសន្តិសុខ និងសុវត្ថិភាព .................................................................................. ៣៦
៧.១. ការចូលមកក្នុងទារកដ្ឋាន និងការជួបជាមួយនឹងកុមារ ......................................................................... ៣៦
៧.២. អន្តរាគមន៍ និងការផ្តល់ឱសថ.................................................................................................................... ៣៦
៧.៣. ការប្រុងប្រយ័ត្នផ្នែកសុវត្ថិភាព.................................................................................................................៣៧
៧.៣.១. វត្ថុដែលអាចបង្កគ្រោះថ្នាក់.................................................................................................................៣៧

៧.៣.២. មុខសញ្ញាគ្រោះថ្នាក់ដែលបង្កឡើងដោយមនុស្សផ្សេងទៀត ..... ៣៧
៧.៤. ផែនការត្រៀមឆ្លើយតបស្ថានភាពអាសន្ន ..... ៣៨
៧.៤.១. ផែនការត្រៀមឆ្លើយតប ..... ៣៨
៧.៤.២. ការទទួលខុសត្រូវក្នុងការអនុវត្តផែនការត្រៀមឆ្លើយតបស្ថានភាពអាសន្ន ..... ៣៩
៧.៤.៣ ការអនុវត្តសុវត្ថិភាព និងគ្រាមានអាសន្ន ..... ៣៩
ឧបសម្ព័ន្ធ ..... ៤០

# សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ថា ការលើកកម្ពស់សមភាពយេនឌ័រ និងកិច្ចគាំពារសង្គម មានសារសំខាន់យ៉ាងខ្លាំងចំពោះការពង្រឹងតួនាទីរបស់ស្ត្រីនៅក្នុងសង្គម។[1] ក្រសួងកិច្ចការនារី បាននិងកំពុងសហការយ៉ាងជិតស្និទជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រីនៅតាមវិស័យនានា។

អត្រាស្ត្រីមានការងារធ្វើនៅកម្ពុជាមាន ៧៩,៩% ខណៈពេលដែលអត្រាបុរសមានការងារធ្វើ គឺ៨៨,៧%[2]។ ក្នុងសកលលោកទាំងមូល វិស័យសាធារណៈ គឺជាវិស័យដែលផ្តល់ការងារដ៏ច្រើន ជាពិសេសវិស័យផ្លូវការ និងបុគ្គលិកដែលមានជំនាញ។ វិស័យនេះផ្តល់ការងារសរុប ១៦% ក្នុងនោះការងារដែលមានប្រាក់ឈ្នួល ៣០% និងការងារដែលមានប្រាក់ឈ្នួលសម្រាប់វិស័យផ្លូវការ ៣៨%។ នៅក្នុងវិស័យសាធារណៈ បុគ្គលិកអាចមានកម្រិតវប្បធម៌ខុសៗគ្នាផ្អែកតាមយេនឌ័រ ទោះបីជាស្ត្រីខ្លះមានបទពិសោធន៍ការងារតិចជាងបុរសក៏ដោយ នេះដោយសារតែ អាជីពការងាររបស់ពួកគេទទួលរងការរំខានពីការទទួលខុសត្រូវមើលថែទាំកូនៗ។ យោងតាមការសិក្សាស្រាវជ្រាវមួយចំនួនដែលទាក់ទងនឹងការងាររបស់ស្ត្រី និងបុរសក្នុងវិស័យឯកជននៅកម្ពុជា បង្ហាញថា ការប្រើប្រាស់ពេលវេលាសម្រាប់ការងារ អាចមានភាពខុសគ្នា ជាពិសេសការចំណាយពេលសម្រាប់ការងារផ្ទះ និងការថែទាំកូន ដែលកត្តាទាំងនោះ គឺជាបញ្ហាប្រឈមសម្រាប់ជម្រើសការងារ ឬមុខរបររបស់ស្ត្រី។ ការសិក្សាទាំងនោះក៏បានបញ្ចូលនូវគម្លាតនៃការផ្តល់ព័ត៌មាន ឬការទទួលបានព័ត៌មាន អំពីការងារដែលធ្វើឱ្យស្ត្រីទទួលបានឱកាសការងារ និងការចូលរួមជាមួយបណ្តាញនានាតិចជាងបុរស ។[3]

នៅកម្ពុជា មន្ត្រីរាជការជាស្ត្រីមាន ៤១%។[4] ក្រសួងកិច្ចការនារីមានមន្ត្រីចំនួន ២៤៥ នាក់ ក្នុងនោះស្ត្រី ១៧៩ នាក់ (ស្មើនឹង ៧៣%) និងមន្ត្រីជាប់កិច្ចសន្យា ១២២ នាក់ ស្រី ៦៥ នាក់ (ស្មើនឹង ៥៣,២៧%)។ ក្នុងចំណោមមន្ត្រីទាំងនេះ មន្ត្រីជាស្ត្រី ២៨ នាក់ មានទាំងមន្ត្រីក្របខ័ណ្ឌ និងមន្ត្រីជាក់កិច្ចសន្យា មានកូនអាយុពី ០-៣ឆ្នាំ (បញ្ចូលទាំងមន្ត្រីដែលមានផ្ទៃពោះផងដែរ)។ ក្នុងឆ្នាំ ២០១៨ រដ្ឋមន្ត្រីក្រសួងកិច្ចការនារីបានផ្តួចផ្តើមគំនិតក្នុងការបង្កើតទារកដ្ឋាន ដើម្បីផ្តល់សេវាថែទាំកូនដោយមិនគិតថ្លៃសម្រាប់មន្ត្រីរបស់ក្រសួងកិច្ចការនារីនៅទីស្តីការក្រសួង។ គោលបំណងជារួមរបស់លោកជំទាវរដ្ឋមន្ត្រី គឺដើម្បីផ្តល់ដំណោះស្រាយចំពោះបញ្ហាថែទាំកូនរបស់មន្ត្រីជាបុរស និងជាស្ត្រី និងដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងាររបស់មន្ត្រីទាំងនេះ។ ក្រោយពេលដែលបង្កើតទារកដ្ឋានរួច ក្រសួងកិច្ចការនារីបានចាត់តាំងមន្ត្រីក្នុងការផ្តល់សេវាថែទាំកុមារ និងបានទទួលការឧបត្ថម្ភជាឯកសារអំណានពីអង្គការស៊ីប៉ា (Sipar) ជាអង្គការមិនមែនរដ្ឋាភិបាលមួយដែលធ្វើការងារដើម្បីអភិវឌ្ឍបំណិនអំណាន និងប្រយុទ្ធប្រឆាំងនឹងបញ្ហាអនក្ខរកម្ម។ បច្ចុប្បន្នមានកុមារ ចំនួន ២០ នាក់ ដែលជាកូនរបស់មន្ត្រីជាស្ត្រី និងបុរស បានមកទទួលសេវានៅ

---

[1] យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ដំណាក់កាលទី IV របស់រាជរដ្ឋាភិបាលកម្ពុជា (២០១៨)។

[2] ការអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ដែលរៀបចំឡើងដោយវិទ្យាស្ថានជាតិស្ថិតិរបស់ក្រសួងផែនការ (២០១៧)។

[3] ការស្វែងរកដំណោះស្រាយដែលមានលក្ខណៈនវានុវត្តន៍សម្រាប់ការិយាធិបតេយ្យ ដើម្បីបង្កើនសមត្ថភាពរបស់រដ្ឋាភិបាល (Innovating bureaucracy for a more capable government) នៃធនាគារពិភពលោក (២០១៩)។

[4] ទិន្នន័យមន្ត្រីរាជការបែងចែកតាមភេទរបស់ក្រសួងមុខងារសាធារណៈ (២០១៨)។

ទារកដ្ឋានរបស់ក្រសួងកិច្ចការនារី ប៉ុន្តែមានតែ ១១ នាក់ប៉ុណ្ណោះ ដែលប្រើប្រាស់សេវាថែទាំពេញម៉ោង។

ការសិក្សាមួយកាលពីឆ្នាំ ២០១៥ ដែលធ្វើឡើងដោយវិទ្យាស្ថានម៉ាគឃីនស៊ីសកល (McKinsey Global Institute) បានប៉ាន់ប្រមាណថា ការបិទគម្លាតយេនឌ័រនៅក្នុងការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចឱ្យបានត្រឹមឆ្នាំ ២០២៥ និងបន្ថែមទឹកប្រាក់ ១២ពាន់លានដុល្លារអាមេរិកទៅក្នុងផលិតផលក្នុងស្រុកសរុប (ផសស) របស់សកលលោកទាំងមូល ដែលធ្វើឱ្យ ផសស ជាសកលកើនឡើង ២៦%[5]។ ការខ្វះសេវាថែទាំកុមារ ដែលមានគុណភាពល្អ និងមានតម្លៃសមរម្យ គឺជាឧបសគ្គមួយក្នុងចំណោមឧបសគ្គសំខាន់ៗ ដែលរារាំងមិនឱ្យស្ត្រីទទួលបានការងារដែលមានគុណភាពល្អ។ ដូច្នេះការរៀបចំ ផ្តល់សេវាថែទាំកុមារ ជាមួយនឹងតម្លៃសមរម្យនៅកម្ពុជា មានសក្តានុពលក្នុងការកាត់បន្ថយការចំណាយពេលវេលាលើការងារដែលពុំមានប្រាក់ឈ្នួល និងបិទគម្លាតយេនឌ័រ។ ការធ្វើបែបនេះ នឹងផ្តល់នូវប្រយោជន៍មកវិញជាច្រើន ដូចជា ការបង្កើនភាពម្ចាស់ការផ្នែកហិរញ្ញវត្ថុរបស់ស្ត្រី ធ្វើឱ្យពួកគេអាចចាប់យកឱកាសរកប្រាក់ចំណូល និងចូលរួមនៅក្នុងកម្លាំងពលកម្ម។ លើសពីនេះ កុមារដែលទទួលបានសេវាថែទាំ និងអប់រំកុមារតូច ច្រើនតែធ្វើបានល្អ នៅពេលចូលរៀន និងក្លាយជាមនុស្សពេញវ័យដែលមានសុខភាពមាំមួន និងកាន់តែមានផលិតភាព។ សេវាថែទាំកុមារអាចជាដំណោះស្រាយឈ្នះ-ឈ្នះ សម្រាប់និយោជិត និយោជក ព្រមទាំងកូនៗរបស់ពួកគេ និងសេដ្ឋកិច្ចទាំងមូល។

សេវាទារកដ្ឋានឯកជនកំពុងមានការកើនឡើងនៅតាមតំបន់ប្រជុំជន ប៉ុន្តែថ្លៃសេវាជាមធ្យមសម្រាប់សេវាថែទាំកុមារពេញមួយថ្ងៃនៅតំបន់ប្រជុំជនសម្រាប់កុមារអាយុពី ៣-៥ ឆ្នាំ គឺ ប្រមាណ១០០ ដុល្លារអាមេរិក ក្នុងមួយខែ សម្រាប់កុមារម្នាក់។

ក្រសួងកិច្ចការនារីទទួលស្គាល់ថា ការកែលម្អដំណើរការរៀបចំទារកដ្ឋាន និងបង្កើនគុណភាពនៃសេវាថែទាំកុមារគឺចាំបាច់បំផុត។ ដើម្បីពង្រឹងគុណភាពនៃដំណើរការ និងសេវាថែទាំនៃទារកដ្ឋានរបស់ក្រសួងកិច្ចការនារី ដោយមានការគាំទ្របច្ចេកទេសពីធនាគារពិភពលោក ក្រសួងកិច្ចការនារី បានរៀបចំគោលការណ៍ណែនាំនេះឡើង ដើម្បីផ្តល់ការណែនាំ និងធ្វើឱ្យកាន់តែប្រសើរឡើងនូវដំណើរការប្រចាំថ្ងៃរបស់ទារកដ្ឋាន។ គោលការណ៍ណែនាំនេះ អាចនឹងត្រូវយកទៅកែសម្រួលសម្រាប់ប្រើប្រាស់នៅតាមក្រសួងស្ថាប័ន ដទៃទៀតរបស់រដ្ឋាភិបាល ក៏ដូចជាអាចប្រើប្រាស់ជាឯកសារមគ្គុទេសក៍ពីលក្ខខណ្ឌអប្បបរមាស្តីពីដំណើរការទារកដ្ឋាន។ ក្រៅពីគោលការណ៍ណែនាំនេះ ក្រសួងកិច្ចការនារីបានបន្តផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិកដែលជាអ្នកផ្តល់សេវាថែទាំកុមារ នូវប្រធានបទជាក់លាក់ ដូចជា ការអភិវឌ្ឍកុមារ ការអប់រំ សុវត្ថិភាព និងសន្តិសុខសម្រាប់កុមារជាដើម។

---

[5] អានុភាពនៃយុត្តភាព៖ របៀបដែលការលើកកម្ពស់សមភាពយេនឌ័រ អាចបន្ថែមទឹកប្រាក់ ១២ ទ្រីលានដុល្លារអាមេរិក ទៅក្នុងកំណើនសកល (The power of parity: How advancing women's equality can add US$12 trillion to global growth) ដោយវិទ្យាស្ថានម៉ាឃីនស៊ីសកល (McKinsey Global Institute) (២០១៥)។

# ផ្នែកទី១ ៖ ទិដ្ឋភាពទូទៅ និងវិសាលភាពនៃគោលការណ៍ណែនាំនេះ

ទារកដ្ឋាននៃក្រសួងកិច្ចការនារីបានឆ្លើយតបចំពោះតម្រូវការរបស់បុគ្គលិក កូនៗរបស់ពួកគេ និងថ្នាក់ដឹកនាំរបស់ក្រសួងកិច្ចការនារី ក្នុងការផ្តល់សេវាថែទាំកុមារប្រកបដោយគុណភាពដល់មន្ត្រីទាំងស្ត្រីទាំងបុរស ព្រមទាំងកូនៗរបស់ពួកគេ។ គោលបំណងរួមរបស់ក្រសួងកិច្ចការនារី គឺដើម្បីកាត់បន្ថយបន្ទុកក្នុងការថែទាំកូនរបស់មន្ត្រីរាជការ និងគ្រួសាររបស់ពួកគេ ក៏ដូចជាលើកកម្ពស់តុល្យភាពរវាងជីវិតការងារ និងជីវិតគ្រួសាររបស់មន្ត្រី ជាពិសេសដើម្បីបង្កើនឱកាស និងភាពអង់អាចដល់មន្ត្រីជាស្ត្រី និងបុរស ក្នុងការបំពេញការងាររបស់ខ្លួន ព្រមទាំងរួមចំណែកជួយជំរុញឱ្យកុមារមានការលូតលាស់ និងអភិវឌ្ឍពេញលេញ។ ការផ្តល់សេវាថែទាំកុមារប្រកបដោយគុណភាពដល់មន្ត្រី គឺជាដំណោះស្រាយមួយក្នុងចំណោមដំណោះស្រាយសំខាន់ៗរបស់ក្រសួងកិច្ចការនារី ដើម្បីបង្កើនភាពអង់អាចដល់ស្ត្រី និងបង្កើនការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចរបស់ពួកគេ ដែលនាំឱ្យពួកគេកាន់តែមានការងារល្អប្រសើរជាងមុន។ ការប្តេជ្ញាចិត្ត និងការវិនិយោគរបស់ថ្នាក់ដឹកនាំបែបនេះ គឺស្របគ្នាជាមួយនឹងទិសដៅអភិវឌ្ឍន៍ជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ និងផែនការយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំ នារីរតនៈទី៥ ដើម្បីជំរុញការបញ្ជ្រាបយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី។

## ១.១. គោលបំណង

លើកកម្ពស់ការផ្តល់សេវាថែទាំកុមារតូចប្រកបដោយគុណភាព និងសុវត្ថិភាព ដើម្បីឱ្យឪពុកម្តាយជាមន្ត្រីរាជការ មានលទ្ធភាពធ្វើការងារប្រកបដោយប្រសិទ្ធភាព ព្រមទាំងកាត់បន្ថយអវត្តមាន និងលើកកម្ពស់តុល្យភាពរវាងជីវិតការងារ និងជីវិតគ្រួសារ។

## ១.២. គោលដៅ

- ផ្តល់សេវាអប់រំ និងគាំពារកុមារតូច តាមរយៈការប្រើប្រាស់បច្ចេកទេសគរុកោសល្យ ដោយផ្តោតលើការអភិវឌ្ឍ ដល់កូនៗរបស់មន្ត្រីរាជការជាស្ត្រី និងបុរសដែលបានចុះឈ្មោះទទួលសេវានេះ
- ផ្តល់ជាគំរូដល់ក្រសួងស្ថាប័នដទៃទៀតរបស់រដ្ឋាភិបាល និងស្ថាប័នឯកជននានា អាចយកទៅកែសម្រួល និងអនុវត្តបន្ត

ទារកដ្ឋាន គឺជាកន្លែងដែលមានសុវត្ថិភាព និងផ្តល់នូវបរិយាកាសល្អប្រសើរដល់កុមារ ឱ្យមានអារម្មណ៍ថាបានទទួលភាពកក់ក្តៅ ការការពារ និងការថែទាំយ៉ាងល្អពីអ្នកផ្តល់ការថែទាំរបស់ពួកគេ។ គ្រប់សកម្មភាពនៅទារកដ្ឋាន ដូចជា៖ ការលេង ការញ៉ាំអាហារ ការគេង និងការរៀនសូត្រ ត្រូវតែមានសុវត្ថិភាព សន្តិសុខ និងមានមេត្រីភាពបរិស្ថានសម្រាប់កុមារ (សូមមើលផ្នែកទី ៧៖ ការប្រុងប្រយ័ត្នផ្នែកសន្តិសុខ និងសុវត្ថិភាព)។

## ១.៣. កុមារដែលមានសិទ្ធិប្រើប្រាស់ទារកដ្ឋាននេះ (Eligibility)

កុមារដែលមានអាយុ០ ខែ[6] រហូតដល់៦០ខែ ដែលមានម្តាយឬឪពុកជាមន្ត្រីក្របខ័ណ្ឌ ឬមន្ត្រីជាប់កិច្ចសន្យា

[6] ខណៈពេលដែលការសម្រាកលំហែមាតុភាពមានរយៈពេល ៩០ ថ្ងៃ ជារឿយៗស្ត្រីចាប់ផ្តើមលំហែមាតុភាពមុនពេលសម្រាលកូន។ ដូច្នេះពួកគេអាចនៅ

របស់ក្រសួងកិច្ចការនារី។ ការផ្តល់ជូននឹងធ្វើឡើងទៅតាមគោលការណ៍អ្នកមកមុនទទួលបានមុន ដោយមិនរំពឹងថាតម្រូវការសេវាទារកដ្ឋានមានលើសពីសមត្ថភាពឆ្លើយតបឡើយ។

ការកំណត់សមត្ថភាពឆ្លើយតប ធ្វើឡើងទៅតាមចំនួនកុមារ ដែលមកទទួលសេវាក្នុងមួយថ្ងៃៗ ពោលគឺប្រសិនបើកុមារមួយចំនួនមកតែពេលព្រឹក នោះកុមារផ្សេងទៀតអាចមកពេលរសៀល។ គួរលើកទឹកចិត្តឱ្យមន្ត្រីចុះឈ្មោះកូន ប្រើប្រាស់សេវាទារកដ្ឋានជាប្រចាំ ឬយ៉ាងហោចណាស់ ជូនដំណឹងជាមុន។

## *១.៤. ការគ្រប់គ្រងទារកដ្ឋាន*

ការិយាល័យអប់រំកុមារតូចនៃនាយកដ្ឋានស្ត្រី និងការអប់រំ របស់ក្រសួងកិច្ចការនារី ទទួលខុសត្រូវលើការគ្រប់គ្រង និងដំណើរការទារកដ្ឋាន ព្រមទាំងបុគ្គលិកទារកដ្ឋាន។ អ្នកគ្រប់គ្រងនឹងជំរុញឱ្យមានការសហការពីអ្នកពាក់ព័ន្ធក្នុងជួររាជរដ្ឋាភិបាល និងក្រៅរដ្ឋាភិបាល ដើម្បីផ្តល់ការគាំទ្របច្ចេកទេស និងធនធាន ព្រមទាំងវាយតម្លៃលើគុណភាពសេវា និងទារកដ្ឋានទាំងមូលទៅតាមការចាំបាច់។ ការធ្វើបែបនេះ នឹងផ្តល់លទ្ធភាពឱ្យអ្នកពាក់ព័ន្ធនានាអាចរៀនសូត្រពីដំណើរការនៃទារកដ្ឋានរបស់ក្រសួងកិច្ចការនារី និងកែសម្រួលគោលការណ៍ណែនាំ ព្រមទាំងបទពិសោធន៍នានាឱ្យស្របទៅតាមកន្លែងធ្វើការរៀងៗខ្លួន ប្រសិនបើអាចធ្វើទៅបាន។

## *១.៥. វិសាលភាពនៃគោលការណ៍ណែនាំ*

គោលការណ៍ណែនាំប្រតិបត្តិនេះ បានផ្តល់ការណែនាំអំពីការគ្រប់គ្រង និងដំណើរការប្រចាំថ្ងៃនៃទារកដ្ឋានរបស់ក្រសួងកិច្ចការនារី។ ឯកសារនេះនឹងត្រូវឆ្លុះបញ្ចាំងក្នុងផែនការប្រចាំឆ្នាំ ផែនការថវិកា និងផែនការយុទ្ធសាស្ត្រ គោលនយោបាយ និងគតិយុត្តនានារបស់ក្រសួងកិច្ចការនារី ។ ទារកដ្ឋាននេះនឹងផ្តល់អាទិភាពនៅក្នុងការផ្តល់សេវាដោយផ្តោតលើគុណភាពនៃការថែទាំ អនាម័យ សុខភាព សុវត្ថិភាព និងការអភិវឌ្ឍកុមារតូច។

---

សល់រយៈពេលលំហែមាតុភាពតែ ៣០ ទៅ ៦០ ថ្ងៃប៉ុណ្ណោះ ក្រោយពេលសម្រាលកូនរួច។ ទារកដ្ឋាននេះអនុញ្ញាតឱ្យបុគ្គលិកយកកូនរបស់ពួកគេមកដាក់ នៅពេលណាដែលពួកគេត្រឡប់មកធ្វើការវិញ។ សម្រាប់មន្ត្រីជាបុរស ពួកគេអាចយកកូនមកដាក់តែក្រោយរយៈពេល ៩០ ថ្ងៃប៉ុណ្ណោះ លើកលែងតែមន្ត្រីដែលជាឪពុកបង្ហាញភស្តុតាងបញ្ជាក់ថា ម្តាយកូននេះបានឈប់សម្រាកលំហែមាតុភាពជាផ្លូវការ ហើយបានវិលត្រឡប់ទៅធ្វើការវិញមុនពេលកូនអាយុបាន ៩០ ថ្ងៃ។

# ផ្នែកទី២ ៖ បរិក្ខារនៅក្នុងទារកដ្ឋាន

ទារកដ្ឋានត្រូវរៀបចំស្តង់ដារសុវត្ថិភាព និងអនាម័យ និងបន្តគោរពតាមស្តង់ដារទាំងនេះ ដូចជា ទីតាំង ការរៀបចំប្លង់ទារកដ្ឋាន ការបំពាក់បរិក្ខារ និងសង្ហារិមនានា។ ដោយសារតែក្រសួងកិច្ចការនារីមានទីតាំងដែលកំពុងប្រើប្រាស់ជាទារកដ្ឋានរួចទៅហើយ ផ្នែកខាងក្រោមនេះគឺសំដៅដាក់លាក់លើទីតាំងនោះតែម្តង។ ប្រសិនបើមានការផ្លាស់ប្តូរ ឬកែប្រែទីតាំង ចាំបាច់អនុវត្តវិធានការជាជំហានៗបន្ថែមទៀត ដើម្បីធានាថា ទីតាំងនោះបានបំពេញទៅតាមស្តង់ដារជាមូលដ្ឋាននេះ។

## *២.១. អគារ ការរចនាបន្ទប់ បរិក្ខារ និងគ្រឿងសង្ហារិម មានលក្ខណៈស្តង់ដា*

### *២.១.១. ការរចនាបន្ទប់ជាទូទៅ*

ទារកដ្ឋានគួរកំណត់សមាសភាគជាមូលដ្ឋានសម្រាប់ការរចនា និងការប្រើប្រាស់ផ្ទៃនៅក្នុងទារកដ្ឋាន និងបន្តអនុវត្តតាមស្តង់ដារទាំងនេះ៖

- ក្នុងបន្ទប់ទារកដ្ឋានគួរមាន ក្រឡាផ្ទៃ ២-៣ ម៉ែត្រការ៉េ សម្រាប់កុមារម្នាក់
- ត្រូវធានាឱ្យមានពន្លឺថ្ងៃចេញចូលគ្រប់គ្រាន់ តាមបង្អួចមកក្នុងបន្ទប់
- ត្រូវមានបរិក្ខារអគ្គិសនី និងទឹកស្អាត ដែលអាចប្រើប្រាស់បាន
- មានកង្ហារ និងម៉ាស៊ីនត្រជាក់ ដែលដំណើរការដើម្បីរក្សាសីតុណ្ហភាពនៅក្នុងបន្ទប់
- គ្រប់បន្ទប់ទាំងអស់ត្រូវស្អាត និងមានអនាម័យ
- មានទឹកស្អាត និងសុវត្ថិភាពសម្រាប់កុមារញ៉ាំ ទោះក្នុងករណីដែលឪពុកម្តាយរបស់ពួកគេពុំបានផ្តល់ទឹក ឬយកទឹកមកពីផ្ទះឱ្យបានគ្រប់គ្រាន់ក៏ដោយ
- មានកន្លែងសម្រាប់រក្សាទុករបស់របរផ្ទាល់ខ្លួនរបស់កុមារម្នាក់ៗ (ដូចជា ចំណីអាហារ ទឹកដោះគោ ដបទឹក ខោ ទឹកនោម ។ល។)
- មានកន្លែងសម្រាប់ទុកដាក់សម្ភារលេង និងសម្ភាររៀនសូត្ររបស់កុមារ
- មានកន្លែងសម្រាប់រក្សាទុកប្រអប់សង្គ្រោះបឋម និងសម្ភារអនាម័យនានា ( ទឹកលាងសម្អាតដៃ ម៉ាស អាកុល បង់បិទដំបៅ... ។ល។)

### *២.១.២. បរិក្ខារ និងគ្រឿងសង្ហារិមសំខាន់ៗ*

- **បន្ទប់ធំ**

ទារកដ្ឋានរបស់ក្រសួងកិច្ចការនារីមានបន្ទប់ធំមួយ និងបន្ទប់បំបៅដោះកូនមួយ ដោយពុំមានការបែងចែកជាបន្ទប់តូចៗនោះឡើយ ប៉ុន្តែមានបន្ទប់ទឹកសមស្របទៅតាមអាយុរបស់កុមារ។ បន្ទប់ធំប្រើប្រាស់សម្រាប់ការលេង ការរៀនសូត្រ ការញ៉ាំអាហារថ្ងៃត្រង់ និងអាហារសម្រន់ជាដើម។ ផ្នែកមួយនៃបន្ទប់ធំ ត្រូវបានប្រើសម្រាប់ដាក់ឱ្យកុមារគេង ពេលសម្រាកគេងថ្ងៃ។ បរិវេណនេះ ជានិច្ចជាកាលគួរមានបរិក្ខារ ដូចខាងក្រោម ដែលត្រូវរក្សាថែទាំឱ្យបានសមស្រប៖

- ធ្នើរសម្រាប់ដាក់របស់របរលេង និងរបស់របរផ្ទាល់ខ្លួនរបស់កុមារ (សម្លៀកបំពាក់ វត្ថុបម្រុងផ្សេងៗ)
- តុ និងកៅអីសមស្របតាមអាយុរបស់កុមារ
- របស់លេងសមស្របតាមអាយុ និងសម្ភារគរុកោសល្យ ដើម្បីភ្ញោចការអភិវឌ្ឍរបស់កុមារ (មានរបស់របរបម្រុងទុកមួយចំនួន ក្នុងករណីដែលកុមារលើសពីម្នាក់ ចង់អាន ប្រើប្រាស់របស់លេង ឬលេងអ្វីដូចគ្នា)
- ទូរដាក់ឯកសារសម្រាប់ដាក់ឯកសាររដ្ឋបាល ត្រូវមានថតចាក់សោរយ៉ាងហោចណាស់មួយ សម្រាប់រក្សាទុកវត្ថុមានតម្លៃរបស់អ្នកផ្តល់ការថែទាំ
- តុ និងកៅអី ដើម្បីឱ្យអ្នកផ្តល់ការថែទាំបំពេញកិច្ចការរដ្ឋបាល
- ក្តាខៀនសម្រាប់អ្នកផ្តល់ការថែទាំប្រើប្រាស់សម្រាប់រៀបចំ និងធ្វើផែនការការងាររបស់ពួកគេ ឬផ្តល់ព័ត៌មានដល់ម្តាយ ឪពុក ឬភ្ញៀវ
- កង្ហារ និង/ឬ ម៉ាស៊ីនត្រជាក់
- ប្រអប់សង្គ្រោះបឋម
- ទឹកអនាម័យ ឬទឹកលាងសម្អាតដៃ ពិសេសក្នុងអំឡុងមានពេលជំងឺកូវីដ-១៩ និងជំងឺឆ្លងផ្សេងៗ។

ដើម្បីភ្ញោចកុមារឱ្យមានការអភិវឌ្ឍ ទារកដ្ឋានគួរមានការរចនា និងតុបតែងឱ្យបានសមស្រប។ ពណ៌ និងការតុបតែង អាចប្រើប្រាស់សម្រាប់ផ្នែកដែលបំពេញមុខងារច្រើនយ៉ាង និងដើម្បីបង្កើនបរិយាកាសផ្សេងៗគ្នានៅតាមទីកន្លែងនីមួយៗទាំងនោះ។[7] ថ្នាំដែលប្រើប្រាស់សម្រាប់លាបបន្ទប់ គួរពុំមានជាតិបារត ដើម្បីធានាឱ្យមានខ្យល់បរិសុទ្ធនៅក្នុងបន្ទប់ និងសុខុមាលភាពកុមារ។

- **កន្លែងសម្រាប់កុមារគេង (Nap area)**

កន្លែងសម្រាប់កុមារគេងជួយឱ្យកុមារទទួលបាននូវការគេងប្រកបដោយគុណភាព និងផាសុខភាព ដែលជាធាតុផ្សំមួយដ៏សំខាន់សម្រាប់ការអភិវឌ្ឍដ៏ប្រសើរសម្រាប់កុមារ។ ដោយសារតែមានបន្ទប់ធំតែមួយនៅក្នុងទារកដ្ឋានរបស់ក្រសួងកិច្ចការនារី ផ្នែកមួយនៃបន្ទប់នេះត្រូវបានបែងចែកសម្រាប់ការគេងរបស់កុមារ និងមានការរៀបចំបានយ៉ាងសមស្រប។ កន្លែងគេង គួរមានកម្រាលក្រាលសម្រាប់ឱ្យកុមារគេង ក្នុងទំហំដែលសមស្រប និងខ្នើយទៅតាមអាយុរបស់កុមារ និងត្រូវមានការរៀបចំពិសេសៗសម្រាប់ទារក និងកុមារតូចៗ ។

> អ្នកជំនាញខាងការថែទាំកុមារផ្តល់ជាអនុសាសន៍ឱ្យដាក់សីតុណ្ហភាពក្នុងបន្ទប់ចន្លោះពី ២៣ ទៅ ២៦ អង្សាសេ។ សីតុណ្ហភាពម៉ាស៊ីនត្រជាក់គួរបង្កើន ឬបញ្ចុះទៅតាមសីតុណ្ហភាពខាងក្រៅ។ បុគ្គលិកគួរពិនិត្យមើលសីតុណ្ហភាពដើម្បីកុំឱ្យបន្ទប់នេះត្រជាក់ពេក ឬក្តៅពេកសម្រាប់កុមារ។

**របៀបដាក់ទារកតូចឱ្យគេង និងការយកចិត្តទុកដាក់ចំពោះពួកគេ** – ទារកតូចៗដែលមិនទាន់ចេះក្រឡាប់

[7] ពណ៌ភ្លឺៗ ដូចជា ពណ៌ក្រហម ស្វាយ (magenta) និងលឿង ជួយដល់ការអភិវឌ្ឍផ្នែកចលនាធំ ពណ៌ខៀវ និងពណ៌បៃតងជាពណ៌ស្រទន់ ជាជម្រើសដ៏ល្អសម្រាប់កន្លែងដែលផ្តល់ការរៀនសូត្រ តាមរយៈការអនុវត្តផ្ទាល់ ហើយពណ៌ស និងពណ៌ដែលភ្លឺ គឺជាពណ៌ដែលសមស្របសម្រាប់ការងារដែលត្រូវការផ្ចង់អារម្មណ៍ និងត្រូវការភ្លើងបំភ្លឺ។ ពណ៌ប៉ាស្ទែល (pastels) ស្រទន់ និងពណ៌ស្រទន់ផ្សេងទៀត គឺល្អសម្រាប់អំណាន និងសកម្មភាពដែលធ្វើយឺតៗផ្សេងទៀត។ ការតុបតែងគួរអនុវត្តទៅតាមទម្រង់ដូចៗគ្នា និងត្រូវមានការផ្លាស់ប្តូរឱ្យបានញឹកញាប់ និងរៀបទៅតាមលំដាប់លំដោយប្រធានបទ និងគម្រោង។

ត្រូវដាក់ឱ្យគេងបែមុខមកខាងលើ លើកលែងតែក្នុងករណីដែលម្ដាយ ឪពុករបស់ទារកនេះ មានឯកសារបញ្ជាក់ពីអ្នកជំនាញខាងសុខភាពថាអាចដាក់កុមារឱ្យគេងតាមរបៀបផ្សេង ឬការដាក់ឱ្យគេងរបៀបផ្សេង មិនបង្កគ្រោះថ្នាក់ដល់កុមារនេះ។ ទារកតូចៗមិនត្រូវមានអ្វីមកគ្របលើក្បាល មុខ ឬអង្រឹងរបស់ពួកគេ ដូចជា ភួយ កន្សែង ឬសម្លៀកបំពាក់ ទោះជានៅពេលណាក៏ដោយ។

- **បន្ទប់ទឹក**

ការរក្សាអនាម័យឱ្យបានល្អមានសារសំខាន់យ៉ាងខ្លាំង ព្រោះថាកុមារងាយនឹងឆ្លងជំងឺ។ ទារកដ្ឋាននេះមានបន្ទប់ទឹកដែលមានកន្លែងលាងដៃ និងបង្គន់សម្រាប់កុមារ។ ត្រូវមានការសម្អាតបន្ទប់ទឹកឱ្យបានយ៉ាងហោចណាស់ពីរដងក្នុងមួយថ្ងៃ (ម្ដងនៅថ្ងៃត្រង់ និងម្ដងទៀតក្រោយពេលបិទទារកដ្ឋាន)។ ទារកដ្ឋានត្រូវរៀបចំឱ្យមាន សាប៊ូគ្រប់គ្រាន់សម្រាប់ការលាងសម្អាតដៃ កន្សែងដែលស្អាត ឬកន្សែងដែលប្រើហើយចោល ក្រដាសបង្គន់ ព្រមទាំងសម្ភារសម្អាត ដើម្បីសម្អាតខ្លួនកុមារ និងសម្អាតទារកដ្ឋានទាំងមូល ទៅតាមការចាំបាច់។ លើសពីនេះ គួរមានធុង ឬថង់សម្រាប់យកសំរាមទៅចោល រួមទាំងខោទឹកនោមផង ប្រសិនបើចាំបាច់។ បន្ទប់ទឹកគួរមានតុសម្រាប់ប្ដូរខោទឹកនោមឱ្យទារកតូចៗ ដើម្បីកុំឱ្យគេដូរខោទឹកនោមនេះនៅក្នុងបន្ទប់ធំ។ ឪពុកម្ដាយចាំបាច់ត្រូវផ្ដល់ខោទឹកនោម និងសម្ភារសម្រាប់សម្អាតទាំងអស់សម្រាប់កូនរបស់ពួកគេ។

- **បន្ទប់/ផ្នែកសម្រាប់បំបៅកូន**

ប្រសិនបើទារកដ្ឋានពុំមានក្រឡាផ្ទៃឱ្យធំគ្រប់គ្រាន់នោះទេ គេអាចប្រើប្រាស់បន្ទប់ធំសម្រាប់បំបៅកូន។ ដើម្បីជួយឱ្យមានភាពងាយស្រួលក្នុងការបំបៅកូន នៅក្នុងទារកដ្ឋាននេះត្រូវមានកៅអី ខ្នើយ គ្រែ ពូក និងផ្ទាំងសម្រាប់បាំង។

### *២.១.៣. បន្ទប់ ឬបរិវេណបន្ថែមសម្រាប់ពង្រីក ជួសជុលកែលម្អក្នុងទារកដ្ឋាននៃក្រសួងកិច្ចការនារី*

ប្រសិនបើក្រសួងកិច្ចការនារីមានធនធានសម្រាប់កែប្រែ ឬពង្រីកទំហំអគារនៃទារកដ្ឋាន គួរមានការពិចារណាពីជម្រើសដូចខាងក្រោម៖

- **ផ្ទះបាយ**

ផ្ទះបាយគួរមានក្រឡាផ្ទៃឱ្យធំគ្រប់គ្រាន់ (ប្រមាណ ៥ម$^{២}$) សម្រាប់រៀបចំ/រក្សាទុកអាហារ និងចំណី។ ផ្ទះបាយគួរមានកន្លែងដាច់ដោយឡែកសម្រាប់ញ៉ាំអាហារ និងគួរមាន៖

- ទូរក្លាសេ/ទូរទឹកកក
- កំសៀវដាំទឹកអគ្គិសនី និងធុងចម្រោះទឹក
- សម្ភារផ្ទះបាយ (កែវ សម ស្លាបព្រា)
- សម្ភារផ្ទះបាយ (ខ្ទះ ឆ្នាំង ឆ្នាំងដាំបាយ ចង្ក្រាន កំសៀវអគ្គិសនី ខ្ទះអគ្គិសនី)
- ខ្ទះចម្អិនដោយប្រើអគ្គិសនី
- កន្លែងរក្សាទុកម្ហូប

- ធុងសំរាម

- **កន្លែងប្រជុំ (ជាជម្រើស)**

កន្លែងប្រជុំអាចឱ្យអ្នកផ្តល់ការថែទាំរៀបចំកិច្ចប្រជុំជាមួយនឹងម្តាយ ឪពុក និងអ្នកថែទាំផ្សេងទៀត និង/ឬ អ្នកគ្រប់គ្រង។ គួររៀបចំឱ្យមានជាតុមួយ កៅអី និងកន្លែងរក្សាទុកឯកសារ។ កន្លែងប្រជុំនេះ គឺជាការរៀបចំជាជម្រើសក្នុងទារកដ្ឋាន។

- **បរិវេណខាងក្រៅ**

ទារកដ្ឋាននៃក្រសួងកិច្ចការនារីបច្ចុប្បន្ននេះមានទីកន្លែង/សួនកុមារដែលនៅខាងក្រៅបន្ទប់។ ប្រសិនបើក្រសួងកិច្ចការនារី ចង់ជួសជុលកែលម្អបរិវេណខាងក្រៅនេះ ក្រសួងត្រូវពិចារណាបំពាក់បេងសុវត្ថិភាព ឧបករណ៍សម្រាប់ជួយអភិវឌ្ឍជំនាញចលនាតូច និងចលនាធំរបស់កុមារ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងបរិក្ខារផ្សេងទៀត។ ការជួសជុលកែលម្អត្រូវតែមានលក្ខណៈកុមារមេត្រី និងត្រូវគិតពីអាយុ សុខភាព សុវត្ថិភាព និងសន្តិសុខកុមារ។

- **បន្ទប់បំបៅដោះកូន**

បន្ទប់បំបៅដោះកូនគួរមានក្រឡាផ្ទៃ៣ម២។ បន្ទប់បំបៅដោះកូន ត្រូវតែផ្តល់ភាពកក់ក្តៅសម្រាប់ទារក ព្រោះថាទារកមួយចំនួនអាចគេងលក់ពេលបៅដោះម្តាយ។ ម្តាយត្រូវមានអារម្មណ៍សុវត្ថិភាពនៅពេលបំបៅដោះកូន និងមិនគួរឱ្យអ្នកដទៃទៀតមើលឃើញឡើយ។

- **បរិក្ខារផ្សេងទៀត**

ចាំបាច់ត្រូវមានបរិក្ខារជាមូលដ្ឋានផ្សេងទៀត ដើម្បីជានាប្រតិបត្តិការ ការផ្តល់សេវា និងការគ្រប់គ្រងទារកដ្ឋានជាប្រចាំថ្ងៃ។ បរិក្ខារទាំងនេះរួមមាន ប្រអប់សង្គ្រោះបឋម កន្លែងរក្សាទុកសម្ភារអនាម័យ (ដូចជា ទឹកលាងដៃជាដើម) ព្រមទាំងសម្ភារសម្រាប់ធ្វើការផ្លាស់ប្តូរសម្លៀកបំពាក់ឱ្យកុមារ (ខោទឹកនោម សម្ភារសម្រាប់សម្អាត) ធុងសំរាម ម៉ាស៊ីនសម្រាប់ដាក់ទឹកត្រជាក់ និងធុងចម្រោះទឹក។

### *២.១.៤. ការរៀបចំ និងគ្រឿងសង្ហារិម*

ទារកត្រូវការកន្លែង និងសង្ហារិម ដែលរៀបចំជាពិសេសនៅទារកដ្ឋាន។

- **ការរៀបចំទីកន្លែងសម្រាប់ទារកត្រូវបញ្ចូលចំណុចដូចខាងក្រោម៖**

- អាចឱ្យអ្នកថែទាំមើលឃើញ និង/ឬស្តាប់ឮកុមារទាំងអស់នៅពេលដែលពួកគេក្រឡេកមួយភ្លែត ឬអាចធ្វើអន្តរាគមន៍នៅពេលដែលចាំបាច់
- មានទីធ្លាបើកចំហ ដែលមានសុវត្ថិភាព សម្រាប់ឱ្យកុមារធ្វើសកម្មភាពដោយសេរី និងលេងកម្សាន្ត
- បែងចែកការថែទាំទារកអាយុក្រោម១៨ខែ ពីកុមារដែលមានអាយុចាប់ពី១៨ខែ លើកលែងតែនៅពេលមានកុមារចាប់ពី១២ នាក់ចុះ នៅក្នុងទារកដ្ឋាន។
- ដាក់អង្រឹងឱ្យឃ្លាតឆ្ងាយពីគ្នាសមល្មម ដើម្បីកុំឱ្យទារកម្នាក់តោងអង្រឹងរបស់ទារកម្នាក់ទៀត

- ផ្តល់ឱ្យអ្នកផ្តល់ការថែទាំនូវទីកន្លែងដែលធំគ្រប់គ្រាន់ សម្រាប់ដើរ និងធ្វើការនៅចន្លោះអង្រឹង គ្រែតូច សម្រាប់ទារក និងកន្ទេល។ល។
- ធានាថាកុមារដែលមានអាយុច្រើននឹងមិនប្រើប្រាស់កន្លែងរបស់កុមារតូចសម្រាប់ដើរកាត់ទៅផ្នែកដទៃទៀត នៃបន្ទប់ ឬអគារឡើយ។

ទារកត្រូវការបរិយាកាសស្ងប់ស្ងាត់ នៅឆ្ងាយពីកន្លែងដែលកុមារអាយុច្រើនជាងត្រូវការរៀនសូត្រ។ ការដាក់អង្រឹងនៅឆ្ងាយពីគ្នា អាចបង្ការមិនឱ្យកុមារម្នាក់ឡើងតោងអង្រឹងរបស់កុមារម្នាក់ទៀតបាន និងដើម្បីធានាសុវត្ថិភាពរបស់ទារកទូទៅ។ ការដាក់គម្លាតគ្នាបែបនេះក៏កាត់បន្ថយលទ្ធភាពនៃការចម្លងជំងឺផ្លូវដង្ហើម តាមរយៈដំណក់ទឹកចេញពីការផ្តាសាយ ឬការក្អក និងអាចមានប្រសិទ្ធភាពក្នុងការទប់ស្កាត់ការចម្លងផ្សេងទៀតនៅកន្លែងថែទាំកុមារ។

- **សង្ហារិម និងបរិក្ខារសម្រាប់កន្លែងរបស់ទារក**

សង្ហារិម និងបរិក្ខារសម្រាប់ទារកត្រូវមានដូចខាងក្រោម៖

- កៅអីបះបើក ឬកៅអី ទំហំសម្រាប់មនុស្សពេញវ័យអង្គុយបាន
- អង្រឹងដាច់ដោយឡែកពីគ្នា សម្រាប់ទារកដែលមិនទាន់អាចដើរបាន
- អង្រឹង គ្រែតូចសម្រាប់ទារក គ្រែ ឬកន្ទេលដែលមិនជ្រាបទឹក និងអាចលាងសម្អាតបាន ដាច់ដោយឡែកពីគ្នា សម្រាប់កុមារដែលចេះដើរ
- កន្លែងលាងសម្អាតដៃនៅក្នុងបរិវេណសម្រាប់ប្តូរខោទឹកនោមក្មេង
- របស់របរលេងក្នុងចំនួនគ្រប់គ្រាន់ ដើម្បីឱ្យកុមារបន្តចូលរួមនៅក្នុងសកម្មភាពនានា។

អង្រឹង ឬកៅអីបះបើក អាចឱ្យអ្នកផ្តល់ការថែទាំកាន់អង្រួន លួង និយាយ ច្រៀង និងអានឱ្យទារកស្តាប់ ប្រកបដោយភាពស្និទ្ធស្នាល និងស្រឡាញ់បីបម។ វាក៏ជាកន្លែងសម្រាប់ឱ្យម្តាយបំបៅកូនផងដែរ។

- **ប្រភេទបរិក្ខារដាក់លាក់ដែលហាមមិនឱ្យប្រើប្រាស់ជាមួយនឹងទារក**

ខាងក្រោមនេះគឺជាបញ្ជីវត្ថុដែលត្រូវបានកំណត់ថាពុំមានសុវត្ថិភាព និងមិនត្រូវប្រើប្រាស់ក្នុងទារកដ្ឋាន៖

- ចង្រ្កងសម្រាប់ក្មេងរៀនដើរ
- ចង្រ្កងពាក់ជាប់ខ្លួនសម្រាប់ក្មេងដោលជើងចុះឡើង (Baby bungee jumpers)
- ប្រដាប់លេងដែលមានទំហំតូច ដែលអាចធ្វើឱ្យក្មេងលេបចូល ឬស្លាក់
- របងសុវត្ថិភាពដែលមានលក្ខណៈជាទ្វាររូត (Accordion safety gates)
- កៅអីពូកទន់ខ្លាំង ពូកទឹក (waterbeds) និងកន្ទេលប៉ុង ដែលប្រើប្រាស់ជាសម្ភារសម្រាប់គេង

- កម្រាលដែលទន់ ឬរលុង ដូចជា ភួយ ឧបករណ៍សម្រាប់ទ្រាប់គេង របស់លេង ដែលមានញាត់សំឡីពីខាងក្នុងខ្នើយឱប ខ្នើយកើយ កម្រាលក្រាលក្នុងផ្ទៃគ្រែ និងសម្ភារផ្សេងៗសម្រាប់លួងកុមារ។ របស់របរទាំងនេះមិនត្រូវប្រើប្រាស់ក្នុងអង្រឹងសម្រាប់កុមារដែលមានអាយុក្រោម ១២ ខែឡើយ។

> ចង្រ្កងសម្រាប់ក្មេងរៀនដើរ (Baby walkers) អាចបង្កជាគ្រោះថ្នាក់ ដោយសារតែហានិភ័យធ្លាក់តាមជណ្តើរ ឬជំពប់នឹងគែមព្រំ ឬជញ្ជាំង។ ឧបករណ៍នេះធ្វើឱ្យកុមារអាចទៅកន្លែងដែលមានផ្ទៃក្តៅ ដូចជា ទ្វារចង្ក្រានកម្តៅ ម៉ាស៊ីនដុតកំដៅ និង ធុងដាក់ទឹកក្តៅ ដូចជា កាហ្វេ សម្លរ ឬប្រេងឆា។ ខ្សែឧបករណ៍ប្រើប្រាស់ដែលរយីងរយោង រុក្ខជាតិដែលមានជាតិពុល ឬសារធាតុដែលមានគ្រោះថ្នាក់ និងធុងទឹកបង្គន់ ឬឧបករណ៍សម្រាប់ដាក់ទឹកផ្សេងទៀត។ ចង្រ្កងពាក់ជាប់ខ្លួនសម្រាប់ក្មេងដោលជើងចុះឡើង តម្រូវឱ្យមានការតាមមើលកុមារ ដើម្បីរក្សាសុវត្ថិភាពរបស់ពួកគេ។ ឧបករណ៍ទាំងនេះមិនសមស្របសម្រាប់ប្រើប្រាស់ជាក្រុមឡើយ។ ទ្វាររូតដែលមានកន្លែងចូលរាងជាអក្សរ V នៅគែមខាងលើ និងរាងបួនជ្រុងការ៉ូបួនជ្រុងនៅចន្លោះចម្រៀកតូចៗ អាចធ្វើឱ្យកុមារទាក់ជាប់ ដែលអាចធ្វើឱ្យពួកគេទាក់ក ថប់ខ្យល់ ឬកៀបកុមារដែលព្យាយាមវារឆ្លងកាត់ ឬវារលើទ្វាររបងនោះ។ ឧទាហរណ៍អំពីវត្ថុដែលអាចបង្កគ្រោះថ្នាក់ ស្លាក់ខ្យល់ដល់ទារក និងកុមារតូចៗ រួមមាន កាក់ប៉េងប៉ោង ម្ជុល គ្រាប់ឃ្លី ស្ពៃ និងរបស់របរស្រដៀងគ្នានេះ និងអេប៉ុង កៅស៊ូ ឬប្រដាប់លេងដែលធ្វើពីជ័រទន់។ ការសិក្សាអំពីបញ្ហាដែលធ្វើឱ្យទារកស្លាប់ភ្លាមៗ គាំទ្រមិនឱ្យមានការប្រើប្រាស់កម្រាលទន់ ឧបករណ៍សម្រាប់ដាក់ឧបករណ៍សម្រាប់កំណត់ទីតាំងគេ និងប្រដាប់លេងដែលមានញាត់សំឡី សម្រាប់កុមារដែលមានអាយុ ១២ ខែឡើយ។

# ផ្នែកទី៣ ៖ សកម្មភាពដែលអនុវត្តជាប្រចាំនៅក្នុងទារកដ្ឋាន

## *៣.១. កាលវិភាគប្រចាំថ្ងៃ អំពីសកម្មភាពនៅក្នុងទារកដ្ឋាន*

ដើម្បីឱ្យស្របតាមម៉ោងធ្វើការរបស់ក្រសួងកិច្ចការនារី ទារកដ្ឋានបានបើកទទួលកុមារពីម៉ោង ៧:៣០ នាទីព្រឹក រហូតដល់ ៥:៣០ នាទីរសៀល (៣០នាទីមុន និង ៣០នាទី ក្រោយម៉ោងធ្វើការងារ)។ ទារកដ្ឋានបើកដំណើរការពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ និងបិទនៅថ្ងៃសៅរ៍ អាទិត្យ ឬថ្ងៃបុណ្យជាតិផ្សេងៗ។ ខណៈពេលដែលកុមារអាចចេញចូលជាមួយនឹងកាលវិភាគខុសៗគ្នា ត្រូវមានការរៀបចំសកម្មភាពជាទៀងទាត់នៅរៀងរាល់ថ្ងៃនីមួយៗ និងត្រូវមានភាពបត់បែនក្នុងកម្រិតមួយសមស្រប ដើម្បីឆ្លើយតបចំពោះតម្រូវការរបស់កុមារ ដែលមានកាលវិភាគមិនទៀងទាត់ ឬកុមារដែលមកទារកដ្ឋានតែម្តងម្កាល។ សកម្មភាពនៅក្នុងទារកដ្ឋានត្រូវអនុវត្តតាមកាលវិភាគប្រចាំថ្ងៃដូចខាងក្រោម៖

### *៣.១.១. ការទទួលស្វាគមន៍កុមារ*

កុមារអាចមកដល់ពេលខុសៗគ្នា ខណៈពេលដែល ពេលវេលាសម្រាប់ទទួលកុមារចាប់ផ្តើមពីម៉ោង ៧:៣០ នាទីព្រឹកទៅ។ ក្រោយពេលមកដល់ ម្តាយ ឪពុកត្រូវចុះហត្ថលេខាលើតារាងវត្តមាន (សូមមើលឧបសម្ព័ន្ធទី ១៤) និងផ្តល់សម្ភារដែលចាំបាច់ទាំងអស់សម្រាប់កុមារ (ដូចជា ទឹកដោះគោ ដបទឹក ចំណី ខោទឹកនោម ។ល។) ព្រមទាំងការណែនាំដែលអ្នកផ្តល់ការថែទាំចាំបាច់ត្រូវដឹង។ កុមារគួរស្លៀកពាក់សម្លៀកបំពាក់សមស្របទៅតាមអាយុ និងអាចឱ្យពួកគេអាចធ្វើចលនាដោយសេរីបាន។ សម្លៀកបំពាក់គួរការពារភាពជាឯកជន និងបូរណភាពរាងកាយរបស់ពួកគេ ដើម្បីឱ្យពួកគេមានអារម្មណ៍ថា ទទួលបានការគោរពពីអ្នកដទៃផងដែរ។

## *៣.២. ការថែទាំ និងសកម្មភាពសម្រាប់ទារក និងកុមារតូចៗ*

### *៣.២.១. ការថែទាំ និងសកម្មភាពសម្រាប់ទារក (អាយុ ០-១៨ ខែ)*

- **ការថែទាំជាមូលដ្ឋានសម្រាប់ទារករួមមាន៖**
  - ការថែទាំត្រូវធ្វើឡើងដោយអ្នកផ្តល់ការថែទាំដដែលជាទៀងទាត់ នៅពេលដែលអាចធ្វើទៅបាន
  - ចាំបាច់ត្រូវមានការយកចិត្តទុកដាក់ពីអ្នកថែទាំម្នាក់ ចំពោះកុមារម្នាក់ៗ ដូចជា ពេលលេង ពេលនិយាយប្រលែង និងបីទារកជាដើម
  - បី និងលួងកុមារដែលមិនសប្បាយចិត្ត
  - ផ្តល់ការយកចិត្តទុកដាក់ជាបន្ទាន់ចំពោះតម្រូវការផ្លូវកាយ ដូចជា ការផ្តល់អាហារ និងការប្តូរខោទឹកនោមជាដើម
  - និយាយទៅកាន់កុមារ ពេលកំពុងផ្តល់ចំណី ប្តូរខោទឹកនោម និងបីកុមារ
  - ប្រាប់ពីឈ្មោះវត្ថុ ច្រៀង ឬនិយាយដោយប្រើពាក្យចុងជួនជាដើម
  - ធានាថានៅក្នុងមជ្ឈដ្ឋានជុំវិញពុំមានវត្ថុដែលអាចធ្វើឱ្យកុមារអាយុក្រោមបីឆ្នាំស្លាក់ ឬមានគ្រោះថ្នាក់
  - មិនត្រូវទុកទារកចោលដោយគ្មានការឃ្លាំមើលនោះឡើយ។

- **សកម្មភាពសម្រាប់កុមាររួមមាន៖**
- រៀបចំឱ្យកុមារលេងនៅខាងក្រៅឱ្យបានរាល់ថ្ងៃ ប្រសិនបើអាកាសធាតុអំណោយផល
- រៀបចំឱ្យកុមារតូចលេងនៅក្រៅអគ្រឹងរបស់ពួកគេ ឬរៀបចំការខណ្ឌចែកពួកលេងបានច្រើនដងជារៀងរាល់ថ្ងៃ
- រៀបចំឱ្យកុមារតូចអាចមានឱកាសឈោង ចាប់ ទាញ លូន វារ និងដើរនៅកន្លែងដែលស្អាត មានសុវត្ថិភាព និងពុំមានរបស់របរបាំងផ្លូវរញ៉េរញ៉ៃ
- រៀបចំឱ្យកុមារមានឱកាសទទួលបានការមើលឃើញតាមរយៈរូបភាព តាមរយៈការប្រាស្រ័យទាក់ទងដោយមិនប្រើពាក្យសម្ដី។ ឧទាហរណ៍ ឧបករណ៍សមស្របតាមអាយុ រួមមាន រូបភាពទំហំធំៗ ដូចជា រូបមុខមនុស្ស វត្ថុដែលពួកគេធ្លាប់ស្គាល់ សៀវភៅ និងប្រដាប់លេង ដែលសាមញ្ញ ទន់ និងអាចលាងសម្អាតបាន កញ្ចក់ដែលមិនបែក ឬវត្ថុចល័តភ្ជាប់ជាមួយនឹងអគ្រឹង ដែលទារកអាចមើលឃើញ និងប្រើកម្រាលអគ្រឹងដែលមានពណ៌ក្រឡេក្រឡាភ្លឺៗ
- រៀបចំឱ្យកុមារមានឱកាសទទួលបានការភ្ញោចឮជាសំឡេង។ ឧទាហរណ៍ អំពីឧបករណ៍ ឬសកម្មភាពសមស្របតាមអាយុ ដូចជា ការប្រាស្រ័យទាក់ទង ដោយប្រើប្រាស់សម្ដី ការចាក់ភ្លេងសម្រាប់លួងកុមារ និងប្រដាប់លេងដែលបន្លឺសំឡេងជាតន្ត្រី/របស់លេងដែលអាចបញ្ចេញសំឡេងបាន
- រៀបចំឱ្យកុមារមានឱកាសសម្រាប់ការភ្ញោច ឬប្រើប្រាស់ញាណដទៃទៀត។ ឧទាហរណ៍អំពីឧបករណ៍សមស្របតាមអាយុ ដូចជា ផ្ទៃខាងលើ ក្រណាត់ ប្រដាប់លេងដែលគ្រើម កូនក្រមុំដែលអាចលាងសម្អាតបាន និងប្រដាប់លេងជារូបសត្វ
- រៀបចំឱ្យកុមារមានឱកាសសម្រាប់ការអភិវឌ្ឍសាច់ដុំតូច។ ឧទាហរណ៍អំពីឧបករណ៍ដែលសមស្របតាមអាយុ រួមមាន ប្រអប់សម្រាប់ឱ្យកុមារលេង, ឧបករណ៍អង្រន់លេងរបស់ទារកដែលបន្លឺសូរក្រឹកៗរណ្ដំគ្នា, ក្បាលជញ្ជក់សម្រាប់ទារក ប្រដាប់លេងដើម្បីឱ្យកុមារចាប់កាន់ ប្រដាប់លេងសម្រាប់ឱ្យកុមារលោក់ ឬច្របាច់ ឬប្រដាប់លេងធ្វើពីក្រណាត់ជាដើម
- រៀបចំឱ្យកុមារមានឱកាសសម្រាប់ការអភិវឌ្ឍសាច់ដុំធំ។ ឧទាហរណ៍អំពីឧបករណ៍ ឬសកម្មភាពដែលសមស្របសម្រាប់អាយុមានដូចជា កួយ ឬ កួយមានញាត់សំឡីក្នុង សម្រាប់ពេលឱ្យកុមារគេងនៅលើឥដ្ឋ អគ្រឹង និង កន្លែងលេងសម្រាប់ទារក ក៏ដូចជា បាល់ដែលមានទម្ងន់ស្រាលៗ ខ្នើយ ឬឧបករណ៍ជួយទប់សម្រាប់កុមារដែលរៀនអង្គុយ
- ក្នុងអំឡុងពេលនៃការរាតត្បាតជាសកលដោយសារជំងឺកូវីដ-១៩ ឬជំងឺឆ្លងរាតត្បាតផ្សេងៗ ទារកដ្ឋាន នៅផ្ទៃខាងក្នុង និងខាងក្រៅ ឧបករណ៍ និងវត្ថុនានា ត្រូវការការសម្អាត និងការធ្វើអនាម័យឱ្យបានច្រើនដងជាងពេលធម្មតា។ ឧទាហរណ៍អំពីការរក្សាអនាម័យ រួមមាន ការដាក់ទឹកលាងសម្អាតដៃនៅកន្លែងដែលអាចឱ្យអ្នកផ្ដល់ការថែទាំលាងសម្អាតដៃឱ្យបានឆាប់ ប៉ុន្តែត្រូវដាក់ឱ្យផុតពីដៃរបស់កុមារ។

ឱកាសលេងកម្សាន្តនៅខាងក្រៅជារៀងរាល់ថ្ងៃ ជួយឱ្យកុមារមានសុខភាពមាំមួន។ ខ្យល់ធម្មជាតិនៅកន្លែងដែលមានទំហំធំ មានចំនួនមេរោគកាន់តែតិច។ ត្រូវរក្សាកន្លែងនៅខាងក្រៅទារកដ្ឋាន និងគ្រប់ឧបករណ៍ទាំងអស់ឱ្យស្អាត និងមានអនាម័យ ជាពិសេសក្នុងអំឡុងពេលនៃការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩។

### *៣.២.២. ការថែទាំ និងសកម្មភាពសម្រាប់កុមារតូច (អាយុពី ១៨-៣៦ ខែ)*

អ្នកផ្តល់ការថែទាំគួរមើលថែកុមារក្នុងគ្រប់សកម្មភាពប្រចាំថ្ងៃ ទាំងខាងក្នុងទារកដ្ឋាន និងខាងក្រៅទារកដ្ឋាន។ ដោយសារតែកុមារមានអាយុខុសគ្នា ដំណាក់កាលនៃការអភិវឌ្ឍ និងសមត្ថភាពផ្សេងៗគ្នា និងប្រភេទសម្ភារដែលមាននៅទារកដ្ឋាន ដូចនេះសកម្មភាពនានាត្រូវបញ្ចូលភ្លេង ចម្រៀង ល្បែង ការរាំ ការឡើង ការដើរ ការអប់រំអំពីធម្មជាតិ និងការធ្វើកាយវិការបែបអប់រំ ព្រមទាំងភាពច្នៃប្រឌិតនានា ដោយសារសកម្មភាពទាំងនេះអាចជួយឱ្យកុមារអភិវឌ្ឍបំណិនរបស់ពួកគេ។

- **សកម្មភាព និងការថែទាំជាមូលដ្ឋានសម្រាប់កុមារតូច (អាយុពី ១៨-៣៦ ខែ)**
  - បំណិនដែលពាក់ព័ន្ធនឹងការប្រើប្រាស់សមត្ថភាពគិត និងការអភិវឌ្ឍញាណ ប្រដាប់លេងសម្រាប់តម្រៀបរៀន/តម្រៀបវត្ថុប្រដាប់លេងបែបសង់ផ្ទះ រូបផ្គុំដែលមិនច្រើនជាង៦បំណែក សៀវភៅ ឬក្តារខៀនដែលលុបបាន ឬលាងសម្អាតបាន ប្រដាប់លេងសម្រាប់ផ្គុំ និងរើចេញបាន ឬលាងសម្អាតបាន ។
  - ការអភិវឌ្ឍសាច់ដុំតូច៖ ខ្មៅដៃ និងហ្វឺតធំៗ ដែលសរសេរហើយ អាចលាងសម្អាតបាន ក្រដាស់ និងសម្ភារសិល្បៈចម្រុះ តុ ឬ ជើងទ្រ ប្រដាប់លេងដូចជាយានយន្តធ្វើដំណើរដែលអាចលាងសម្អាតបាន រូបសត្វ និងរូបមនុស្សសម្រាប់លេងជាដើម។
  - ការអភិវឌ្ឍសាច់ដុំធំ៖ សំណង់ដែលមានកម្ពស់ទាបសម្រាប់ឡើង ប្រដាប់លេងតូចៗដែលអាចជិះបាន ប្រដាប់លេងសម្រាប់រុញ ឬទាញ បាល់ស្រាលៗច្រើនប្រភេទសម្រាប់ការលេងនៅក្នុងអគារ និងនៅខាងក្រៅ ឧបករណ៍ដែលបន្លឺសំឡេងបាន។
  - ការអភិវឌ្ឍភាសា៖ សត្វទន់ៗ ឬរូបតុក្កតាដែលអាចលាងសម្អាតបាន សៀវភៅរូបភាពងាយៗ រូបភាពដែលបង្ហាញពីវត្ថុ និងទីកន្លែង ដែលកុមារធ្លាប់ស្គាល់។
  - ការទំនាក់ទំនងសង្គម/អារម្មណ៍៖ សម្លៀកបំពាក់សម្រាប់ស្លៀកលេង និងគ្រឿងតុបតែង ឧបករណ៍សម្រាប់ថែទាំផ្ទះ កញ្ចក់ដែលមិនបែក រូបកូនក្រមុំដែលអាចលាងសម្អាតបាន អមនឹងវត្ថុសម្រាប់តុបតែង វត្ថុសម្រាប់រៀនបិទឡេវ រូតចុះរូតឡើង ចងខ្សែ និង ផ្ទាត់ដៃឱ្យឮសំឡេង និងកន្ត្រក បំពង់ និងថង់ក្រណាត់ (មិនមែនជាថង់ប្លាស្ទិក) សម្រាប់យួរ។
  - ជំនាញអន្តរបុគ្គល៖ ការប្រើប្រាស់បង្គន់ ការលាងសម្អាតដៃ និងការញ៉ាំអាហារ។
- **ការលេង**

  ការសិក្សាមួយចំនួនបានបង្ហាញថា ការអភិវឌ្ឍមុខងារចលនាអាចកើតឡើងដោយឯកឯង។ ប្រសិនបើកុមារត្រូវបានអនុញ្ញាតឱ្យធ្វើសកម្មភាពដោយខ្លួនឯង ពួកគេអាចអភិវឌ្ឍខ្លួនក្លាយជាមនុស្សពេញវ័យដោយមាន

ភាពម្ចាស់ការ។ កុមារអាចរៀនសូត្រដោយខ្លួនឯង ដែលអាចជួយឱ្យពួកគេកាន់តែមានភាពម្ចាស់ការ។

- **ឥរិយាបថ ឬវត្ថុមួយចំនួនដែលគួរជៀសវាង**

  ការប្រើប្រាស់សម្ភារសម្រាប់ជួយឱ្យកុមារអង្គុយ គេង ឬដើរច្រើនពេក (ដូចជា កៅអីសម្រាប់បញ្ចុកអាហារ ខ្នើយ ចង្រ្កងសម្រាប់កុមាររៀនដើរ។ល។) អាចបង្កផលប៉ះពាល់ជាអវិជ្ជមានដល់ការរៀនដើររបស់កុមារ ដោយសារតែពួកគេប្រើប្រាស់ម្រាមជើងជំនួសកែងជើង។ ជាការសំខាន់ណាស់ដែលពួកគេត្រូវរៀនទប់លំនឹងដោយខ្លួនឯង។

### ៣.២.៣. អាហារ និងអាហារសម្រន់

កុមារត្រូវការញ៉ាំអាហារ និង/ឬអាហារសម្រន់នៅពេលដែលពួកគេស្ថិតនៅក្នុងទារកដ្ឋាន។ កុមារតូចៗអាចញ៉ាំលើតុជាមួយនឹងកុមារផ្សេងទៀត ប្រើប្រាស់កៅអីទៅតាមអាយុរបស់ពួកគេ។ កុមារដែលមានអាយុច្រើនអាចញ៉ាំជាមួយគ្នា អ្នកផ្តល់ការថែទាំអាចជួយពួកគេជាក្រុមតូចៗ (អ្នកផ្តល់ការថែទាំម្នាក់សម្រាប់ក្រុមនីមួយៗ)។ ទារកដ្ឋានរបស់ក្រសួងកិច្ចការនារីគួរពិចារណាផ្តល់អាហារ និងអាហារសម្រន់ដែលជួយទ្រទ្រង់សុខភាពកុមារអាយុចាប់ពី ៦ ខែ ដោយត្រូវការរៀបចំអាហារទាំងនេះឱ្យស្របតាមអាយុរបស់ពួកគេ។ ម្តាយអាចទៅបំបៅដោះកូន ម្តាយឪពុកអាចទៅមើល និងផ្តល់អាហារថ្ងៃត្រង់ដល់កូន នៅក្នុងអំឡុងម៉ោងធ្វើការរបស់ទារកដ្ឋាន។ ប្រសិនបើម្តាយ ឬឪពុកម្តាយកំពុងធ្វើការពុំមានពេល ឬកំពុងបំពេញភារកិច្ចនៅពេលអាហារថ្ងៃត្រង់ ពួកគេអាចប្រាប់អ្នកផ្តល់ការថែទាំជាមុន ដើម្បីស្នើសុំឱ្យពួកគេជួយផ្តល់អាហារថ្ងៃត្រង់ដល់កូន (ប្រាប់នៅពេលដែលកូនមកដល់ពេលព្រឹក)។

ក្នុងទារកដ្ឋានត្រូវមានទឹកស្អាតសម្រាប់ញ៉ាំជាប្រចាំ។ ការញ៉ាំទឹកជាមធ្យមប្រចាំថ្ងៃគឺ ១ លីត្រសម្រាប់កុមារម្នាក់។ ទឹកសម្រាប់កុមារញ៉ាំ ត្រូវតែជាទឹកដែលមានសុវត្ថិភាព និងគុណភាពល្អ ដើម្បីការពារកុមារពីជំងឺនានា ដូចជាជំងឺរាគរូសជាដើម។ បើតាមប្រកាសលេខ ០៥៤ ស្តីពីភេសជ្ជៈ ដែលមានអនាម័យ ទឹក ឬភេសជ្ជៈគួររក្សាទុកឱ្យបានត្រឹមត្រូវ ហើយសម្ភារ ឬដបសម្រាប់ផ្តល់អាហារដល់កុមារ ត្រូវតែជាសម្ភារ/ដបដែលស្អាត។ កុមារម្នាក់ៗ ត្រូវមានដប ឬពែងផ្ទាល់ខ្លួន។

### ៣.២.៤. អាហារសម្រន់

នៅចន្លោះ មុន និងក្រោយអាហារថ្ងៃត្រង់ អ្នកថែទាំអាចផ្តល់អាហារសម្រន់ដែលទ្រទ្រង់សុខភាពដល់កុមារ (តាមអាយុរបស់ពួកគេ)។ កុមារដែលមានអាយុលើសពី ៦ ខែ ត្រូវការអាហារសម្រន់បន្ថែម ទៅតាមការណែនាំ របស់ក្រសួងសុខាភិបាល។ ទារកដ្ឋានរបស់ក្រសួងកិច្ចការនារី គួរពិចារណាផ្តល់អាហារសម្រន់ដល់កុមារដោយប្រើប្រាស់ថវិកាប្រតិបត្តិរបស់ក្រសួងកិច្ចការនារី។ ប្រសិនបើចំណាយលើសពីសមត្ថភាពថវិការបស់ក្រសួងកិច្ចការនារី ក្រសួងកិច្ចការនារីត្រូវពិចារណាស្នើសុំឱ្យម្តាយ ឪពុកចេញថ្លៃចំណាយនេះ ដើម្បីឱ្យបុគ្គលិកទារកដ្ឋានទិញអាហារសម្រន់ដែលល្អសម្រាប់សុខភាពកុមារ។ សម្រាប់ប្រភេទអាហារសម្រន់ទាំងនេះ សូមមើលតារាងទី១៖ ការណែនាំស្តីពីអាហារបន្ថែម។ ម្តាយឪពុកចាំបាច់ត្រូវស្នើសុំឱ្យអ្នកថែទាំផ្តល់អាហារសម្រន់ឱ្យកូនរបស់ខ្លួន។ ម្តាយឪពុកចាំបាច់ត្រូវប្រាប់ទៅអ្នកថែទាំ ប្រសិនបើកូនរបស់ពួកគេមិនអាចញ៉ាំអាហារមួយចំនួនបាន — សូមមើលឧបសម្ព័ន្ធទី ៣ និងទី ៥។ នៅរៀងរាល់ថ្ងៃ អ្នកថែទាំចាំបាច់ត្រូវផ្តល់អាហារជាប្រចាំថ្ងៃដល់កុមារ — សូមមើលឧបសម្ព័ន្ធទី ៨។

### ៣.២.៥. អាហារថ្ងៃត្រង់

ស្រដៀងគ្នានឹងអាហារសម្រន់ដែរ ទារកដ្ឋានរបស់ក្រសួងកិច្ចការនារី គួរផ្តល់អាហារថ្ងៃត្រង់ដោយយកចិត្តទុកដាក់អំពីអាហាររូបត្ថម្ភដល់កុមារទៅតាមអាយុរបស់ពួកគេ។ ទារកដ្ឋានរបស់ក្រសួងកិច្ចការនារី ត្រូវពិចារណាចំណាយថវិកាប្រតិបត្តិរបស់ខ្លួនសម្រាប់ការទិញអាហារថ្ងៃត្រង់ ឬឱ្យម្តាយ ឪពុករ៉ាប់រងលើការទិញអាហារនេះ។ សម្រាប់ប្រភេទអាហារ/ចំណីដែលល្អសម្រាប់សុខភាព សូមមើលតារាងទី១៖ អនុសាសន៍ស្តីពីអាហារបន្ថែម។ ដោយសារតែម្តាយ ឪពុក មួយចំនួនអាចទៅមើលកូនរបស់ខ្លួនក្នុងពេលសម្រាកអាហារថ្ងៃត្រង់ ពួកគេអាចផ្តល់អាហារថ្ងៃត្រង់ដល់កូនៗរបស់ខ្លួនផងដែរ។

ប្រសិនបើម្តាយ ឪពុកពុំមានពេលក្នុងពេលអាហារថ្ងៃត្រង់ទេ ពួកគេចាំបាច់ត្រូវប្រាប់ឱ្យអ្នកថែទាំផ្តល់អាហារថ្ងៃត្រង់ដល់កូនរបស់ខ្លួន។ ម្តាយ ឪពុកចាំបាច់ត្រូវប្រាប់ដល់អ្នកថែទាំ ក្នុងករណីដែលកូនរបស់ពួកគេត្រូវតមអាហារអ្វីមួយ — សូមមើលឧបសម្ព័ន្ធទី ៣ និងទី ៥។ ជារៀងរាល់ថ្ងៃ អ្នកថែទាំចាំបាច់ត្រូវផ្តល់អាហារប្រចាំថ្ងៃដល់កុមារ — សូមមើលឧបសម្ព័ន្ធទី ៨។

> កុមារដែលមានអាយុច្រើនអាចញ៉ាំជុំគ្នាជាក្រុមតូចៗ ដោយអ្នកថែទាំចាំជួយ (អ្នកថែទាំម្នាក់សម្រាប់ក្រុមនីមួយៗ)។ ពេលញ៉ាំអាហារថ្ងៃត្រង់ គួរធ្វើឡើងដោយពុំមានការរំខាន (ឧទាហរណ៍ ទូរទស្សន៍ ឬការលេងជាមួយនឹងថេបប្លេត) ដើម្បីឱ្យកុមារអាចបានសម្រាក និងបង្កើតបរិយាកាសឱ្យបានល្អ ពេលដែលពួកគេកំពុងញ៉ាំអាហារ។ អ្នកថែទាំមិនគួរបង្ខំកុមារឱ្យញ៉ាំឡើយ ប្រសិនបើពួកគេមិនចង់ញ៉ាំនោះ។

នៅមុនអាហារថ្ងៃត្រង់ អ្នកថែទាំគួរលាងមាត់ និងដៃរបស់កុមារ និងផ្លាស់ប្តូរខោទឹកនោមរបស់ពួកគេប្រសិនបើចាំបាច់។ ក្រោយអាហារថ្ងៃត្រង់ អ្នកថែទាំគួរសម្អាតកុមារម្តងទៀត និងរៀបចំពួកគេសម្រាប់ពេលគេង។ អ្នកថែទាំ ក៏គួរដឹង និងយកចិត្តទុកចំពោះកុមារ ដែលត្រូវការញ៉ាំអាហារច្រើនជាងកុមារផ្សេងទៀតផងដែរ។

- **អ្វីដែលត្រូវធ្វើសម្រាប់ការផ្តល់អាហារដល់ទារក**
  - បីទារកដែលមានអាយុចាប់ពី ០ ខែរហូតដល់ ៦ ខែ ពេលផ្តល់អាហារដល់ពួកគេ
  - បីទារកដែលមានអាយុលើសពី ៦ ខែដែលមិនអាចអង្គុយដោយខ្លួនឯងបានលើកៅអីដែលខ្ពស់ ឬឧបករណ៍សម្រាប់អង្គុយដទៃទៀត ពេលផ្តល់អាហារដល់ពួកគេ
  - សូមកុំដាក់ដបទឹកដោះគោបញ្ឈរចោលឱ្យទារកបៅដោយខ្លួនឯង។ ទារក ឬមនុស្សពេញវ័យ ត្រូវកាន់ដប
  - រៀបចំពេលផ្តល់ចំណី និងអាហារឱ្យបានទៀងទាត់ដល់ទារកដែលគ្រប់អាយុអាចញ៉ាំអាហារបាន
  - ធានាថាកុមារដែលលែងត្រូវការការបី ពេលញ៉ាំអាហារ បានទទួលអាហារប្រកបដោយសុវត្ថិភាព
  - ដាក់ស្លាកសម្គាល់ដប និងពែងសម្រាប់បង្រៀនកុមារ ដោយមានឈ្មោះ និងសម្គាល់នាមត្រកូលរបស់កុមារ
  - កុំបណ្តោយឱ្យកុមារដើរជុំវិញ ឬគេងដោយមានកាន់ដប ឬពែង
  - មិនត្រូវប្រើឡាបូសម្រាប់លាងសម្អាតដៃ ឬផ្ទៃសម្រាប់ប្តូរខោទឹកនោម ជាកន្លែងសម្រាប់រៀបចំអាហារ ឬសម្រាប់លាងសម្អាតឧបករណ៍ដែលប្រើប្រាស់សម្រាប់ផ្តល់អាហារ/ចំអិនអាហារ ដប ក្បាលដោះ ឬប្រដាប់

លេងនោះឡើយ
- សម្អាតកៅអីដែលប្រើប្រាស់សម្រាប់បញ្ចុកអាហារកុមារ និងសម្ភារ ក៏ដូចជា វត្ថុដទៃទៀត មុនពេលប្រើប្រាស់ម្តងៗ ជាពិសេសការពារ ការឆ្លងជំងឺកូវីដ-១៩។

- ការស្រាវជ្រាវបង្ហាញថា ដបទឹកដោះគោ អាចធ្វើឱ្យកុមារស្លាក់ និងថប់ដង្ហើម និងបង្កើនហានិភ័យឆ្លងជំងឺត្រចៀក ពុកធ្មេញ និងធ្វើឱ្យធ្មេញវេងរបួស។ វាក៏អាចធ្វើឱ្យកុមារពុំបានទទួលទំនាក់ទំនងផ្ទាល់ដែលពួកគេត្រូវការជាចាំបាច់ផងដែរ។
- ការប្រើទីកន្លែងសម្រាប់ប្តូរខោទឹកនោម និងកន្លែងសម្រាប់លាងសម្អាតដៃ សម្រាប់រៀបចំអាហារ ឬលាងសម្អាតរបស់របរដែលប្រើប្រាស់សម្រាប់ផ្តល់អាហារអាចបង្កើនការចម្លងមេរោគ។

### *៣.២.៦. ការប្តូរខោទឹកនោម*

អ្នកថែទាំត្រូវយកចិត្តទុកដាក់ដើម្បីធានាថាកុមារត្រូវស្អាតជានិច្ចពេញមួយថ្ងៃ។ ចាំបាច់ត្រូវមានការពិនិត្យខោទឹកនោមរបស់កុមារទាំងអស់ និងធ្វើការផ្លាស់ប្តូរ ប្រសិនបើចាំបាច់។ កុមារគួរមានសម្លៀកបំពាក់ដែលធ្វើឱ្យពួកគេស្រួលខ្លួនមុនពេលគេង ហើយខោទឹកនោមត្រូវតែស្អាត។ ជាការសំខាន់ណាស់ដែលកុមារត្រូវមានផាសុកភាពក្នុងពេលគេង។ ម្តាយ ឪពុកចាំបាច់ត្រូវរៀបចំខោទឹកនោមក្នុងចំនួនមួយជាក់លាក់ សម្រាប់ផ្តល់ទៅឱ្យអ្នកថែទាំ ដើម្បីធានាសុខភាព និងអនាម័យសម្រាប់កុមារ។ អ្នកថែទាំគួរប្តូរក្រណាត់ទ្រាប់/ខោទឹកនោមឱ្យបានទៀងទាត់ទៅតាមការណែនាំសំខាន់ៗដូចខាងក្រោម៖

- អ្នកថែទាំគួរប្តូរក្រណាត់ទ្រាប់/ខោទឹកនោមសម្រាប់កុមារម្នាក់ៗ ឱ្យបានយ៉ាងហោចណាស់ពីរដងក្នុងមួយថ្ងៃ (ឧទាហរណ៍ ម្តងនៅម៉ោង ១០ ព្រឹក និងម្តងទៀតនៅម៉ោង ៤ រសៀល) និងឱ្យបានញឹកញាប់បំផុតទៅតាមការចាំបាច់
- ត្រូវអនុវត្តតាមវិធានជាមូលដ្ឋានសម្រាប់ការរក្សាអនាម័យ៖
  - ការប្តូរខោទឹកនោម និងការទុកដាក់ខោទឹកនោមដែលប្រឡាក់ គួរធ្វើដាច់ដោយឡែកពីកន្លែងសម្រាប់រៀបចំអាហារ
  - ត្រូវលាងសម្អាត និងសម្លាប់មេរោគនៅកន្លែងប្តូរខោទឹកនោម ក្រោយរៀងរាល់ពេលប្រើប្រាស់
  - អ្នកថែទាំត្រូវលាងសម្អាតដៃ មុន និងក្រោយពេលប្តូរខោទឹកនោមម្តងៗ។

### *៣.២.៧. ការលេង*

ការលេងដោយសេរី ផ្តល់នូវកន្លែងធំគ្រប់គ្រាន់ និងពេលវេលាគ្រប់គ្រាន់ ដើម្បីឱ្យកុមារលេង និងផ្តល់ឱ្យពួកគេនូវសេរីភាពក្នុងការជ្រើសរើសល្បែងដែលពួកគេចង់លេង។ ការអាចសម្រេចដោយខ្លួនឯង ជួយបង្កើនទំនុកចិត្ត និងភាពម្ចាស់ការរបស់កុមារ។ កុមារដែលត្រូវបានអនុញ្ញាតឱ្យសម្រេចទៅតាមអ្វីដែលខ្លួនចង់បាន និងស្វែងយល់

ដោយសេរី អាចធ្វើសកម្មភាពកាន់តែមានទំនុកចិត្ត។ កុមារអាចជ្រើសរើសអ្វីដែលទាក់ទាញសម្រាប់ពួកគេ ដើម្បីឱ្យពួកគេទទួលបាននូវភាពសប្បាយរីករាយនៅពេលលេង និងសម្រេចបានសក្តានុពលរបស់ពួកគេ។

មានការលើកស្ទួនូវសកម្មភាពលេងជាច្រើនប្រភេទសម្រាប់កុមារ។ ប្រសិនបើចាំបាច់ គេអាចបង្កើតក្រុមកុមារតាមអាយុ ដើម្បីធានាយ៉ាងណាឱ្យសកម្មភាពទាំងនេះសមស្របទៅតាមកម្រិតនៃការអភិវឌ្ឍរបស់ពួកគេ។ កុមារអាចលេងដោយសេរី ដោយខ្លួនឯង ឬលេងទៅតាមសកម្មភាពដែលបានគ្រោងទុក។ ក្នុងពេលលេង អ្នកថែទាំត្រូវសង្កេត និងឃ្លាំមើលកុមារជាប់ជានិច្ច។

សកម្មភាពច្រៀង និងអាន ជានិច្ចជាកាលគឺជាសកម្មភាពដែលល្អនៅចន្លោះសកម្មភាពចំនួនពីរ និង/ឬព្រឹត្តិការណ៍ចំនួនពីរ (នៅពេលចប់សកម្មភាព និងពេលញ៉ាំអាហារថ្ងៃត្រង់ជាដើម)។ សកម្មភាពទាំងនេះ អាចជួយឱ្យកុមារបានសម្រាកបន្ធូរបន្ថយ អារម្មណ៍រំភើប/រំជួលចិត្ត (កម្រិតខ្ពស់) របស់ពួកគេ និងត្រៀមពួកគេសម្រាប់ព្រឹត្តិការណ៍/សកម្មភាពបន្ទាប់។ កុមារធ្វើអន្តរកម្មជាមួយនឹងមិត្តភក្តិរបស់ពួកគេ នៅក្នុងពេលជាក់លាក់។ អ្នកថែទាំគួរយកចិត្តទុកដាក់ ដើម្បីធានាយ៉ាងណាមិនឱ្យកុមារណាម្នាក់ត្រូវបានគេបដិសេធមិនឱ្យចូលរួមនៅក្នុងក្រុម។

កុមារចូលចិត្តលេងល្បែងដែលឆ្លើយតបទៅនឹងតម្រូវការដែលពាក់ព័ន្ធនឹងការប្រើប្រាស់ជំនាញគិត និងតម្រូវការផ្នែកអារម្មណ៍របស់ពួកគេដោយខ្លួនឯង។ ក្នុងពេលលេងដោយសេរី កុមារអាចសាកល្បងល្បែងដែលស្រួលពេក និងពិបាកពេក។ ការលេងដោយសេរី ផ្តល់ឱកាសឱ្យកុមារបង្ហាញពីការអភិវឌ្ឍរបស់ពួកគេ ព្រោះថាវាអនុញ្ញាតឱ្យកុមារខិតខំបង្កើនជំនាញរបស់ពួកគេ។ ពេលលេងដោយសេរី គួរអនុញ្ញាតឱ្យកុមារលេងក៏បាន ឬមិនលេងក៏បាន ជ្រើសរើសអ្វីដែលពួកគេចង់លេង ជ្រើសរើសរបៀបលេង និងសម្រេចចិត្តថាតើពួកគេគួរលេងតែឯង ឬគួរលេងជាមួយអ្នកដទៃ។ អ្នកថែទាំចាំបាច់ត្រូវតាមមើលកុមារ និងផ្តល់ការណែនាំបន្ថែម នៅពេលដែលពួកគេកំពុងលេង។

### *៣.២.៨ កាលវិភាគគេងទៀងទាត់សម្រាប់ទារក/កុមារតូច*

ទារក/កុមារតូច ម្នាក់ៗត្រូវមានរយៈពេលគេង ដោយមានអ្នកថែទាំចាំមើល ដើម្បីឱ្យទារកអាចរក្សាពេលគេង និងពេលភ្ញាក់ឱ្យបានទៀងទាត់។ នៅក្នុងពេលគេង ត្រូវបែងចែកកុមារទៅតាមក្រុមអាយុ និងមានការតាមមើលពីអ្នកថែទាំ។ កុមារអាចនៅលើពូក ខណៈពេលដែលទារកអាចគេងនៅក្នុងអង្រឹង ដោយមានរបងការពារជុំវិញពួកគេ។ កាលវិភាគប្រចាំថ្ងៃ ត្រូវមានភាពបត់បែន ដើម្បីសម្របទៅតាមបរិមាណនៃការគេង ដែលកុមារម្នាក់ៗត្រូវការ។

### *៣.២.៩. ពេលគេង*

គួររៀបចំពេលគេងដូចខាងក្រោម៖

- អ្នកថែទាំអាចឱ្យកុមារគេង ឬសម្រាកប្រហែលជា ៥ ម៉ោង។ ចំនួនម៉ោងគេង ឬម៉ោងសម្រាកគួរអាស្រ័យទៅតាមតម្រូវការនៃរាងកាយ និងអាយុរបស់កុមារ

- ពេលគេងកុមារត្រូវការឱ្យស្លៀកពាក់សម្លៀកបំពាក់ដែលផ្តល់នូវផាសុកភាព អ្នកថែទាំគួរជួយកុមារប្តូរសម្លៀកបំពាក់មុន និងក្រោយពេលគេង ប្រសិនបើចាំបាច់
- គួរមានការរៀបចំសម្ភារគេងឱ្យមានសណ្តាប់ធ្នាប់ មុន និងក្រោយពេលគេង
- គួររៀបចំផ្លូវដើរសម្រាប់អ្នកថែទាំ នៅចន្លោះគ្រែ ឬពូក ពេលកុមារកំពុងគេង
- អ្នកថែទាំ និងកុមារត្រូវមានចន្លោះសម្រាប់ដើរ ដោយមិនអាចជាន់ ឬដើររំលងកុមារផ្សេងទៀតនោះឡើយ
- មិនគួរបិទអំពូលភ្លើងនៅក្នុងបន្ទប់ឡើយ ប៉ុន្តែជំនួសឱ្យវិញគួរបន្ថយកម្រិតភ្លឺ ដើម្បីឱ្យអ្នកថែទាំអាចមើលឃើញកុមារក្នុងអំឡុងពេលគេង
- ប្រសិនបើកុមារមួយចំនួនភ្ញាក់ អ្នកថែទាំគួររកសកម្មភាពផ្សេងៗឱ្យពួកគេធ្វើ ដែលអាចរក្សាបាននូវភាពស្ងប់ស្ងាត់រហូតដល់ពេលចប់ពេលគេងសម្រាប់កុមារផ្សេងទៀត
- នៅពេលដែលកុមារណាម្នាក់ក្រោកពីគេង អ្នកថែទាំត្រូវយកគាត់ចេញពីអង្រឹង និងឱ្យគាត់លេងដោយសេរី ឬធ្វើសកម្មភាពដែលបានគ្រោងទុក
- គួរកំណត់សីតុណ្ហភាពនៅក្នុងបន្ទប់ចន្លោះពី ២៣ ទៅ ២៦ អង្សាសេ ហើយសីតុណ្ហភាពម៉ាស៊ីនត្រជាក់គួរឡើង ឬចុះទៅតាមសីតុណ្ហភាពខាងក្រៅ

អ្នកថែទាំត្រូវធានាថាអង្រឹង និងគ្រែមានសុវត្ថិភាពសម្រាប់កុមារ។ កុមារតូចគួរគេងនៅលើផ្ទៃរាបស្មើ ដែលរឹងមាំ ចៀសវាងការប្រើប្រាស់សម្ភារទន់ៗ ដូចជា ភួយ កម្រាលក្រាលក្នុងផ្ទៃគ្រែ កន្សែងរុំ តុក្កតាសត្វញាត់សំឡី ខ្នើយ និងវត្ថុ ដូចជា ខ្នើយផ្សេងទៀត ភួយបត់ និងកម្រាលគេងសម្រាប់ទារក។ សម្ភារទាំងនេះអាចរាំខានដល់ចរន្តខ្យល់នៅជុំវិញមុខរបស់កុមារតូច និងអាចនាំឱ្យថប់ដង្ហើមបាន។

> សូមកុំឱ្យកុមារតូចគេងគ្រែជាមួយគ្នា ព្រោះបទពិសោធន៍មួយចំនួនបង្ហាញថា វាអាចនាំឱ្យមានការសង្កត់ និងថប់ដង្ហើមដោយចៃដន្យ។ ទុកឱ្យកុមារគេង បើទោះជាកុមារផ្សេងទៀតដឹងខ្លួនក៏ដោយ ព្រោះថាកុមារម្នាក់ៗមានចង្វាក់នៃការគេងរៀងៗខ្លួន ហើយកុមារមួយចំនួនត្រូវការការគេងច្រើនជាងកុមារផ្សេងទៀត។ទ

### *៣.២.១០. ពេលសម្រាប់លេងក្រោយអាហារថ្ងៃត្រង់*

ក្រោយពេលគេង កុមារអាចបន្តលេងទៀត។ ទោះជាយ៉ាងណាក៏ដោយ សកម្មភាពរបស់កុមារអាចមានតិចជាង និងអាចងាយស្រួលជាងសកម្មភាពនៅពេលព្រឹកដោយសារតែកុមារអាចនឿយហត់នឹងការលេងច្រើននៅពេលព្រឹក។ អ្នកមើលថែត្រូវលើកទឹកចិត្តឱ្យកុមារលេងដោយខ្លួនឯង ដើម្បីឱ្យពួកគេអភិវឌ្ឍបំណិនរបស់ពួកគេបន្ថែមទៀតដោយខ្លួនឯង។

### *៣.២.១១. ការមកដល់របស់ម្តាយ ឪពុក*

អ្នកថែទាំគួរត្រៀមយោបល់ និងព័ត៌មានមួយចំនួន ដើម្បីផ្តល់ជូនទៅម្តាយ ឪពុក។ ចំណុចសង្កេតឃើញ

ទាំងនេះគួរសរសេរទុកសម្រាប់គ្រប់សកម្មភាពទាំងអស់នៅក្នុងមួយថ្ងៃៗ ដើម្បីតាមដានមើលព័ត៌មានសំខាន់ៗ និងការរីកចម្រើនរបស់កុមារ (សូមមើលឧបសម្ព័ន្ធទី ៨)។ យោបល់នានាគួរធ្វើរួមមាន៖

- ពេលដែលកុមារគេង
- ពេល និងបរិមាណអាហារដែលកុមារញ៉ាំ
- ពេលប្តូរខោទឹកនោម
- អារម្មណ៍ជាទូទៅរបស់កុមារនៅក្នុងមួយថ្ងៃៗ
- សង្ខេបអំពីសកម្មភាពដែលកុមារបានចូលរួម។

ដោយសារទារកមិនអាចប្រាប់ពីព័ត៌មានសំខាន់ៗដល់ម្តាយ ឪពុករបស់ពួកគេបាន ជាការសំខាន់ណាស់ដែលអ្នកថែទាំត្រូវប្រាប់ពីព័ត៌មានទាំងនេះ។ នៅក្នុងទារកដ្ឋាន អាចមានអ្នកថែទាំច្រើននាក់សម្រាប់ទារកម្នាក់ ឬអាចមានការប្តូរវេនគ្នា។ របាយការណ៍គួរផ្តល់លទ្ធភាពឱ្យម្តាយ ឪពុកនោះដឹងថាតើកូនរបស់ពួកគេចំណាយពេលធ្វើអ្វីខ្លះនៅក្នុងរយៈពេលមួយថ្ងៃនេះ ដើម្បីឱ្យម្តាយឪពុកអាចបំពេញបន្ថែមលើសកម្មភាពផ្សេងៗ ឬអាហារ សម្រាប់ទារកនៅផ្ទះ។ វាជាវិធីដ៏ល្អមួយដើម្បីកសាងការប្រាស្រ័យទាក់ទង និងទំនាក់ទំនងឱ្យបានល្អជាមួយម្តាយឪពុក ព្រមទាំងបង្កើនការការពារ និងសុខុមាលភាពរបស់ទារកផង។

# ផ្នែកទី៤ ៖ សមាសភាគសំខាន់ៗនៃការអភិវឌ្ឍកុមារ ដែលត្រូវអនុវត្ត នៅក្នុងទារកដ្ឋាន

## *៤.១. ការអភិវឌ្ឍកាយសម្បទា*

ការឆ្លើយតបចំពោះតម្រូវការនៃការលូតលាស់ផ្នែកកាយសម្បទារបស់កុមារ មានសារសំខាន់យ៉ាងខ្លាំង សម្រាប់សុខុមាលភាពកាយសម្បទារយៈពេលវែងរបស់ពួកគេ។ តម្រូវការទាំងនោះរួមមាន ទីជម្រក (កន្លែងដែលមានសុវត្ថិភាព) សុខភាព អាហារ និងសម្លៀកបំពាក់ជាដើម។

### *៤.១.១. ការអភិវឌ្ឍបំណិនចលនា*

ការអភិវឌ្ឍបំណិនចលនារួមមាន សកម្មភាពនានាដែលភ្ជាប់ចលនា ឬកាយវិការរបស់កុមារ។ វាជួយឱ្យកុមារមានការរីកចម្រើនទាំងផ្លូវកាយ និងផ្លូវចិត្ត។ ខាងក្រោមនេះគឺជាការអភិវឌ្ឍបំណិនចលនាពីរប្រភេទ៖

- **ការអភិវឌ្ឍបំណិនចលនាតូច**

បំណិនចលនាតូចរួមមាន បំណិនប្រើប្រាស់ម្រាមដៃ និងដៃ ដូចជា ការសរសេរ កាត់ បើកប្រអប់អាហារ ចងខ្សែស្បែកជើង។ល។ ការអភិវឌ្ឍបំណិនទាំងនេះ រួមទាំងការគ្រប់គ្រងអវយវៈសំខាន់ៗ និងកម្លាំងស្មា គឺអាស្រ័យទៅតាមអាយុ និងសមត្ថភាពរាងកាយរបស់កុមារ។ (សូមមើលឧបសម្ព័ន្ធទី១៖ ជំហាននៃការអភិវឌ្ឍទារក និងឧបសម្ព័ន្ធទី ២៖ ជំហាននៃការអភិវឌ្ឍកុមារតូច)។

- **ការអភិវឌ្ឍបំណិនចលនាធំ**

បំណិនចលនាធំតម្រូវឱ្យធ្វើចលនាមួយតួខ្លួន និងមានការប្រើប្រាស់សាច់ដុំធំ (ដែលជួយរក្សាលំនឹង) របស់រាងកាយ ដើម្បីធ្វើសកម្មភាពប្រចាំថ្ងៃ ដូចជា ឈរ ដើរ រត់ និងអង្គុយត្រង់ខ្លួនជាដើម។ បំណិននេះក៏រួមមានបំណិនសម្របសម្រួលរវាងភ្នែក និងដៃ ដូចជា បំណិនប្រើបាល់ (គប់ ចាប់ និងទាត់បាល់) ជាដើម។

### *៤.១.២. ការអភិវឌ្ឍផ្លូវចិត្ត និងសង្គម*

ការតាមដានការអភិវឌ្ឍរបស់កុមារមានសារសំខាន់យ៉ាងខ្លាំង ប៉ុន្តែត្រូវបានគេទទួលស្គាល់ថាជារឿងដែលពិបាក។ កុមារម្នាក់អភិវឌ្ឍទៅតាមល្បឿនរបស់ពួកគេ។ អ្នកថែទាំអាចវាយតម្លៃ និងតាមដានដំណាក់កាលសំខាន់ៗនៃការអភិវឌ្ឍរបស់កុមារម្នាក់ៗ ដែលចុះឈ្មោះមករៀននៅក្នុងទារកដ្ឋាន (សូមមើលឧបសម្ព័ន្ធទី១ និងទី ២)។ កុមាររៀនបានល្អបំផុតពីមនុស្សពេញវ័យ។ ការថែទាំកុមារឱ្យបានល្អ នៅឆ្នាំដំបូងៗគឺជារឿងដែលចាំបាច់ដើម្បីកសាងមូលដ្ឋានគ្រឹះឱ្យបានរឹងមាំសម្រាប់ការអភិវឌ្ឍសង្គម និងផ្លូវចិត្ត។ ការសិក្សានានាបង្ហាញថា កុមារតូចមានការលំបាកក្នុងការកសាងទំនាក់ទំនង ប្រកបដោយការជឿទុកចិត្តគ្នា នៅពេលដែលមានមនុស្សពេញវ័យច្រើនពេកទំនាក់ទំនងជាមួយនឹងពួកគេ។ សុខភាព និងសុខុមាលភាពរបស់កុមារ អាចទទួលឥទ្ធិពលជាវិជ្ជមាន ឬកាន់តែមានភាពប្រសើរ នៅពេលដែលពួកគេទំនាក់ទំនងជាមួយនឹងអ្នកថែទាំដដែលៗជាទៀងទាត់។ កុមារមិនមែនសុទ្ធតែអាចប្រាប់ពីតម្រូវការរបស់ពួកគេទៅកាន់មនុស្សពេញវ័យនោះឡើយ។ អ្នកថែទាំត្រូវយល់ និងយកចិត្តទុកដាក់ចំពោះកាយវិការ និងឥរិយាបថដែលបញ្ជាក់ពីបំណងរបស់ពួកគេ។ ត្រូវមានការយកចិត្តទុកដាក់ជាពិសេសលើចំណុចដូច

ខាងក្រោម៖

- ការថែទាំត្រូវផ្តល់ដោយអ្នកថែទាំដដែលជាទៀងទាត់នៅក្នុងករណីដែលអាចធ្វើទៅបាន
- ហាមឃាត់មិនឱ្យមានអំពើហិង្សាគ្រប់ប្រភេទ (អំពើហិង្សាផ្លូវកាយ សង្គម សព្វេតនា)
- ធានាថាកុមារមានពេលផ្ទាល់ខ្លួនប្រកបដោយគុណភាព ជាមួយនឹងអ្នកថែទាំ
- លើកទឹកចិត្តឱ្យមានទំនាក់ទំនងក្នុងសង្គមរវាងកុមារ និងកុមារ។

> កុមាររៀនបានល្អបំផុតពីមនុស្សពេញវ័យ ដែលស្រលាញ់ និងគោរពពួកគេ ហើយដែលពួកគេបានកសាងទំនាក់ទំនងប្រកបដោយការជឿទុកចិត្តជាមួយគ្នា។ ការយកចិត្តទុកដាក់ដែលកុមារទទួលបាននៅឆ្នាំដំបូងៗនៃជីវិតរបស់ពួកគេ មានសារសំខាន់យ៉ាងខ្លាំងសម្រាប់ការអភិវឌ្ឍស្មារតី និងសង្គមរបស់កុមារ។ ការសិក្សាលើឥរិយាបថរបស់ទារកបង្ហាញថា ទារកមានការលំបាកនៅក្នុងការកសាងទំនាក់ទំនងប្រកបដោយការជឿទុកចិត្តនៅក្នុងស្ថានភាពដែលមានមនុស្សពេញវ័យជាច្រើននាក់ទំនាក់ទំនងជាមួយនឹងពួកគេ។ សុខភាព និងសុខុមាលភាព របស់កុមារ អាចរងឥទ្ធិពលជាវិជ្ជមាន តាមរយៈការមានអ្នកថែទាំដដែលឱ្យបានទៀងទាត់។

### *៤.១.៣. ការអភិវឌ្ឍបញ្ញាញាណ ភាសា និងបំណិនគិត*

បទពិសោធន៍នៅក្នុងឆ្នាំដំបូងៗ និងមជ្ឈដ្ឋានជុំវិញ ជាកត្តាសម្រេចការអភិវឌ្ឍរបស់កុមារ។ បទពិសោធន៍ជាវិជ្ជមាន និងបរិយាកាសដែលភ្ញោចការអភិវឌ្ឍរបស់កុមារ ជួយឱ្យកុមារអភិវឌ្ឍមុខងារបញ្ញាញាណរបស់ពួកគេបានយ៉ាងល្អ។ រយៈពេល ៣ ឆ្នាំដំបូងនៃជីវិត មានសារសំខាន់យ៉ាងខ្លាំងសម្រាប់ការអភិវឌ្ឍរបស់កុមារ។ ជាការសំខាន់ណាស់ដែលទារកដ្ឋាន និងអ្នកថែទាំលើកទឹកចិត្តឱ្យកុមារស្វែងយល់ និងរិះរកអ្វីដោយខ្លួនឯង។ ទារកដ្ឋានគួរ៖

- អនុញ្ញាតឱ្យកុមារបានសម្រាកក្រោយពេលធ្វើសកម្មភាព ដើម្បីឱ្យពួកគេចាំអ្វីដែលពួកគេបានរៀន
- រៀបចំឱ្យមានសកម្មភាពចម្រុះច្រើនប្រភេទដើម្បីជំរុញឱ្យមានការអភិវឌ្ឍកុមារបានគ្រប់ជ្រុងជ្រោយ
- ស្វែងយល់ពីការអភិវឌ្ឍបញ្ញាញាណរបស់កុមារ។

## *៤.២ អាហារូបត្ថម្ភ និងសុខភាពរបស់កុមារ*

សុខភាព និងអាហារូបត្ថម្ភដែលល្អ គឺជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍរបស់កុមារ។ កត្តាដែលរួមចំណែកធ្វើឱ្យកុមារមានសុខភាពល្អ រួមមាន៖

- **គេង**

គេងគឺជាពេលវេលាដ៏សំខាន់ និងមានតម្លៃសម្រាប់កុមារ។ ការគេងជួយឱ្យកុមារបានសម្រាក និងមានសារសំខាន់ដើម្បីឱ្យពួកគេអាចចងចាំព័ត៌មាន និងចំណេះដឹងដែលពួកគេបានទទួលនៅក្នុងរយៈពេលមួយថ្ងៃ ដែលជាការផ្តល់ពេលវេលាឱ្យខួរក្បាលមានភាពចាស់ទុំ។ ដំណើរការនេះអាស្រ័យលើគុណភាពនៃការគេង ដែលទទួលរងឥទ្ធិពលពីគុណភាពនៃមជ្ឈដ្ឋានជុំវិញ។ រយៈពេលប៉ុន្មានខែដំបូងនៅក្នុងជីវិត មានសារសំខាន់សម្រាប់ការអភិវឌ្ឍសង្វាក់ប្រចាំថ្ងៃ (ពេលភ្ញាក់/ពេលគេង)។ ការគេងឱ្យបានគ្រប់គ្រាន់គិតជាចំនួនម៉ោង និងគុណភាពនៃការគេង មាន

សារសំខាន់យ៉ាងខ្លាំងសម្រាប់ការអភិវឌ្ឍរបស់កុមារ និងជាពិសេសសម្រាប់ការគ្រប់គ្រងខ្លួនឯង ការអភិវឌ្ឍសុខភាព ការចងចាំ និងការបំពេញមុខងារបញ្ញាញាណបានយ៉ាងល្អ។

- **អនាម័យ**

អនាម័យគឺជាសមាសភាគមួយដ៏សំខាន់ ដើម្បីឱ្យកុមារបន្តមានសុខភាពមាំមួន។ របៀបរក្សាអនាម័យ និងសម្អាតទីកន្លែងផ្សេងនៅក្នុងទារកដ្ឋានមានសារសំខាន់យ៉ាងខ្លាំង។ ត្រូវមានការសម្អាតទារកដ្ឋានជាប្រចាំដើម្បីកាត់បន្ថយឱ្យបានជាអតិបរមា និងវត្តមានមីក្រុប មេរោគ និងបាក់តេរី ហើយត្រូវមានការតាមដានមើលការសម្អាតជាទៀងទាត់។ រាល់បរិក្ខារនៅក្នុងទារកដ្ឋាន ព្រមទាំងសម្ភារ និងប្រដាប់លេងទាំងអស់ ត្រូវតែថែទាំឱ្យបានស្អាតល្អ និងត្រូវសម្អាតជាទៀងទាត់។ អ្នកថែទាំ និងកុមារ ត្រូវលាងសម្អាតដៃជាទៀងទាត់ ដើម្បីការពារជំងឺ។ ទារកដ្ឋានត្រូវការការសម្អាតបន្ថែមទៀត នៅក្នុងអំឡុងពេលនៃការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងផ្សេងៗ។

- **អាហារូបត្ថម្ភ**

នៅកម្ពុជាបញ្ហាអាហារូបត្ថម្ភរបស់កុមារនៅតែជាបញ្ហាប្រឈមធំមួយ។ មានការប៉ាន់ប្រមាណថា កុមារអាយុក្រោម ៥ ឆ្នាំ ប្រមាណ ៣២% មានបញ្ហាក្រិន (កម្ពស់ទាបបើធៀបនឹងអាយុ) ២៤% ខ្វះទម្ងន់ (ទម្ងន់ស្រាល បើធៀបនឹងអាយុ) និង ១០% ស្គមស្គាំង (ទម្ងន់ស្រាលធៀបនឹងកម្ពស់)។[8] បញ្ហាអាហារូបត្ថម្ភ ជាពិសេសបញ្ហាកង្វះអាហារូបត្ថម្ភ បង្កមហន្តរាយធ្ងន់ធ្ងរដល់ការអភិវឌ្ឍកាយសម្បទា និងអាចបង្កផលប៉ះពាល់ធ្ងន់ធ្ងរដល់ការអភិវឌ្ឍខួរក្បាល និងមុខងារបញ្ញាញាណ។ ដូច្នេះកុមារត្រូវការអាហារចម្រុះគ្រប់គ្រាន់ មានគុណភាព និងមានជីវជាតិចិញ្ចឹម ដើម្បីទ្រទ្រង់រាងកាយរបស់ពួកគេជាចាំបាច់។

- **ការបំបៅកូនដោយទឹកដោះម្តាយ**

ការបំបៅកូនដោយទឹកដោះម្តាយ គឺជាលក្ខខណ្ឌសំខាន់មួយក្នុងចំណោមលក្ខខណ្ឌសំខាន់ៗដែលម្តាយ ឪពុក និងថ្នាក់ដឹកនាំក្រសួងកិច្ចការនារី ត្រូវពិចារណាដូចជា ត្រូវផ្តល់ពេលវេលាឱ្យបានគ្រប់គ្រាន់ និងមានពេលគ្រប់គ្រាន់ក្នុងថ្ងៃធ្វើការស្របតាមគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាល និងអនុសាសន៍របស់អង្គការសុខភាពពិភពលោក។ ក្រសួងសុខាភិបាល និងអង្គការសុខភាពពិភពលោកលើកទឹកចិត្តម្តាយឱ្យបំបៅកូនរហូតដល់កូនមានអាយុ ២ ឆ្នាំ និងបំបៅកូនដោយទឹកដោះម្តាយតែមួយគត់ រហូតដល់កូនអាយុ ៦ ខែ។ ការបំបៅកូនដោយទឹកដោះម្តាយ គឺជាប្រភពអាហារូបត្ថម្ភដ៏ល្អបំផុតសម្រាប់ទារក ព្រោះថាវាផ្តល់នូវសារជាតិប្រឆាំងមេរោគ ពពួកខ្លាញ់សំខាន់ៗ និងសារជាតិចិញ្ចឹម ដែលមានសារសំខាន់សម្រាប់ការអភិវឌ្ឍរបស់កុមារ។ ការបំបៅកូនដោយទឹកដោះម្តាយក៏អាចកាត់បន្ថយហានិភ័យនៃការឆ្លងជំងឺ និងបញ្ហាជាត់ជ្រុលផងដែរ។ ទារកដ្ឋានរបស់ក្រសួងកិច្ចការនារីលើកទឹកចិត្តឱ្យម្តាយ ឪពុកបំបៅទារកអាយុក្រោម ៦ខែ ដោយទឹកដោះម្តាយ។ ការបំបៅកូនដោយទឹកដោះម្តាយ គឺរៀបចំនៅក្នុងបន្ទប់ដាច់ដោយឡែក។ ប្រសិនបើមានកន្លែងនៅក្នុងទារកដ្ឋានរបស់ក្រសួងកិច្ចការនារី ឬការបំបៅកូនអាចធ្វើឡើងនៅក្នុងបន្ទប់ធំតែម្តង ដរាបណាមានផ្ទាំងខណ្ឌចែកដើម្បីផ្តល់នូវផាសុខភាពសម្រាប់ទារក និងម្តាយ។ ចាំបាច់ត្រូវមាន កៅអីខ្នើយ គ្រែ ឬពូកសម្រាប់ការបំបៅកូន។ ខាងក្រោមនេះគឺអនុសាសន៍ដែលគួរអនុវត្តតាម៖

- បំបៅកូនដោយទឹកដោះម្តាយឱ្យបានឆាប់បំផុត ក្រោយពេលសម្រាល ក្នុងអំឡុងម៉ោងដំបូងក្រោយសម្រាល
- បំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់សម្រាប់រយៈពេល ៦ ខែដំបូង (១៨០ ថ្ងៃ)

[8] ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ២០១៤។

- ចាប់ផ្តើមផ្តល់អាហារបន្តិចម្តងៗបន្ថែមលើទឹកដោះម្តាយសម្រាប់ទារកដែលមានអាយុលើសពី ៦ខែ។

▸ **អាហារបន្ថែម និងអាហារចម្រុះ**

អាហារបន្ថែមដែលសមស្រប គឺចាំបាច់សម្រាប់កុមារអាយុពី ៦ខែ ដល់ ២៣ ខែ ដើម្បីធានាការរស់រាន និងការអភិវឌ្ឍកាយសម្បទា និងបញ្ញាស្មារតីរបស់ពួកគេឱ្យបានល្អបំផុត។ អាហារចម្រុះ សំដៅលើអាហារដែលមានសារជាតិចិញ្ចឹម ឬសារជាតិចិញ្ចឹមជីវសាស្ត្រសម្រាប់កុមារអាយុចាប់ពី ៦ខែឡើងទៅ។ ជាការសំខាន់ណាស់ដែលកុមារត្រូវទទួលបានគ្រប់សារជាតិចិញ្ចឹមទាំងអស់ ក៏ដូចជា ប្រូតេអ៊ីន និងកាឡូរី ដែលចាំបាច់សម្រាប់ការអភិវឌ្ឍបញ្ញាស្មារតី និងកាយសម្បទារបស់ពួកគេ។ ក្រោយពេលទទួលបានការបំបៅដោះម្តាយតែមួយមុខគត់ នៅពេលដែលទារកអាយុបាន ៦ ខែ ពួកគេទទួលបានអាហារបន្ថែមចម្រុះ។ ទារកដែលមានអាយុចាប់ពី ៦ ខែ ឡើងទៅ គួរទទួលបានអាហារបន្ថែម ដើម្បីបំពេញតម្រូវការសារជាតិចិញ្ចឹម ដែលបន្តមានការកើនឡើងសម្រាប់ពួកគេ។

តារាងទី១ សង្ខេបការណែនាំអំពីរបៀបផ្តល់អាហារបន្ថែមឱ្យបានសមស្របដល់កុមារ ដែលមានអាយុចាប់ពី ៦ខែ ដល់ ២៤ ខែ គួបផ្សំនឹងការបំបៅដោយទឹកដោះម្តាយ៖

**តារាងទី១៖ ការណែនាំស្តីពីអាហារបន្ថែម**

| អាយុ | ប្រភេទអាហារ | ឯកតា/ដង | បរិមាណអាហារ/សម្រាប់ពេលផ្តល់អាហារម្តង |
|---|---|---|---|
| ៦ ខែ | ចាប់ផ្តើមជាមួយនឹង៖<br>- បបរដែលសំបូរដោយសារជាតិចិញ្ចឹម<br>- អាហារដែលកិនម៉ត់ល្អ ដូចជា ចេក ដំឡូង ល្ពៅស្ងោរ ដែលយកមកកិន។ល។ | ចាប់ផ្តើមពីរដងក្នុងមួយថ្ងៃ អមជាមួយនឹងការបំបៅដោយទឹកដោះម្តាយជាទៀងទាត់ យ៉ាងហោចណាស់ ៨ ដង ក្នុងមួយថ្ងៃ | ចាប់ផ្តើមពី ២ ទៅ ៣ ស្លាបព្រា (ស្លាព្រាបាយ) សម្រាប់អាហារមួយពេល |
| ៧-៨ ខែ | - បបរដែលសំបូរដោយសារជាតិចិញ្ចឹម<br>- អាហារដែលកិនម៉ត់ល្អ | បង្កើនដល់បីដងក្នុងមួយថ្ងៃ ជាមួយនឹងការបំបៅដោយទឹកដោះម្តាយជាទៀងទាត់ យ៉ាងហោចណាស់ ៨ ដង ក្នុងមួយថ្ងៃ | បង្កើនបន្តិចម្តងៗរហូតដល់កន្លះចានក្នុងមួយពេល |
| ៩-១១ ខែ | - បបរដែលសំបូរដោយសារជាតិចិញ្ចឹម<br>- អាហារដែលកិនម៉ត់ល្អ, អាហាររឹងដែលម៉ត់ល្អ ចិញ្ច្រាំ ឬកាប់ជាដុំៗ ដែលទារកអាចកាន់ញ៉ាំបាន | ៣ ដងក្នុងមួយថ្ងៃ និងការផ្តល់អាហារបន្ថែមម្តងនៅចន្លោះពេលបៅដោះម្តាយ យ៉ាងហោចណាស់ ៦ ដង ក្នុងមួយថ្ងៃ | បង្កើនបន្តិចម្តងៗរហូតដល់ ២/៣នៃចានក្នុងមួយពេល |

| | | | |
|---|---|---|---|
| ១២-២៤ ខែ | - អាហារសម្រាប់គ្រួសាររួម កិនម៉ត់<br>- ប្រសិនបើចាំបាច់ សូមបន្ថែមបបរ | អាហារ ៣ ពេល និងអាហារបន្ថែម ២ ដង នៅចន្លោះការបៅដោះម្តាយ ៣ដង ក្នុងមួយថ្ងៃ | ១ ចានពេញក្នុងមួយពេល |

# ផ្នែកទី៥ ៖ អ្នកគ្រប់គ្រងបុគ្គលិក និងរដ្ឋបាល

## *៥.១. អ្នកគ្រប់គ្រងទារកដ្ឋាន*

អ្នកគ្រប់គ្រងទារកដ្ឋានរបស់ក្រសួងកិច្ចការនារី ទទួលខុសត្រូវក្នុងការធានាយ៉ាងណាឱ្យទារកដ្ឋានដំណើរការទៅតាមគោលការណ៍ណែនាំ និងស្របតាមបទដ្ឋានអប្បបរមាស្តីពីការថែទាំកុមារតូច។ អ្នកគ្រប់គ្រងទារកដ្ឋានទទួលខុសត្រូវលើការគ្រប់គ្រងសេវាក្នុងទារកដ្ឋានប្រចាំថ្ងៃ និងធានាយ៉ាងណាឱ្យដំណើរការទារកដ្ឋាន អនុវត្តមុខងារដោយឆ្លើយតបទៅនឹងគោលដៅរបស់ទារកដ្ឋាន គោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលកំណត់ដោយក្រសួងស្ថាប័ន ដែលទទួលបន្ទុកក្នុងការលើកកម្ពស់កិច្ចការពារ និងការអភិវឌ្ឍកុមារ ព្រមទាំងជួយឱ្យម្តាយ ឪពុកមានឱកាសបំពេញការងារបានកាន់តែប្រសើរ។ អ្នកគ្រប់គ្រងទារកដ្ឋានធ្វើការនៅក្នុងនាយកដ្ឋានស្ត្រី និងការអប់រំ នៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍សង្គមរបស់ក្រសួងកិច្ចការនារី និងផ្តោតការយកចិត្តទុកដាក់ដាក់លាក់លើ សេវាដែលត្រូវអនុវត្តនៅក្នុងទារកដ្ឋាន។

**ការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រងទារកដ្ឋាន៖**

ក) សហការជាមួយម្តាយ ឪពុក នាយកដ្ឋានពាក់ព័ន្ធក្រោមចំណុះក្រសួងកិច្ចការនារី ក្រសួង និងស្ថាប័នពាក់ព័ន្ធ ដើម្បីកៀរគរធនធាន និងជំនួយបច្ចេកទេសដែលចាំបាច់សម្រាប់ដំណើរការទារកដ្ឋានឱ្យបានរលូន និងប្រកបដោយប្រសិទ្ធភាព។

ខ) ជ្រើសរើសអ្នកថែទាំដែលមានសមត្ថភាព និងបុគ្គលិកដទៃទៀតរបស់ទារកដ្ឋាន នៅពេលដែលចាំបាច់។ ការជ្រើសរើសនឹងអាចស្នើសុំឱ្យក្រសួងជ្រើសរើសតាមរយៈនាយកដ្ឋានស្ត្រី និងការអប់រំ។

គ) គ្រប់គ្រងអ្នកថែទាំក្នុងការបំពេញភារកិច្ចប្រចាំថ្ងៃរបស់ពួកគេ។

ឃ) រៀបចំវគ្គតម្រង់ទិស និង/ឬវគ្គបណ្តុះបណ្តាលសម្រាប់អ្នកថែទាំ ដូចជា អំពីបទបញ្ជាផ្ទៃក្នុង តួនាទី និងភារកិច្ច និងការណែនាំអំពីការថែទាំកុមារជាដើម។

ង) តាមដាន និងវាយតម្លៃអ្នកថែទាំ និងបុគ្គលិកដទៃទៀតរបស់ទារកដ្ឋាន ដើម្បីធានាឱ្យមានការគោរពតាមលិខិតបទបញ្ជាផ្ទៃក្នុង (ដែលទទួលបានការឯកភាពពីថ្នាក់ដឹកនាំទទួលបន្ទុក) និងគោលការណ៍ណែនាំស្តីពីដំណើរការទារកដ្ឋាននេះ។

ច) រៀបចំកិច្ចប្រជុំ និងវគ្គឆ្លុះបញ្ចាំងជាមួយនឹងអ្នកថែទាំ និងបុគ្គលិក។

ឆ) គ្រប់គ្រងបុគ្គលិកដែលមកធ្វើការជំនួសក្នុងករណីដែលអ្នកថែទាំអវត្តមាន។

ជ) ចាត់វិធានការសមស្រប ក្នុងករណីដែលមានជម្លោះ ឬមានស្ថានភាពបន្ទាន់នៅក្នុងទារកដ្ឋាន។ វិធានការនានាដែលអនុវត្ត ត្រូវមានការពិគ្រោះយោបល់ និងឯកភាពពីថ្នាក់ដឹកនាំទទួលបន្ទុកគ្រប់កម្រិត។

ឈ) ធានាឱ្យមានការផ្តល់ព័ត៌មានដែលចាំបាច់ទាំងអស់ ដល់ម្តាយ ឪពុក និងថ្នាក់ដឹកនាំរបស់ក្រសួងកិច្ចការនារី។

ញ) ធ្វើបច្ចុប្បន្នភាព និងផ្ទៀងផ្ទាត់កម្មវិធី និងសម្ភារគរុកោសល្យ/អប់រំ ដែលប្រើប្រាស់នៅក្នុងទារកដ្ឋាននេះ ដោយមានការពិគ្រោះយោបល់ជាមួយអ្នកថែទាំ អ្នកជំនាញ និងថ្នាក់ដឹកនាំរបស់ក្រសួងកិច្ចការនារី។

ឋ) បំពេញការងាររដ្ឋបាល ការប្រាស្រ័យទាក់ទង ការគ្រប់គ្រង និងការរៀបចំរបាយការណ៍អំពីការងារអនុវត្ត

ការងាររបស់ទារកដ្ឋាន រួមទាំងការផ្ទៀងផ្ទាត់ នីតិវិធីប្រតិបត្តិការ ការចុះឈ្មោះកុមារ និងការសហការរបស់ម្តាយ ឪពុក ការរៀបចំផែនការប្រតិបត្តិ និងផែនការថវិកា។

ឱ) ផ្តល់ការគាំទ្រដល់បុគ្គលិករបស់ទារកដ្ឋាន និងអ្នកថែទាំទៅតាមការចាំបាច់ និងក្នុងករណីបន្ទាន់។

**លក្ខណៈសម្បត្តិ និងលក្ខខណ្ឌតម្រូវ**

**អ្នកគ្រប់គ្រងទារកដ្ឋានគួរបំពេញទៅតាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖**

ក) មានអាយុយ៉ាងហោចណាស់ ២៥ ឆ្នាំ

ខ) មានសញ្ញាបត្របរិញ្ញាបត្រជំនាញពាក់ព័ន្ធ ឬជំនាញគរុកោសល្យ គឺជាគុណសម្បត្តិ

គ) មានបទពិសោធន៍ខាងគ្រប់គ្រងទារកដ្ឋាន ការងារដឹកនាំ និងគ្រប់គ្រង គណនេយ្យ ការបណ្តុះបណ្តាល ការធ្វើផែនការសកម្មភាព និងផែនការថវិកា ការតាមដាន និងវាយតម្លៃ និងការគ្រប់គ្រងបុគ្គលិក

ឃ) ជំនាញអន្តរបុគ្គលៈ អត់ធ្មត់ មានចំណាប់អារម្មណ៍ និងមានមេត្រីភាព ចំពោះកុមារ ការប្រាស្រ័យទាក់ទង និងការផ្តល់ការតម្រង់ទិស

ង) ចេះភាសាខ្មែរស្ទាត់ជំនាញ និងសមត្ថភាពប្រាស្រ័យទាក់ទងជាភាសាអង់គ្លេស គឺជាគុណសម្បត្តិ។

### *៥.២. អ្នកថែទាំ*

**ការទទួលខុសត្រូវរបស់អ្នកថែទាំ**

អ្នកថែទាំគឺជាកម្លាំងពលកម្មស្នូលរបស់ទារកដ្ឋាន និងជាអ្នកទទួលខុសត្រូវក្នុងការមើលថែទាំកុមារនៅក្នុងទារកដ្ឋាន។ អ្នកថែទាំមានការទទួលខុសត្រូវដូចខាងក្រោម៖

ក) ផ្តល់ការថែទាំដល់កុមារដែលបានចុះឈ្មោះ មកទទួលសេវាក្នុងម៉ោងធ្វើការនៃទារកដ្ឋានរបស់ក្រសួងកិច្ចការនារី។ ស្វាគមន៍កុមារ ផ្តល់អាហារដល់កុមារ នៅពេលញ៉ាំអាហារ រៀបចំកុមារឱ្យគេង និងផ្តល់ការថែទាំផ្សេងទៀត ធ្វើសកម្មភាពគ្រប់គ្រង និងផ្តល់ការអប់រំ ទាំងក្នុង និងក្រៅអគារទារកដ្ឋាន

ខ) ធានាមិនឱ្យមានការបំពាន ទុកកុមារចោល ឬកេងប្រវ័ញ្ចលើកុមារនៅក្នុងទារកដ្ឋាន

គ) រាយការណ៍ទៅកាន់អ្នកគ្រប់គ្រងទារកដ្ឋាន ឬម្តាយ ឪពុកអំពីករណីសង្ស័យ ដូចជា ការរំលោភបំពាន ការទុកកុមារចោល និងការប្រព្រឹត្តអំពើហិង្សា និងការកេងប្រវ័ញ្ចក្នុងទម្រង់ណាមួយនៅក្នុងទារកដ្ឋាន

ឃ) គ្រប់គ្រង និងពិនិត្យសុវត្ថិភាពរបស់កុមារនៅគ្រប់ពេលក្នុងម៉ោងបំពេញភារកិច្ច

ង) ជួយឱ្យកុមារទទួលបាននូវការរក្សា អនាម័យ និងភាពស្អាត រួមទាំងការដូរខោទឹកនោមផងដែរ

ច) កសាងទំនាក់ទំនងឱ្យបានល្អ និងការជឿទុកចិត្តគ្នាជាមួយនឹងកុមារ ដើម្បីបំពេញតម្រូវការផ្លូវចិត្ត និងសង្គមរបស់ពួកគេ

ឆ) រក្សាព័ត៌មាន និងប្រវត្តិរបស់កុមារជាការសម្ងាត់

ជ) រៀបចំ/ផ្តល់អាហារដល់កុមារ

ឈ) កសាង និងរក្សាទំនាក់ទំនងឱ្យបានល្អជាមួយម្តាយ ឪពុក ដែលយកកូនមកចុះឈ្មោះទទួលសេវានៅក្នុងទារកដ្ឋាន

ញ) ប្រមូល និងធ្វើបច្ចុប្បន្នភាពរាល់ព័ត៌មានពាក់ព័ន្ធដែលចាំបាច់ទាំងអស់របស់កុមារ ដែលមកទទួលសេវា

នៅក្នុងទារកដ្ឋាន

ដ) ផ្តល់ការអប់រំ ឬកម្មវិធីគរុកោសល្យដល់កុមារទៅតាមអាយុរបស់ពួកគេ រួមចំណែកដល់ការអភិវឌ្ឍកម្មវិធី និងឯកសារដែលប្រើប្រាស់សម្រាប់ការអប់រំកុមារ

ឋ) ធានាថាទារកដ្ឋានមានភាពស្អាតជានិច្ច ស្របតាមនីតិវិធីរក្សាអនាម័យ និងសម្អាត

ឌ) ធ្វើការជាក្រុមជាមួយនឹងអ្នកថែទាំដទៃទៀត។

**លក្ខណៈសម្បត្តិ និងលក្ខខណ្ឌតម្រូវសម្រាប់អ្នកថែទាំ**

អាកប្បកិរិយា និងឥរិយាបថរបស់អ្នកថែទាំមានសារសំខាន់យ៉ាងខ្លាំង ព្រោះថាគុណភាពនៃការថែទាំ ពឹងផ្អែកលើពួកគេ។ អាកប្បកិរិយារបស់អ្នកថែទាំអាចមានឥទ្ធិពលលើការអភិវឌ្ឍរបស់កុមារ។ ការអភិវឌ្ឍកាយសម្បទា សង្គម សញ្ចេតនា និងបញ្ញាស្មារតីរបស់កុមារ ព្រមទាំងសុវត្ថិភាពរបស់ពួកគេ គឺអាស្រ័យលើការផ្តល់ការថែទាំ និងការទំនាក់ទំនងប្រកបដោយភាពស៊ីសង្វាក់គ្នារវាងពួកគេ និងអ្នកថែទាំពួកគេ។ អ្នកថែទាំគួរមានគុណវុឌ្ឍិ និងត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

ក) មានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ និងមានសុខភាពមាំមួន

ខ) យ៉ាងហោចណាស់បញ្ចប់ការសិក្សាថ្នាក់ទី ៩

គ) ការមានឥរិយាបថល្អ និងវិជ្ជមាន និងមានចំណាប់អារម្មណ៍ខ្លាំងលើការងារថែទាំកុមារ

ឃ) ការមានចំណេះដឹងជាមូលដ្ឋានអំពីសិទ្ធិរបស់កុមារ និងការការពារកុមារ គឺជាគុណសម្បត្តិ

ង) ការមានចំណេះដឹងជាមូលដ្ឋានអំពីអាហារូបត្ថម្ភរបស់កុមារ គឺជាគុណសម្បត្តិ

ច) ការមានចំណេះដឹងជាមូលដ្ឋានអំពីការអភិវឌ្ឍកុមារ និងចំណេះដឹងស្តីពីការចិញ្ចឹមបីបាច់កូនបែបវិជ្ជមាន គឺជាគុណសម្បត្តិ

ឆ) គោរព និងអនុវត្តតាមវិធានផ្ទៃក្នុង និងការណែនាំរបស់ទារកដ្ឋាន

ជ) មានជំនាញក្នុងនិយាយ អាន សរសេរ និងទំនាក់ទំនងជាភាសាខ្មែរបានល្អ

ឈ) មានភាពស្មោះត្រង់ គោរពពេលវេលា គោរពអ្នកដទៃ ប្រឹងប្រែងធ្វើការ និងធ្វើការប្រកបដោយភាពវៃឆ្លាត និងមានចរិយាសម្បត្តិល្អក្នុងការធ្វើការងារជាមួយនឹងកុមារ ដែលមានអាយុផ្សេងគ្នាជាមួយម្តាយ ឪពុក និងជាមួយក្រុមការងារទាំងមូល

ញ) ធ្វើការងារដោយយកចិត្តទុកដាក់ និងបង្ហាញពីភាពវិជ្ជមាន និងមេត្តាធម៌ចំពោះកុមារ និងក្រុមការងារ។

### *៥.២.១. ការជំនួសអ្នកថែទាំ*

នៅក្នុងករណីដែលអ្នកថែទាំអវត្តមាន អ្នកគ្រប់គ្រងទារកដ្ឋានត្រូវរៀបចំឱ្យមានអ្នកមកជំនួស ដើម្បីធានាឱ្យមានការផ្តល់សេវាជាធម្មតា។ ថ្នាក់ដឹកនាំរបស់ក្រសួងកិច្ចការនារី ឬអ្នកគ្រប់គ្រងទារកដ្ឋាន ត្រូវជួលអ្នកថែទាំជំនួស ឬបុគ្គលិកសម្អាត អាចផ្តល់ការថែទាំជាបណ្តោះអាសន្ន ព្រោះគាត់គឺជាអ្នកដែលស្គាល់បរិយាកាសនៅក្នុងទារកដ្ឋានស្រាប់។ អ្នកគ្រប់គ្រងគួរកំណត់រកអ្នកថែទាំជំនួសជាមុន ដើម្បីត្រៀមសម្រាប់ពេលដែលអវត្តមានអ្នកថែទាំដោយមិនបានរំពឹងទុកជាមុន។ អ្នកថែទាំជំនួសត្រូវចូលរួមនៅក្នុងសកម្មភាពនានារបស់អ្នកជំនួស សម្រាប់រយៈពេលដែលត្រូវបានកំណត់ទុកជាមុន និងអាចចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលរំលឹកឡើងវិញផងដែរ។ អ្នកថែទាំជំនួសគួរទទួលបានប្រាក់ឈ្នួលទៅតាមថ្ងៃធ្វើការរបស់អ្នកថែទាំពេញសិទ្ធិ។

### *៥.២.២. ជំនួយការ ឬអ្នកសម្អាតក្នុងទារកដ្ឋាន*

ជំនួយការ ឬអ្នកសម្អាតជួយអ្នកថែទាំក្នុងការរក្សាទារកដ្ឋានឱ្យនៅស្អាត តាមរយៈការអនុវត្តតាមនីតិវិធីរក្សាអនាម័យ ដែលលើកកម្ពស់នូវបរិយាកាសកុមារមេត្រី ដែលជួយឱ្យកុមារមានសុខភាពមាំមួន។ ជំនួយការ ឬអ្នកសម្អាតមានភារកិច្ចដូចខាងក្រោម៖

ក) សម្អាតទារកដ្ឋាន និងបរិក្ខារសម្ភារដែលប្រើប្រាស់នៅខាងក្នុង និងខាងក្រៅអគារ (កៅអី តុ ធុងដាក់ទឹកសម្រាប់ញ៉ាំ ចាន សួនកុមារ កន្លែងញ៉ាំអាហារ កន្លែងគេង កន្លែងលេង សួនកុមារ បន្ទប់ទឹក)

ខ) ជួយអ្នកថែទាំនៅពេលញ៉ាំអាហារ និងពេលញ៉ាំចំណីដើម្បីរៀបចំអាហារទៅតាមកាលវិភាគប្រចាំថ្ងៃ

គ) រៀបចំ និងសម្អាតតុ កៅអី និងសម្ភារដទៃទៀតទាំងអស់ ទាំងខាងក្នុង និងខាងក្រៅអគារ ពិនិត្យរៀបចំ និងថែទាំសម្ភារសម្អាតសារជាតុដែលប្រើប្រាស់សម្រាប់សម្អាត ដូចជា ម្សៅសាប៊ូ ទឹកសាប៊ូសម្រាប់លាងដៃ អំបោស ធុងដាក់ទឹក និងធុងដាក់សំរាម ជាដើម។

ឃ) ជួយអ្នកថែទាំក្នុងករណីបន្ទាន់ ឬបំពេញភារកិច្ចដទៃទៀត ក្នុងពេលដែលចាំបាច់។

### *៥.២.៣. ចំនួនកុមារ/អ្នកថែទាំ និងទំហំក្រុម*

ផលធៀបអ្នកថែទាំ និងកុមារសំដៅលើចំនួនកុមារដែលទទួលបានការថែទាំពីអ្នកថែទាំម្នាក់។ ទារកដ្ឋានត្រូវបំពេញទៅតាមលក្ខខណ្ឌអប្បបរមា គឺអ្នកថែទាំម្នាក់ត្រូវមើលថែទារកតូចដែលមានអាយុចាប់ពី ១៨ខែទៅ ៣៦ ខែ ចំនួន ១០ នាក់។ ផលធៀបសម្រាប់អ្នកថែទាំកាន់តែខ្ពស់ នៅពេលដែលកុមារកាន់តែមានអាយុតិច ស្របតាមស្តង់ដារសកល ឧទាហរណ៍ អ្នកថែទាំម្នាក់ ត្រូវមើលថែទាំកុមារអាយុពី ៦ខែ ទៅ ១៧ ខែ ចំនួន ៥ នាក់, អ្នកថែទាំម្នាក់ត្រូវមើលថែកុមារដែលមានអាយុពី ៣៧ខែ ទៅ ៦០ ខែ ចំនួន ១៥ នាក់។ ទារកដ្ឋាននីមួយៗត្រូវមានអ្នកថែទាំច្រើនបំផុតចំនួន ៤ នាក់។

ជាទូទៅក្រុមកុមារត្រូវនៅជាមួយនឹងអ្នកថែទាំដែលបានចាត់តាំងពេញមួយថ្ងៃ និងអាចផ្លាស់ទីទៅកាន់កន្លែងផ្សេងៗនៅក្នុងទារកដ្ឋាន ទាំងខាងក្នុង និងខាងក្រៅអាគារ។ ការកំណត់ពីផលធៀបអ្នកថែទាំ គួរពិចារណាលើចំណុចដូចខាងក្រោម៖

- ផលធៀបកុមារ និងអ្នកថែទាំ ត្រូវកំណត់ផ្អែកទៅតាមអាយុរបស់កុមារ
- អាយុនៃការអភិវឌ្ឍ ឬអាយុដែលបង្ហាញពីភាពចាស់ទុំនៃអារម្មណ៍របស់កុមារ គឺមានសារសំខាន់ណាស់នៅពេលដែលកំណត់ពីផលធៀបនេះ
- ជំនាញ និងសមត្ថភាពរបស់អ្នកថែទាំ ក៏ដូចជា តម្រូវការរបស់កុមារម្នាក់ៗ។

### ៥.២.៤. វិធីដាក់វិន័យ និងការណែនាំ

អ្នកថែទាំអាចប្រើប្រាស់វិធីដាក់វិន័យតាមបែបវិជ្ជមាន និងផ្តល់ការណែនាំដែលលើកទឹកចិត្តឱ្យកុមារផ្តល់តម្លៃដោយខ្លួនឯង ចេះគ្រប់គ្រងខ្លួនឯង និងកំណត់ទិសដៅដោយខ្លួនឯង។ វិធីទាំងនេះរួមមាន៖

ក) ផ្តល់ការណែនាំ និងលើកទឹកចិត្តឱ្យមានការអនុវត្តឥរិយាបថឱ្យបានល្អ

ខ) បន្តទំនាក់ទំនងជាមួយនឹងកុមារប្រកបដោយភាពវិជ្ជមាន

គ) យកចិត្តទុកដាក់ចំពោះកុមារម្នាក់ៗនៅក្នុងទារកដ្ឋាន និងធានាយ៉ាងណាឱ្យពួកគេទទួលបានការយកចិត្តទុកដាក់ត្រឹមត្រូវ និងដូចៗគ្នា
ឃ) ទទួលស្គាល់ និងគោរពសក្តានុពលពិសេសៗរបស់កុមារម្នាក់ៗ និងគោរពគ្រួសាររបស់ពួកគេ
ង) យកចិត្តទុកដាក់ចំពោះរបៀបផ្ទាល់ខ្លួនរបស់កុមារ ក្នុងការរៀនសូត្រ ទំនាក់ទំនង សម្រាក និងលេងកម្សាន្ត កុមារមួយចំនួនប្រហែលជាត្រូវការពេលលេងច្រើនជាងកុមារផ្សេងទៀត
ច) ធានាថាកុមារទទួលបានការគេងគ្រប់គ្រាន់ កុមារមួយចំនួនត្រូវការគេងច្រើនជាងកុមារផ្សេងទៀត
ឆ) ធានាថាកាលវិភាគ និងសកម្មភាពនានាផ្តល់ឱ្យកុមារនូវសកម្មភាពផ្លូវកាយ ការសម្រាក និងពេលវេលាបានគ្រប់គ្រាន់
ជ) កំណត់រកសញ្ញាដែលបង្ហាញពីបញ្ហាអារម្មណ៍ ឬបញ្ហាដែលពាក់ព័ន្ធនឹងការអភិវឌ្ឍរបស់កុមារ និងប្រាប់ម្តាយ ឪពុករបស់ពួកគេអំពីបញ្ហាទាំងនេះ។

## ប្រភេទនៃការដាក់វិន័យដែលត្រូវបានហាមឃាត់

ការណែនាំ ការធ្វើសកម្មភាព និងការដាក់វិន័យបែបអវិជ្ជមាន ឬការប្រើប្រាស់អំពើហិង្សាក្នុងទម្រង់នានាដូចជា អំពើហិង្សាផ្លូវកាយ ផ្លូវចិត្ត និងការមិនអើពើ អាចបង្កផលប៉ះពាល់អវិជ្ជមានលើការអភិវឌ្ឍផ្លូវកាយ ចិត្តសង្គម និងបញ្ញាស្មារតីរបស់កុមារ។ រាល់ការដាក់វិន័យបែបអវិជ្ជមានទាំងអស់ត្រូវបានហាមឃាត់ ហើយអ្នកថែទាំត្រូវចៀសវាងទង្វើដូចខាងក្រោម៖

ក) ដាក់ទោស ឬគំរាមដាក់ទោស
ខ) ចាប់ចងកុមារ
គ) ដាក់កុមារណាម្នាក់ឱ្យនៅឆ្ងាយពីកុមារផ្សេងទៀតនៅក្នុងទារកដ្ឋាន
ឃ) មិនឱ្យកុមារញ៉ាំអាហារ ញ៉ាំទឹក ឬគេង
ង) ចាប់រលាក់ ឬក្តិច
ច) ខាំ ឬវាយកុមារ នឹងវត្ថុ ដៃ ឬជើង
ឆ) ឱ្យកុមារស្ងាត់ តាមរយៈការយកអ្វីមួយទៅដាក់នៅខាងក្នុង ឬលើមាត់កុមារ
ជ) ធ្វើឱ្យកុមាររងភាពអាម៉ាស់ បន្ទុះបង្អាប់ ឬស្រែកដាក់កុមារ ធ្វើឱ្យកុមារខ្លាច
ឈ) ប្រើប្រាស់ភាសាឃោរឃៅ ឬភាសាដែលមានលក្ខណៈរំលោភបំពានជាមួយកុមារ
ញ) យកកុមារទៅដាក់នៅក្នុងបន្ទប់ចាក់សោរ ឬបន្ទប់ងងឹត បន្ទប់ទឹក ឬទូរខោអាវដែលមានទ្វារបិទជិត។

អំពើឆ្គាំឆ្គងដែលប្រព្រឹត្តដោយអ្នកថែទាំ ឬបុគ្គលិកដទៃទៀតចំពោះកុមារ និងនាំឱ្យមានការផ្អាកការងារបុគ្គលិករូបនោះជាបណ្ដោះអាសន្ន ឬជាអចិន្ត្រៃយ៍។ បុគ្គលិកនឹងទទួលវិន័យទៅតាមច្បាប់ការងារ ឬច្បាប់ព្រហ្មទណ្ឌរបស់ប្រទេសកម្ពុជា។

## ៥.៣. ការទទួលខុសត្រូវរបស់ម្ដាយ ឪពុក

### ៥.៣.១. សុវត្ថិភាពពេលយកកុមារមកដល់ទារកដ្ឋាន និងពេលមកយកកុមារពីទារកដ្ឋាន

ប្រសិនបើម្ដាយ ឪពុកចាំបាច់ត្រូវធ្វើដំណើរទៅធ្វើការ ពួកគេអាចរៀបចំឱ្យសមាជិកគ្រួសារ ឬសាច់ញាតិណាម្នាក់យកកុមារមកទារកដ្ឋាន និងយកកុមារចេញពីទារកដ្ឋានរបស់ក្រសួងកិច្ចការនារី។ ម្ដាយ ឪពុកត្រូវអនុញ្ញាតឱ្យសមាជិកគ្រួសារ ឬសាច់ញាតិបំពេញភារកិច្ចនេះ នៅពេលដែលពួកគេអវត្តមាន។ ព័ត៌មានទំនាក់ទំនងរបស់សមាជិកគ្រួសារ ឬសាច់ញាតិនោះ ត្រូវបញ្ចូលទៅក្នុងឯកសាររបស់កុមារ ដើម្បីចៀសវាងហានិភ័យដែលអាចកើតមានឡើងនាពេលអនាគត។ ព័ត៌មាន និងព័ត៌មានទំនាក់ទំនងរបស់សាច់ញាតិ ឬសមាជិកគ្រួសារដែលបានទទួលការអនុញ្ញាត ត្រូវបំពេញចូលទៅក្នុងទម្រង់ចុះឈ្មោះកុមារ និងមានការចុះហត្ថលេខាពីម្ដាយ ឪពុក (សូមមើលឧបសម្ព័ន្ធទី ៥)។

## ៥.៤. ឯកសាររបស់កុមារនៅក្នុងទារកដ្ឋាន

ក្នុងអំឡុងពេលនៅក្នុងទារកដ្ឋាន អាចមានព្រឹត្តិការណ៍កើតមានឡើងចំពោះកុមារ ដែលអ្នកថែទាំចាំបាច់ត្រូវមើលព័ត៌មានរបស់កុមារ ដើម្បីការពារពួកគេ ។

- អ្នកថែទាំត្រូវអាចយកឯកសាររបស់កុមារទាំងអស់មកមើលភ្លាមៗក្នុងម៉ោងធ្វើការរបស់ទារកដ្ឋានក្នុងករណីដែលមានស្ថានភាពបន្ទាន់កើតមានឡើង
- ម្ដាយ ឪពុក អាចមើលឯកសារកូនរបស់ខ្លួន ក្នុងពេលប្រជុំជាមួយនឹងអ្នកថែទាំ ឬជាមួយអ្នកគ្រប់គ្រងទារកដ្ឋាន
- ត្រូវមានការពិនិត្យ និង/ឬ ធ្វើបច្ចុប្បន្នភាពឯកសាររបស់កុមារទាំងអស់ ទៅតាមចំនួនកុមារដែលចេញចូលនៅទារកដ្ឋាន ជាប្រចាំ
- ទារកដ្ឋានគួរការពាររាល់ព័ត៌មានផ្ទាល់ខ្លួន និងទិន្នន័យទាំងអស់ របស់កុមារដែលចុះឈ្មោះក្នុងទារកដ្ឋាននេះ។[9]

### ៥.៤.១. ប្រភេទឯកសារ

អ្នកគ្រប់គ្រងទារកដ្ឋានគួរទទួលខុសត្រូវរៀបចំឯកសារ ដែលត្រូវបំពេញព័ត៌មានដោយម្ដាយ ឪពុកនៅពេលយកកូនរបស់ពួកគេមកចុះឈ្មោះ។ ឯកសារទាំងនេះ គួរដាក់នៅក្នុងទារកដ្ឋាននៅគ្រប់ពេលវេលាទាំងអស់។ តារាងទី ២ រៀបរាប់ពីឈ្មោះ គោលបំណង និងអ្នកដែលទទួលខុសត្រូវ លើការកត់ត្រាទិន្នន័យ និងភាពញឹកញាប់នៃការកត់ត្រាទិន្នន័យ។

[9] ឧបសម្ព័ន្ធទី ៥, ៨,១២, និង ១៤ និងទម្រង់ពាក់ព័ន្ធដទៃទៀត ប្រសិនបើចាំបាច់។

**តារាងទី ២៖ ទម្រង់ឯកសារ**[10]

| ឈ្មោះឯកសារ | គោលបំណង | អ្នកទទួលខុសត្រូវ | ភាពញឹកញាប់ |
|---|---|---|---|
| ការងាររដ្ឋបាល | | | |
| ទម្រង់វត្តមានរបស់កុមារ | កត់ត្រាការចូល និងចេញរបស់កុមារម្នាក់ៗនៅក្នុងទារកដ្ឋាន | អ្នកថែទាំ | ជារៀងរាល់ថ្ងៃ (ពេលមកដល់ និងពេលចេញទៅវិញ) |
| កិច្ចព្រមព្រៀងអំពីការប្រើប្រាស់សេវាទារកដ្ឋាន | កិច្ចព្រមព្រៀងរវាងម្តាយ ឪពុក និងអ្នកគ្រប់គ្រងទារកដ្ឋាន ដើម្បីឱ្យកុមារអាចមកទទួលសេវានៅក្នុងទារកដ្ឋាន | ម្តាយ ឪពុក និងអ្នកគ្រប់គ្រងអ្នកថែទាំ | នៅពេលចុះឈ្មោះ បន្ទាប់មកធ្វើឡើងជារៀងរាល់ឆ្នាំ |
| លេខទូរស័ព្ទសម្រាប់ស្ថានភាពបន្ទាន់ | បញ្ជីលេខទូរស័ព្ទពាក់ព័ន្ធនៅក្នុងករណីបន្ទាន់ (សង្គ្រោះបន្ទាន់ អំពើហិង្សាលើកុមារ ។ល។) | អ្នកថែទាំ | រៀងរាល់ឆ្នាំ |
| ការយល់ព្រមរបស់ម្តាយ ឪពុកសម្រាប់ការផ្តល់ការថែទាំ និងការដឹកជញ្ជូននៅក្នុងស្ថានភាពបន្ទាន់ | អនុញ្ញាតឱ្យកុមារទទួលបានការព្យាបាល ឬអនុញ្ញាតឱ្យយកកុមារទៅមូលដ្ឋានសុខាភិបាលណាមួយ | ម្តាយ ឪពុក | នៅពេលចុះឈ្មោះ បន្ទាប់មកធ្វើឡើងជារៀងរាល់ឆ្នាំ |
| សុខភាព | | | |
| ការអនុញ្ញាតឱ្យប្រើប្រាស់ថ្នាំ | អនុញ្ញាតឱ្យកុមារទទួលបានការព្យាបាល | ម្តាយ ឪពុក | នៅពេលចុះឈ្មោះ បន្ទាប់មកធ្វើឡើងជារៀងរាល់ឆ្នាំ |
| ឯកសារកត់ត្រាថ្នាំដែលត្រូវបានប្រើប្រាស់ | អនុញ្ញាតឱ្យគេអាចតាមដាន និងដឹង (ឧទាហរណ៍៖ ពីផលវិបាក ដែលអាចកើតមានពីប្រភេទថ្នាំនីមួយៗដែលផ្តល់ទៅឱ្យកុមារ) | អ្នកថែទាំ ឬគិលានុបដ្ឋាយិកា | សម្រាប់គ្រប់ថ្នាំទាំងអស់ដែលត្រូវបានផ្តល់ |
| ការវាស់សីតុណ្ហភាព | ពិនិត្យសីតុណ្ហភាពរបស់កុមារ ធានាថាសីតុណ្ហភាពនៅកម្រិតធម្មតា ជាពិសេសក្នុងអំឡុងពេលនៃការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ | អ្នកថែទាំ/គិលានុបដ្ឋាយិកា | រៀងរាល់ព្រឹក |

[10] សម្រាប់ទម្រង់កត់ត្រា សូមមើលឧបសម្ព័ន្ធ។

| | | | |
|---|---|---|---|
| ការពិនិត្យរោគសញ្ញា[11] និងការតាមដានមើលសីតុណ្ហភាពរបស់កុមារ | ពិនិត្យមើលរោគសញ្ញារបស់កុមារ ធានាថាពុំមានរោគសញ្ញាជំងឺកូវីដ-១៩ លើកុមារដែលកំពុងស្ថិតនៅក្នុងទារកដ្ឋានឡើយ តាមដានមើលសុខភាពរបស់កុមារដែលមានជំងឺ | អ្នកថែទាំ/គិលានុបដ្ឋាយិកា | រៀងរាល់ថ្ងៃ និងរៀងរាល់ ២ ម៉ោងម្តងនៅពេលដែលកុមារមានជំងឺ |
| ទម្រង់របាយការណ៍ពីការរងរបួស | តាមដានស្ថានភាពគ្រោះថ្នាក់ ឬការរងរបួស និងប្រសិនបើចាំបាច់ត្រូវការ ការសង្គ្រោះបឋមដែលអាចផ្តល់ជូន | អ្នកថែទាំ ឬគិលានុបដ្ឋាយិកា | គ្រប់ពេល នៅពេលដែលមានការរងរបួសកើតមានឡើង |

| | | | |
|---|---|---|---|
| បញ្ជីសុខភាពកុមារ | ព័ត៌មានពាក់ព័ន្ធនឹងសុខភាព និងទម្លាប់របស់កុមារ | ម្តាយ ឪពុក | នៅពេលចុះឈ្មោះ បន្ទាប់មករៀងរាល់ឆ្នាំ ឬរៀងរាល់ពេលដែលមានការផ្លាស់ប្តូរសំខាន់ៗ |
| របាយការណ៍ប្រចាំថ្ងៃរបស់កុមារ | ការតាមដានជារៀងរាល់ថ្ងៃលើកុមារម្នាក់ៗ ដូចជា ពេលគេង អាហារដែលកុមារញ៉ាំ និងការប្តូរខោទឹកនោម | អ្នកថែទាំ | រៀងរាល់ថ្ងៃ |
| សន្តិសុខ | | | |
| ឯកសារហ្វឹកហាត់ជម្លៀសពេលមានអគ្គិភ័យ | តាមដានការហ្វឹកហាត់ជម្លៀសខ្លួនពេលមានអគ្គិភ័យ (ចំនួនមនុស្សដែលមានវត្តមាន ដូចជា កុមារ បុគ្គលិក។ល។) | អ្នកគ្រប់គ្រងទារកដ្ឋាន | សម្រាប់រាល់ពេលមានការហ្វឹកហាត់ ជម្លៀសខ្លួនពេលមានអគ្គិភ័យ (ជាមធ្យមរៀងរាល់ ៦ ម្តង) |
| អនាម័យ | | | |
| បញ្ជីសម្អាត | អនុញ្ញាតឱ្យមានការតាមដានជំហាននៃការសម្អាត | អ្នកថែទាំ/អ្នកសម្អាត | រៀងរាល់ថ្ងៃ |

[11] រោគសញ្ញាជំងឺកូវីដ-១៩ ត្រូវផ្អែកទៅតាមការជូនដំណឹងជាសាធារណៈពីក្រសួងសុខាភិបាល។ ទារកដ្ឋានគួរអនុវត្តតាមព័ត៌មានបច្ចុប្បន្នភាពស្តីពីជំងឺកូវីដ-១៩ ដែលផ្តល់ដោយក្រសួងសុខាភិបាល និងត្រូវចាត់វិធានការដើម្បីការពារកុមារ និងបុគ្គលិក។

## ៥.៥. របាយការណ៍សុខភាពសម្រាប់កុមារនៅក្នុងទារកដ្ឋាន

ឯកសាររបស់ទារកដ្ឋាន ត្រូវមានរបាយការណ៍សុខភាពរបស់កុមារម្នាក់ៗ ដែលត្រូវដាក់មិនឱ្យហួសពីមួយសប្តាហ៍ក្រោយពេលចុះឈ្មោះកុមារដំបូង។ ព័ត៌មានសុខភាពគឺចាំបាច់ដើម្បីធានាឱ្យមានការកត់ត្រាស្ថានភាពសុខភាពរបស់កុមារម្នាក់ៗ។ ព័ត៌មាននេះក៏នឹងការពារសុខភាព និងសុវត្ថិភាពរបស់កុមារទាំងអស់នៅក្នុងទារកដ្ឋានផងដែរ។ របាយការណ៍សុខភាពគឺ៖

- របាយការណ៍លាយលក្ខណ៍អក្សរដែលចេញដោយអ្នកជំនាញផ្នែកថែទាំសុខភាព ដែលបានពិនិត្យមើលកុមារកាលពីឆ្នាំមុន។ របាយការណ៍នេះនឹងបញ្ជាក់ថាតើកុមារមានសុខភាពល្អគ្រប់គ្រាន់ដើម្បីចូលរួមនៅក្នុងកម្មវិធីថែទាំកុមារដែរឬទេ?
- សំណៅចម្លងប័ណ្ណលឿងដែលត្រូវបានធ្វើបច្ចុប្បន្នភាពសម្រាប់កុមារ ស្របតាមតារាងដូចខាងក្រោម (កម្មវិធីជាតិផ្តល់ថ្នាំបង្ការរបស់ក្រសួងសុខាភិបាល ដែលត្រូវបានពិនិត្យឡើងវិញកាលពីឆ្នាំ ២០១២)។

**តារាងទី ៣៖ វ៉ាក់សាំង**

| ល.រ | វ៉ាក់សាំង | អាយុ | | | | | |
|---|---|---|---|---|---|---|---|
| | | ពេលសម្រាល | ៦ សប្តាហ៍ | ១០ សប្តាហ៍ | ១៤ សប្តាហ៍ | ៩ សប្តាហ៍ | ១៨ សប្តាហ៍ |
| ១ | BCG | ✓ | | | | | |
| ២ | រលាកថ្លើមប្រភេទ B | ✓ | | | | | |
| ៣ | ថ្នាំបន្តក់ការពារជំងឺគ្រុនស្វិតដៃជើង | | ✓ | ✓ | ✓ | | |
| ៤ | DTP Hep-B-Hib | | ✓ | ✓ | ✓ | | |
| ៥ | PCV 1B (ជំងឺរលាកសួត) | | ✓ | ✓ | ✓ | | |
| ៦ | IPV (ការពារជំងឺគ្រុនស្វិតដៃជើងដែលលែងមានទៀត) | | | | ✓ | | |
| ៧ | ជំងឺកញ្ជ្រិល | | | | | ✓ | ✓ |
| ៨ | JE (តាមខេត្តមួយចំនួន) | | | | | ✓ | ✓ |

## ផ្នែកទី៦ ៖ ការរៀបចំរបាយការណ៍ ការតាមដាន និងវាយតម្លៃ

ការតាមដាន និងវាយតម្លៃ (M&E) គឺជាដំណើរការសម្រាប់កែលម្អប្រតិបត្តិការ និងកំណត់ពីគុណភាពនៃទារកដ្ឋានរបស់ក្រសួងកិច្ចការនារី។ លទ្ធផលនៃការតាមដាន និងវាយតម្លៃនឹងជួយធ្វើឱ្យសកម្មភាពប្រតិបត្តិការកាន់តែមានភាពប្រសើរ និងកំណត់ពីទិសដៅនាពេលអនាគតរបស់ទារកដ្ឋាន។ M&E គឺជាឧបករណ៍សម្រាប់វាយតម្លៃសេវាកម្ម បរិក្ខារ និងសម្ភារទាំងក្នុងអគារ ទាំងក្រៅអគារ។ ឧបករណ៍ M&E មានគោលដៅធំៗចំនួនពីរ៖

- តាមដាន និងវាយតម្លៃការគ្រប់គ្រង និងដំណើរការទារកដ្ឋាន ដោយផ្តោតលើគុណភាពសេវា បរិក្ខារ សម្ភារ និងទីតាំង។
- តាមដាន និងវាយតម្លៃការអនុវត្តស្តង់ដារប្រតិបត្តិការរបស់ទារកដ្ឋាន។ អ្នកជំនាញបច្ចេកទេស ដែលមកពីតាមស្ថាប័ននានា ដូចជា ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ព្រមទាំងក្រសួង និងស្ថាប័នពាក់ព័ន្ធដទៃទៀត នឹងចុះមកពិនិត្យទារកដ្ឋាននេះ។

បុគ្គលិករដ្ឋបាល ឬអ្នកគ្រប់គ្រងទារកដ្ឋាន ត្រូវធ្វើការតាមដានជាប្រចាំខែ និងប្រចាំត្រីមាស។ បុគ្គលិកអាចត្រូវស្នើឱ្យមានការចូលរួមពីថ្នាក់ដឹកនាំរបស់ក្រសួងកិច្ចការនារី ដែលមិនចូលរួមផ្ទាល់ក្នុងការគ្រប់គ្រង និងដំណើរការទារកដ្ឋាន។ គួរមានការរៀបចំកិច្ចប្រជុំប្រចាំសប្តាហ៍ជាមួយនឹងអ្នកថែទាំ ដើម្បីទទួលបានមតិត្រឡប់ពីអ្នកថែទាំ លើសកម្មភាពដែលអនុវត្តនៅក្នុងសប្តាហ៍ មេរៀនដែលទទួលបាន និងបញ្ហាប្រឈមនានា។ អ្នកគ្រប់គ្រងអាចប្រើប្រាស់មតិត្រឡប់នេះដើម្បីធ្វើឱ្យការផ្តល់សេវាកាន់តែប្រសើរឡើង។ ដោយសារតែអ្នកថែទាំចាំបាច់ត្រូវនៅជាមួយកុមារ សូម្បីតែក្នុងពេលញ៉ាំបាយថ្ងៃត្រង់ អ្នកគ្រប់គ្រងទារកដ្ឋានគួរមានភាពបត់បែនក្នុងការរកពេលវេលា ដើម្បីទទួលបានមតិត្រឡប់នេះ ឧទាហរណ៍ ដូចជា នៅក្នុងថ្ងៃ ឬក្រោយម៉ោងធ្វើការងារជាដើម។ ប្រសិនបើអ្នកថែទាំមិនមានពេលជួបប្រជុំផ្ទាល់ អ្នកគ្រប់គ្រងទារកដ្ឋានត្រូវស្នើសុំឱ្យអ្នកថែទាំសរសេរមតិត្រឡប់របស់ពួកគេ។ ត្រូវមានការរៀបចំកិច្ចប្រជុំប្រចាំត្រីមាសជាមួយនឹងម្តាយ ឪពុក ដើម្បីបង្ហាញពីសកម្មភាពរបស់ទារកដ្ឋាន ការអនុវត្តល្អ ព្រមទាំងបញ្ហាប្រឈមនានា និងដើម្បីទទួលបានមតិត្រឡប់ពីម្តាយ ឪពុកលើអ្វីដែលទារកដ្ឋានគួរធ្វើដើម្បីកែលម្អបន្ថែមទៀត។

ទារកដ្ឋានគួរសហការជាមួយនឹងម្តាយ ឪពុក ដើម្បីការអភិវឌ្ឍ និងការផ្តល់ការថែទាំដល់កូនៗរបស់ពួកគេ អាចជាការសហការជាលក្ខណៈបុគ្គល និងការសហការជាមួយនឹងក្រុមម្តាយ ឪពុក។ ព័ត៌មាន និងរាល់ការសង្កេតឃើញទាំងអស់លើកុមារម្នាក់ៗ ត្រូវបង្ហាញទៅកាន់ម្តាយ ឪពុករបស់ពួកគេ ដូចជា ពេលគេង ពេលញ៉ាំអាហារ ការលេង ការរៀនសូត្រ គ្រោះថ្នាក់។ល។ គួរមានការរៀបចំកិច្ចប្រជុំជាមួយនឹងម្តាយ ឪពុកឱ្យបានជាទៀងទាត់ ដើម្បីបន្តផ្តល់ព័ត៌មានដល់ម្តាយ ឪពុក និងទទួលបានមតិត្រឡប់របស់ពួកគេអំពីសេវាថែទាំកុមារ។

ក្នុងទារកដ្ឋាននេះ អ្នកគ្រប់គ្រងគួរពិចារណាបង្កើតជាប្រអប់ទទួលមតិត្រឡប់/បណ្តឹងតវ៉ា ដើម្បីឱ្យម្តាយ ឪពុកប្រើប្រាស់ប្រសិនបើចាំបាច់។ ព័ត៌មានជាមូលដ្ឋាន និងព័ត៌មានអប់រំផ្សព្វផ្សាយមួយចំនួនអំពីទារកដ្ឋាន នឹងត្រូវបង្ហាញ តាមរយៈគេហទំព័រ និង/ឬទំព័រហ្វេសប៊ុករបស់ក្រសួងកិច្ចការនារី។

មន្ត្រីអធិការកិច្ចមកពីតាមក្រសួងស្ថាប័ននានានឹងចុះធ្វើការវាយតម្លៃរៀងរាល់ឆមាស ឬរៀងរាល់ឆ្នាំ។ ការវាយតម្លៃលើគុណភាពសេវាអាចផ្តោតលើដំណើរការ វាយតម្លៃលើផែនការធៀបនឹងការអនុវត្ត ព្រមទាំងសូចនាករកម្មវិធីអប់រំ សម្ភារ ទីធ្លា ការអភិវឌ្ឍកុមារ ព្រមទាំងទិដ្ឋភាពផ្សេងទៀត ដែលឆ្លើយតបចំពោះគោលបំណង និងគោលដៅរួមរបស់ទារកដ្ឋាន។ ការតាមដាន និងវាយតម្លៃត្រូវបញ្ចូលបញ្ជីសំណួរសម្រាប់តាមដាន ត្រួតពិនិត្យ និងវាយ

តម្លៃ ព្រមទាំងមានការបែងចែកអ្នកជំនាញជាក្រុម ដើម្បីចូលរួមនៅក្នុងការតាមដាន និងវាយតម្លៃនេះ ហើយលទ្ធផលនឹងត្រូវបង្ហាញទៅកាន់ភាគីពាក់ព័ន្ធក្នុងក្រសួងកិច្ចការនារី និងស្ថាប័នដទៃទៀត រួមទាំងអ្នកជំនាញដែលចូលរួមនៅក្នុងការតាមដាន និងវាយតម្លៃ និងម្តាយ ឪពុកដែលបានចុះឈ្មោះកូនឱ្យទទួលសេវានៅក្នុងទារកដ្ឋានផងដែរ។

អ្នកគ្រប់គ្រងទារកដ្ឋាន ត្រូវរៀបចំរបាយការណ៍ជាប្រចាំ (ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ប្រចាំឆ្នាំ របាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃ ។ល។)។ របាយការណ៍ទាំងនោះ សំដៅដល់ការផ្តល់សេវានៅក្នុងទារកដ្ឋាន រួមទាំងគ្របដណ្តប់ទៅដល់សម្ភារ បរិក្ខានានានៅក្នុងទារកដ្ឋានផង។ ព័ត៌មានត្រឡប់ពីអ្នកថែទាំកុមារ មតិយោបល់នានាពីម្តាយ ឪពុកកុមារដែលប្រើប្រាស់សេវាទារកដ្ឋាន ត្រូវដាក់បញ្ចូលនៅក្នុងរបាយការណ៍ទាំងនោះ។ ក្នុងផ្នែកនេះដែរ ក្រសួងកិច្ចការនារី អាចពិចារណា ធ្វើការលើកកម្ពស់ការបង្កើតទារកដ្ឋានក្នុងស្ថាប័ននានា តាមរយៈការដកស្រង់ព័ត៌មាន ឬទិន្នន័យសំខាន់ៗពីរបាយការណ៍ទាំងនេះ ទៅផ្សព្វផ្សាយក្នុងគេហទំព័រ ឬទំព័រហ្វេសប៊ុករបស់ក្រសួងផងដែរ។

# ផ្នែកទី៧ ៖ ការប្រុងប្រយ័ត្នផ្នែកសន្តិសុខ និងសុវត្ថិភាព

ការប្រុងប្រយ័ត្នផ្នែកសន្តិសុខ និងសុវត្ថិភាពមានសារសំខាន់យ៉ាងខ្លាំង ទាំងក្នុងអគារ ទាំងក្រៅអគារនៅទារកដ្ឋានរបស់ក្រសួងកិច្ចការនារី។ ថ្នាក់ដឹកនាំរបស់ក្រសួងកិច្ចការនារី និងអ្នកគ្រប់គ្រងទារកដ្ឋានត្រូវមានផែនការប្រុងប្រយ័ត្នជាមុន ដោយផ្តោតលើសុវត្ថិភាព និងសន្តិសុខរបស់កុមារ ព្រមទាំងការរៀបចំផែនការឆ្លើយតបចំពោះស្ថានភាពបន្ទាន់ ដើម្បីជានាឱ្យមានការការពារឱ្យបានគ្រប់គ្រាន់ដល់កុមារដែលបានចុះឈ្មោះមកទទួលសេវាក្នុងទារកដ្ឋាន។

### *៧.១. ការចូលមកក្នុងទារកដ្ឋាន និងការជួបជាមួយនឹងកុមារ*

បុគ្គលិកទារកដ្ឋានត្រូវយកចិត្តទុកដាក់ចំពោះមនុស្សដែលចូល និងចេញពីទារកដ្ឋាន។ ការចេញចូលតម្រូវឱ្យមានការសម្គាល់អត្តសញ្ញាណ និងត្រូវមានបុគ្គលិកម្នាក់អមដំណើរ នៅពេលដែលពួកគេកំពុងស្ថិតនៅក្នុងទារកដ្ឋាន។ ទារកដ្ឋានត្រូវអនុញ្ញាតឱ្យម្តាយ ឪពុក ឬសាច់ញាតិដែលបានកំណត់ (ដូចចែងនៅក្នុងកិច្ចព្រមព្រៀងរបស់ម្តាយ ឪពុក) ឱ្យមកយកកុមារ។ ម្តាយ ឪពុក ឬសាច់ញាតិដែលបានទទួលការអនុញ្ញាតត្រូវមាន និងបង្ហាញអត្តសញ្ញាណប័ណ្ណដែលមានឈ្មោះរបស់ពួកគេ ព្រមទាំងឈ្មោះ និងរូបថតរបស់កុមារ ដែលស្ថិតក្រោមការទទួលខុសត្រូវរបស់ពួកគេ។ ព័ត៌មាននេះត្រូវបញ្ចូលទៅក្នុងឯកសារព័ត៌មានរបស់កុមារ ដើម្បីជានាសុវត្ថិភាព។

### *៧.២. អន្តរាគមន៍ និងការផ្តល់ឱសថ*

នៅពេលចុះឈ្មោះ ម្តាយ ឪពុក ឬសាច់ញាតិដែលត្រូវបានចាត់តាំង ត្រូវផ្តល់របាយការណ៍លាយលក្ខណ៍អក្សរពីអ្នកជំនាញផ្នែកថែទាំសុខភាព ដែលបានពិនិត្យសុខភាពរបស់កុមារនៅក្នុងរយៈពេល ១២ ខែ ចុងក្រោយនេះ។ របាយការណ៍សុខភាពនេះត្រូវចែងថា កុមារមានសុខភាពមាំមួន និងអាចចូលរួមក្នុងកម្មវិធីរបស់ទារកដ្ឋានបាន។

ទារកដ្ឋានរបស់ក្រសួងកិច្ចការនារីត្រូវអនុវត្តតាមពិធីសារ និងការណែនាំទាំងនេះ ក្នុងករណីដែលកុមារមានជំងឺ ឬរងរបួស ឬប្រសិនបើកុមារមានរោគសញ្ញាអ្វីមួយ៖

- មានតែបុគ្គលិកសុខាភិបាលតែប៉ុណ្ណោះ ដែលត្រូវបានអនុញ្ញាតឱ្យចេញថ្នាំ ប្រសិនបើរបួសជារបួសតូចតាច អ្នកថែទាំអាចផ្តល់សេវាសង្គ្រោះបឋមនៅក្នុងទារកដ្ឋានបាន
- ដើម្បីបញ្ចៀសហានិភ័យនៃការចម្លងជំងឺ ឬមេរោគ និងការពារសុខភាពកុមារដទៃទៀត និងអ្នកថែទាំ អ្នកគ្រប់គ្រងមិនត្រូវអនុញ្ញាតឱ្យកុមារដែលឈឺ ឬកុមារដែលមានសីតុណ្ហភាពរាងកាយខុសប្រក្រតី (ខ្ពស់ជាង ៣៧,៥°C) ឱ្យចូលមកក្នុងទារកដ្ឋានឡើយ រហូតដល់ពេលកុមារស្រួលខ្លួនឡើងវិញ
- អ្នកថែទាំទាំងអស់ រាប់បញ្ចូលទាំងអ្នកថែទាំជំនួសផង គួរទទួលបានការបណ្តុះបណ្តាលអំពីការសង្គ្រោះបឋម និងអាចផ្តល់ការសង្គ្រោះបឋមទៅឱ្យកុមារ នៅពេលដែលចាំបាច់
- អ្នកថែទាំ និងបុគ្គលិកទាំងអស់ រួមទាំងអ្នកគ្រប់គ្រង និងអ្នកថែទាំជំនួសផង គួរទទួលបានការបណ្តុះបណ្តាលអំពីពិធីសារស្តីពីសុខភាព និងសុវត្ថិភាព ដែលពាក់ព័ន្ធនឹងជំងឺកូវីដ-១៩ និងជំងឺឆ្លងនានា
- ក្នុងករណីដែលមានការរងរបួស ឬជំងឺធ្ងន់ធ្ងរកើតឡើងនៅក្នុងម៉ោងធ្វើការ ម្តាយ ឪពុក ឬសាច់ញាតិដែលត្រូវបានចាត់តាំង ត្រូវបញ្ជូនកុមារទៅមូលដ្ឋានសុខាភិបាល។ អ្នកថែទាំត្រូវផ្ទេរ ឬអមដំណើរកុមារដែលមាន

ជំងឺ ឬដែលរងរបួសទៅកាន់មូលដ្ឋានសុខាភិបាល នៅពេលដែលម្តាយ ឪពុក ឬសាច់ញាតិដែលត្រូវបានចាត់តាំងស្នើសុំ ឬផ្តល់ការអនុញ្ញាតឱ្យធ្វើបែបនេះតែប៉ុណ្ណោះ។ ម្តាយ ឪពុកត្រូវជ្រើសរើសមូលដ្ឋានសុខាភិបាល មុនពេលដែលអ្នកថែទាំអាចយកកុមារទៅទទួលការព្យាបាល។

- ក្នុងករណីដែលចាំបាច់ត្រូវយកកុមារដែលមានជំងឺ ឬដែលរងរបួសទៅកាន់មូលដ្ឋានសុខាភិបាលណាមួយ អ្នកគ្រប់គ្រង ឬអ្នកថែទាំត្រូវធានាថាមធ្យោបាយដឹកជញ្ជូនកុមារផ្តល់នូវផាសុខភាព និងមានសុវត្ថិភាពសម្រាប់កុមារ
- ក្នុងទារកដ្ឋាន អ្នកគ្រប់គ្រងគួរបិទផ្សាយលេខទូរស័ព្ទសម្រាប់ពេលមានស្ថានភាពអាសន្នផ្នែកសុខភាព ហើយអ្នកថែទាំត្រូវដឹងពីរបៀបចុចលេខទាំងនោះនៅក្នុងករណីមានគ្រោះអាសន្ន។

### *៧.៣. ការប្រុងប្រយ័ត្នផ្នែកសុវត្ថិភាព*

ការប្រុងប្រយ័ត្នផ្នែកសុវត្ថិភាពត្រូវអនុវត្តផ្អែកតាមនីតិវិធីស្តីពីសុវត្ថិភាព និងសន្តិសុខ សមស្របទៅតាមស្ថានភាពរបស់កុមារនៅក្នុងទារកដ្ឋានរបស់ក្រសួងកិច្ចការនារី។

### *៧.៣.១. វត្ថុដែលអាចបង្កគ្រោះថ្នាក់*

ការគ្រាន់តែឃ្លាំមើលតែមួយមុខ មិនអាចបង្ការរាល់គ្រោះថ្នាក់ និងការរងរបួសទាំងអស់នោះឡើយ ដូច្នេះបរិស្ថាននៅក្នុងទារកដ្ឋានត្រូវតែមិនមានមុខសញ្ញាគ្រោះថ្នាក់ផ្នែកសុខភាព និងសុវត្ថិភាពដើម្បីកាត់បន្ថយ ព្រមទាំងបញ្ចៀសហានិភ័យនានា។ ការធានានូវបរិស្ថានដែលមានសុវត្ថិភាព មានសារសំខាន់សម្រាប់ទារកដ្ឋានទាំងខាងក្នុង និងខាងក្រៅអគារ។ វត្ថុដែលមិនសមស្រប (ដូចជា កន្ត្រៃ ថង់ កាំបិត បារី ដែកកេះ សារធាតុរាវដែលងាយឆេះ ថ្នាំ សារធាតុគីមី) ដែលអាចបង្កហានិភ័យ ឬការរងរបួសដល់កុមារអាយុក្រោម ៣ ឆ្នាំ មិនគួរទុកនៅក្នុងទារកដ្ឋានឡើយ។ ប្រភព ឬបណ្តាញខ្សែអគ្គិសនី ត្រូវដំឡើងឱ្យឆ្ងាយពីទារកដ្ឋាន ឬឱ្យឆ្ងាយពីកន្លែងលេងរបស់កុមារ។ ត្រូវសាងសង់របងសុវត្ថិភាពនៅកន្លែងដែលចាំបាច់ក្នុងទារកដ្ឋាន។ ត្រូវមានការឃ្លាំមើលកុមារម្នាក់ៗ ដើម្បីធានាថាពួកគេមានសុវត្ថិភាព និងសន្តិសុខពេលមានគ្រោះថ្នាក់នានា។ ហេដ្ឋារចនាសម្ព័ន្ធនៅក្នុងទារកដ្ឋានត្រូវបំពេញទៅតាមស្តង់ដារសុវត្ថិភាព និងសន្តិសុខសម្រាប់កុមារអាយុក្រោម ៣ ឆ្នាំ។ ការប្រុងប្រយ័ត្នសម្រាប់ការពារមុខសញ្ញាគ្រោះថ្នាក់ ត្រូវមានដូចជា៖

- បរិស្ថានត្រូវស្អាត និងពុំមានការបំពុលខ្យល់ និងសំឡេងរំខាន
- បរិស្ថានមិនត្រូវមានវត្ថុគ្រោះថ្នាក់ ដែលអាចបង្កហានិភ័យ ឬការរងរបួសដល់កុមារ
- ព្រីភ្លើងដែលកុមារអាចប៉ះបាន ត្រូវតែមានគម្របការពារមិនឱ្យកុមារបើកបាន
- ម៉ាស៊ីនត្រជាក់ និងកង្ហារ ត្រូវដាក់ឱ្យផុតដៃកុមារទាំងអស់ ដើម្បីបញ្ចៀសហានិភ័យ ឬការរងរបួសនានា
- ត្រូវទុកវត្ថុ ឬបរិក្ខារដែលអាចបង្កគ្រោះថ្នាក់ឱ្យឆ្ងាយពីកន្លែងដែលកុមារប្រើប្រាស់។

### *៧.៣.២. មុខសញ្ញាគ្រោះថ្នាក់ដែលបង្កឡើងដោយមនុស្សផ្សេងទៀត*

ភស្តុតាងវិទ្យាសាស្ត្របង្ហាញពីទំនាក់ទំនងរវាងផ្សែងបារី និងហានិភ័យដែលបណ្តាលឱ្យកើតមានជំងឺផ្លូវដង្ហើម។ ទារក និងកុមារតូចនៅក្នុងទារកដ្ឋាន អាចប៉ះពាល់នឹងផ្សែងបារី ដែលបំភាយពីអ្នកជក់ និងប្រឈមមុខខ្ពស់

អាចកើតជំងឺផ្លូវដង្ហើម ដូចជា ជំងឺរលាកទងសួត រលាកសួត និងការឆ្លងនៅផ្នែកកណ្ដាលនៃត្រចៀកជាដើម។ ខាងក្រោមនេះគឺជាការប្រុងប្រយ័ត្នដែលទារកដ្ឋានត្រូវពិចារណា៖

- មិនត្រូវអនុញ្ញាតឱ្យអ្នកដែលមានឥរិយាបថ និង/ឬស្ថានភាពសុខភាពដែលអាចបង្កការគំរាមកំហែង ឬគ្រោះថ្នាក់ដល់សុខភាព ឬសុវត្ថិភាពរបស់កុមារឱ្យចូលមកក្នុងទារកដ្ឋាន នៅពេលដែលកំពុងមានវត្តមានកុមារនោះឡើយ។
- ត្រូវហាមឃាត់មិនឱ្យមានគ្រឿងស្រវឹង បារី និងសារធាតុពុលដទៃទៀតក្នុងទារកដ្ឋាន ទាំងក្នុងអគារ និងក្រៅអគារ។

## ៧.៤. ផែនការត្រៀមឆ្លើយតបស្ថានភាពអាសន្ន

គួររៀបចំផែនការត្រៀមបង្ការស្ថានភាពអាសន្ន ដើម្បីជានាការឆ្លើយតបចំពោះបញ្ហាសុវត្ថិភាព និងស្ថានភាពអាសន្នសម្រាប់កុមារ។ ផែនការនេះគួរកំណត់ពីការទទួលខុសត្រូវរបស់បុគ្គលិក និងជួយឱ្យទារកដ្ឋានបានត្រៀមខ្លួនឆ្លើយតបស្ថានភាពអាសន្ន ការជម្លៀសកុមារចេញពីអគារ និងការផ្លាស់ប្ដូរទីកន្លែងជាដើម។ ផែនការនេះត្រូវឆ្លើយតបចំពោះស្ថានភាពអាសន្នតាមប្រភេទផ្សេងៗគ្នា ដែលទំនងជានឹងកើតឡើងនៅក្នុងទារកដ្ឋាន ដូចជា អគ្គិភ័យ បញ្ហាសុខភាព ការផ្ទុះជំងឺឆ្លង។ល។ ជាការសំខាន់ណាស់ដែលគេត្រូវយល់ថា កុមារអាចមានភាពអន្ទះអន្ទែងក្នុងចិត្ត ឬភ័យខ្លាចនៅពេលដែលមានស្ថានភាពអាសន្នកើតមានឡើង ហើយអ្នកថែទាំគួររក្សាចិត្តឱ្យស្ងប់ និងចាត់វិធានការដើម្បីបង្ការមិនឱ្យបញ្ហានេះកើតមានឡើយ។

### ៧.៤.១. ផែនការត្រៀមឆ្លើយតប

**ក) ការជម្លៀស**

នៅក្នុងករណីដែលមានអាសន្នកើតឡើង ការទទួលខុសត្រូវដំបូងរបស់បុគ្គលិកទារកដ្ឋាន គឺត្រូវយកកុមារទៅកាន់កន្លែងដែលមានសុវត្ថិភាព ឬទៅកាន់ជម្រកសុវត្ថិភាពផ្សេងទៀត ដែលបុគ្គលិកទារកដ្ឋានទាំងអស់ស្គាល់។ នីតិវិធីស្ដីពីការជម្លៀសខ្លួន ដែលត្រូវបានសរសេរជាលាយលក្ខណ៍អក្សរត្រូវបញ្ចូលខ្លឹមសារដូចខាងក្រោម៖

- របៀបយកកុមារទៅកាន់កន្លែងសុវត្ថិភាពដែលត្រូវបានកំណត់ ឬជម្រកសុវត្ថិភាពផ្សេងទៀត រួមទាំងនីតិវិធីសម្រាប់យកកុមារតូចៗដែលមិនអាចដើរដោយខ្លួនឯងបាន។
- ផែនការ ឬដ្យាក្រាមសម្រាប់ជម្លៀស និងផ្លាស់ទីពេលមានអាសន្ន។
- ឈ្មោះ និងអាសយដ្ឋានរបស់ជម្រកសុវត្ថិភាពជាជម្រើសដែលនៅឆ្ងាយពីទារកដ្ឋាន ហើយដែលអាចប្រើប្រាស់បាន។
- របៀបដែលកុមារត្រូវបានធានា ឬជម្លៀសទៅទីកន្លែងដែលមានសុវត្ថិភាព ឬទីជម្រកបណ្ដោះអាសន្ន។

**ខ) ការប្រាស្រ័យទាក់ទង**

- លេខទូរស័ព្ទសម្រាប់ស្ថានភាពអាសន្នក្នុងបញ្ជីព័ត៌មានទំនាក់ទំនងរបស់ទារកដ្ឋាន
- ជានាថាបុគ្គលិកទារកដ្ឋានអាចទំនាក់ទំនងទៅកាន់បុគ្គល ឬស្ថាប័នសំខាន់ៗ (ដូចជា នគរបាលពន្លត់អគ្គិភ័យ រថយន្តសង្គ្រោះបន្ទាន់ អ្នកជំនាញខាងសុខភាព ម្ដាយ ឪពុក)។

### *៧.៤.២. ការទទួលខុសត្រូវក្នុងការអនុវត្តផែនការត្រៀមឆ្លើយតបស្ថានភាពអាសន្ន*

- អ្នកគ្រប់គ្រងទារកដ្ឋានទទួលខុសត្រូវលើការអនុវត្តផែនការត្រៀមឆ្លើយតបចំពោះស្ថានភាពអាសន្ន
- អ្នកគ្រប់គ្រងទារកដ្ឋានអាចចាត់តាំងបុគ្គលិកបន្ថែមឱ្យទទួលខុសត្រូវរៀបចំការជម្លៀស និងការផ្លាស់ប្តូរទីតាំងក្នុងករណីចាំបាច់

### *៧.៤.៣ ការអនុវត្តសុវត្ថិភាព និងគ្រាមានអាសន្ន*

- អ្នកគ្រប់គ្រងទារកដ្ឋានត្រូវរៀបចំការហ្វឹកហាត់ជម្លៀសខ្លួនពេលមានអគ្គិភ័យរៀងរាល់៦ខែម្តង និងសម្រាប់បុគ្គលិកដែលចូលថ្មីម្នាក់ៗ
- កុមារត្រូវ ឬអាចចាកចេញពីអគារប្រកបដោយសុវត្ថិភាពមិនឱ្យលើសពី ៣នាទី
- អ្នកគ្រប់គ្រងទារកដ្ឋានត្រូវកត់ត្រាព័ត៌មានអំពីការហ្វឹកហាត់ជម្លៀសអគ្គិភ័យ ដូចជា កាលបរិច្ឆេទ និងពេលវេលានៃការហ្វឹកហាត់ជាដើម
- ផែនទីជម្លៀស និងផ្លាស់ប្តូរទីតាំងពេលមានអាសន្ន ត្រូវបិទនៅកន្លែងដែលអាចមើលឃើញ និងយល់បានសម្រាប់បុគ្គលិកទាំងអស់នៅក្នុងទារកដ្ឋាន។ ផែនទីនេះត្រូវមាន ដូចជា៖
  - ច្រកចេញចំនួនពីរពីបន្ទប់នីមួយៗ
  - ទីតាំងដែលត្រូវបានកំណត់នៅខាងក្រៅទារកដ្ឋាន ដែលអ្នកថែទាំ និងកុមារទាំងអស់ត្រូវជុំគ្នា ក្រោយពីបានចាកចេញពីទារកដ្ឋានប្រកបដោយសុវត្ថិភាព
  - ទារកដ្ឋានត្រូវបិទផ្សាយផែនការជម្លៀស និងផ្លាស់ប្តូរទីតាំងពេលមានអាសន្ននៅតាមបន្ទប់នីមួយៗ
- ទារកដ្ឋានត្រូវមានច្រកចេញយ៉ាងហោចណាស់ចំនួនពីរទៅខាងក្រៅ ដែលស្ថិតនៅឆ្ងាយពីគ្នាក្នុងអគារនីមួយៗ។ ទ្វារដែលមានអ្វីបិទបាំង ឬត្រូវបានចាក់សោរមិនរាប់ជាច្រកចេញនោះឡើយ។

# ឧបសម្ព័ន្ធ

## ការអភិវឌ្ឍកុមារ

## ឧបសម្ព័ន្ធទី ១៖ ដំណាក់កាលនៃការអភិវឌ្ឍរបស់ទារក

### ការលូតលាស់ និងការអភិវឌ្ឍរបស់ទារក (០-១៨ ខែ)

រៀបចំដោយ Chris Plauche Johnson, MEd, MD* និង Peter A. Blasco, MD

**ចំណុចសំខាន់ៗ**

១. ការអភិវឌ្ឍរបស់ទារកកើតឡើងទៅតាមលំដាប់លំដោយ ដែលគេអាចព្យាករដឹងជាមុន។ ការអភិវឌ្ឍរបស់ទារកបន្តចេញពីផ្នែកនៃក្បាលដល់ចុងជើង (cephalic to caudal) ក៏ដូចជា ចេញពីប្រតិកម្មទូទៅចំពោះការភ្ញោចរហូតដល់ប្រតិកម្មជាក់លាក់ឆ្ពោះទៅសម្រេចគោលដៅអ្វីមួយ ដែលកាន់តែជាក់លាក់ទៅទៀត។ កម្លាំងពីខាងក្រៅអាចមានឥទ្ធិពលលើបម្រែបម្រួល និងគុណភាពនៃការអភិវឌ្ឍរបស់ទារក។

២. ត្រូវមានការវាយតម្លៃលើផ្នែកនៃការអភិវឌ្ឍនីមួយៗ ក្នុងអំឡុងពេលបន្តឃ្លាំមើលការអភិវឌ្ឍរបស់ទារក នៅក្នុងបរិបទនៃការតាមដានផ្នែកសុខភាព។ ការកំណត់ពីការអភិវឌ្ឍទូទៅមិនអាចធ្វើឡើងផ្អែកទៅតាមការវាយតម្លៃលើបំណិនរបស់ទារកក្នុងផ្នែកអភិវឌ្ឍន៍តែមួយនោះឡើយ (ពោលគឺគេមិនអាចរៀបរាប់ពីការយល់ដឹងរបស់ទារក ដោយផ្អែកតែលើការអភិវឌ្ឍផ្នែកចលនាធំនោះឡើយ)។ ទោះជាយ៉ាងណាក៏ដោយ បំណិននៅក្នុងផ្នែកអភិវឌ្ឍន៍ណាមួយពិតជាមានឥទ្ធិពលលើការទទួលបាន និងការវាយតម្លៃលើបំណិននៅក្នុងផ្នែកផ្សេងទៀត។

៣. ភាពយឺតយ៉ាវនៃការចេះនិយាយ គឺជាការព្រួយបារម្ភផ្នែកការអភិវឌ្ឍដែលកើតមានជាញឹកញាប់ដែលត្រូវបានសង្កេតឃើញដោយគ្រូពេទ្យព្យាបាលកុមារទូទៅ តែទោះជាយ៉ាងណាក៏ដោយ បញ្ហាទាំងនេះមិនទាន់ត្រូវបានគេយល់ឱ្យបានច្បាស់ និងត្រូវបានគេធ្វើរោគវិនិច្ឆ័យឃើញឱ្យបានលឿននោះឡើយ។ ការយល់ឱ្យបានច្បាស់អំពីភាពខុសប្លែកគ្នារវាងភាពយឺតយ៉ាវក្នុងការចេះនិយាយ ដែលកើតឡើងជាករណីដោយឡែក (ជាធម្មតាដោយសារមជ្ឈដ្ឋានជុំវិញ ហើយជារឿយៗអាចដោះស្រាយបាន) និងភាពយឺតយ៉ាវនៃការអភិវឌ្ឍភាសាពិតប្រាកដ (បញ្ហាក្នុងការនិយាយស្ដីផង និងការយល់ព័ត៌មានផង ដែលមានន័យថា អាចជាបញ្ហាធ្ងន់ធ្ងរ) និងជួយឱ្យអ្នកជំនាញខាងគ្លីនិកបញ្ជូនកុមារទៅរកសេវាធ្វើវិនិច្ឆ័យ និងគ្រប់គ្រងបញ្ហានេះឱ្យបានសមស្រប។

៤. ជាការសំខាន់ណាស់ដែលគេត្រូវយល់ដឹងពីការអភិវឌ្ឍជាធម្មតា និងបម្រែបម្រួលនៃការអភិវឌ្ឍជាធម្មតា ដែលគេអាចទទួលយកបានដើម្បីសម្គាល់ដឹងឱ្យបានទាន់ពេលវេលាពីបញ្ហានៃការអភិវឌ្ឍរបស់កុមារ ដែលអាចបង្ហាញពីលទ្ធភាពអាចកើតមានបញ្ហាពិការភាពដែលពាក់ព័ន្ធនឹងការអភិវឌ្ឍ។

៥. ការវាយតម្លៃលើគុណភាពនៃជំនាញ និងការតាមដានការសម្រេចបានចំណុចដៅនៃការអភិវឌ្ឍ មានសារសំខាន់យ៉ាងខ្លាំងសម្រាប់ការធ្វើរោគវិនិច្ឆ័យឱ្យបានទាន់ពេលវេលានូវបញ្ហាពិការភាព ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍ និងការបញ្ជូនឱ្យបានលឿនទៅរកកម្មវិធីអន្តរាគមន៍ទាន់ពេលវេលា។

ទារក គឺជាមនុស្សដែលប្រកបដោយភាពរស់រវើក និងបន្តមានការប្រែប្រួល ដែលឆ្លងកាត់លំដាប់លំដោយនៃការអភិវឌ្ឍផ្នែកខួរក្បាល និងការអភិវឌ្ឍរាងកាយទៅតាមដំហានៗ និងដែលគេអាចព្យាករដឹងមុនបាន។ លំដាប់លំដោយនេះទទួលរងឥទ្ធិពលជាបន្តបន្ទាប់ ដោយសារកម្លាំងខាងក្នុង និងខាងក្រៅ ដែលធ្វើឱ្យទារកម្នាក់ៗមានការវិវត្តខុសៗគ្នា និងធ្វើឱ្យដំណើរនៃការអភិវឌ្ឍរបស់ទារកម្នាក់ៗមានលក្ខណៈពិសេស។ ឥទ្ធិពលខាងក្នុងមាន ដូចជា លក្ខណៈកាយសម្បទា សុខុមាលភាព ឬការមានជំងឺ អារម្មណ៍ និងកត្តាដទៃទៀតដែលកំណត់ដោយសារហ្សែនរបស់កុមារ។ ឥទ្ធិពលពីខាងក្រៅក្នុងអំឡុងវ័យជាទារកមានប្រភពចម្បងពីគ្រួសារ។ បុគ្គលិកលក្ខណៈ និងរបៀបរបបនៃការផ្តល់ការថែទាំដោយម្តាយ ឪពុក និងបងប្អូន ស្ថានភាពសេដ្ឋកិច្ចរបស់គ្រួសារ និងពេលវេលា និងធនធានហិរញ្ញវត្ថុសម្រាប់កុមារ ក៏ដូចជា បរិបទវប្បធម៌ដែលកុមារកើតមក។ លំដាប់លំដោយនៃការអភិវឌ្ឍខួរក្បាលអាចចាត់ទុកថាជាចំណុចដៅនៃការអភិវឌ្ឍ ដែលគេធ្លាប់ដឹងកន្លងមក។ ចំណុចដៅនៃការអភិវឌ្ឍ គឺជាវិធីសាស្រ្តដែលមានលក្ខណៈជាប្រព័ន្ធសម្រាប់សង្កេតមើលការអភិវឌ្ឍរបស់កុមារនៅក្នុងរយៈពេលមួយ។ ការចេះបំណិនអ្វីមួយកើតឡើង បន្ទាប់ពីការចេះបំណិនមុនៗ។ កម្រមានករណីដែលមានការរំលងការអភិវឌ្ឍបំណិនណាស់ នៅពេលដែលមានបញ្ហានេះកើតមានឡើង បំណិននៅកម្រិតខ្ពស់អាចថាជាបំណិន "ដែលកើតឡើងលឿន" ពោលគឺជាការអភិវឌ្ឍក្នុងគន្លងមួយខុសពីធម្មតា។ ឧទាហរណ៍ ការចេះប្រើប្រាស់ប្រយោគមានពាក្យ ៥ ម៉ាត់របស់កុមារអាយុ ២ ឆ្នាំ ដែលមិនអនុវត្តតាមគន្លងនៃការចេះភាសាសាមញ្ញ អាចបង្ហាញពីបញ្ហាជំងឺអូទីហ្សឹម។ ប្រយោគទាំងនោះពុំមានអត្ថន័យ និងនិយាយពុំមានគោលបំណងប្រាស្រ័យទាក់ទងឡើយ។ ភាពយឺតយ៉ាវនៅក្នុងផ្នែកអភិវឌ្ឍន៍អ្វីមួយអាចធ្វើឱ្យប៉ះពាល់ដល់ការអភិវឌ្ឍនៅក្នុងផ្នែកមួយទៀត។ ឧទាហរណ៍ ការពុំអាចធ្វើចលនារាងកាយបាន ដោយសារតែបញ្ហាប្រព័ន្ធបញ្ជាសាច់ដុំនៅក្នុងខួរក្បាល ជាកត្តារារាំងមិនឱ្យកុមារស្វែងយល់ពីមជ្ឈដ្ឋានជុំវិញ និងធ្វើឱ្យប៉ះពាល់ដល់ការអភិវឌ្ឍបញ្ញាញាណ ដែលជាធម្មតាកើតឡើងតាមរយៈការលេងជាមួយនឹងវត្ថុនានា។ ការខ្វះភាពស្ទាត់ជំនាញនៅក្នុងផ្នែកមួយ អាចធ្វើឱ្យប៉ះពាល់ដល់ការវាយតម្លៃលើកម្រិតជំនាញនៅក្នុងផ្នែកមួយទៀត ទោះបីជាការអភិវឌ្ឍផ្នែកទី ២ នេះកើតឡើងជាធម្មតាក៏ដោយ។ ឧទាហរណ៍ គេពិបាកធ្វើការវាយតម្លៃលើបំណិនដោះស្រាយបញ្ហារបស់កុមារដែលមានបញ្ហាជំងឺពិការចលនាខួរក្បាល ព្រោះតែកុមារអាចយល់ពីទស្សនទាននៃរូបរាងធរណីមាត្រ ប៉ុន្តែមិនអាចដាក់រូបរាងធរណីមាត្រនេះទៅក្នុងក្តារខៀនដែលមានប្រឡោះសម្រាប់ដាក់រូបទាំងនេះ។ ចំណុចដៅនៃការអភិវឌ្ឍគឺជាមូលដ្ឋានដែលត្រូវបានប្រើប្រាស់សម្រាប់ការវាយតម្លៃស្តង់ដារ និងឧបករណ៍ពិនិត្យបឋមភាគច្រើន។ ទោះបីជាឧបករណ៍ពិនិត្យបឋមនេះ ផ្តល់ឱ្យអ្នកជំនាញគ្លីនិកនូវវិធីសាស្រ្តសម្រាប់សង្កេតមើលការវិវត្តរបស់ទារក និងជួយកំណត់រកបញ្ហាអភិវឌ្ឍន៍យឺតយ៉ាវក៏ដោយ ក៏ឧបករណ៍ជាច្រើនមិនអាចផ្តោតលើគ្រប់ចំណុចទាំងអស់នៃការអភិវឌ្ឍឡើយ។ គេមិនគួរទុកចោលការព្រួយបារម្ភរបស់ម្តាយ ឪពុកនៅពេលដែលលទ្ធផលនៃការពិនិត្យបឋមលើការអភិវឌ្ឍចេញមកជាលទ្ធផលធម្មតានោះឡើយ។ ការផ្តោតជាលក្ខណៈចង្អៀតលើចំណុចដៅតែមួយចំនួន អាចរកមិនឃើញនូវបញ្ហាខុសប្រក្រតីក្នុងដំណើរការនៃការអភិវឌ្ឍរបស់កុមារបាន។ ដូច្នេះជាការសំខាន់ណាស់ ដែលគេត្រូវធ្វើការវិភាគទៅលើរាល់ចំណុចដៅទាំងអស់ក្នុងបរិបទនៃប្រវត្តិការលូតលាស់ និងការពិនិត្យកាយសម្បទារបស់កុមារ ជាផ្នែកមួយនៃកម្មវិធីតាមដានការអភិវឌ្ឍរបស់កុមារជាប្រចាំ។ ការធ្វើបែបនេះ គេអាចដឹងជារួមពីស្ថានភាពនៃការអភិវឌ្ឍពិតប្រាកដរបស់កុមារ និងភាពចាំបាច់ក្នុងការធ្វើអន្តរាគមន៍។ ទោះបីជាចំណុចដៅនៃការអភិវឌ្ឍគឺជាមូលដ្ឋានគ្រឹះសម្រាប់ការពិភាក្សាក៏ដោយ គោលបំណងចម្បងនៃអត្ថបទនេះ គឺដើម្បីផ្តល់នូវព័ត៌មានទូទៅអំពីដំណើរការនៃ

ការអភិវឌ្ឍរបស់ទារក និងជួយឱ្យអ្នកជំនាញខាងគ្លីនិកសម្គាល់ដឹងពីឥរិយាបថដែលប្រាប់ឱ្យដឹងមុនពីភាពយឺតយ៉ាវនៃការអភិវឌ្ឍ("ទង់ក្រហម")របស់ទារក។ នៅក្នុងអត្ថបទនេះពុំមានការលើកឡើងពីអាយុសមស្របទៅតាមចំណុចដៅនៃការអភិវឌ្ឍឡើយ ដើម្បីទុកលទ្ធភាពឱ្យមានការពិភាក្សាអំពីប្រធានបទនៃការអភិវឌ្ឍសម្រាប់ផ្នែកនីមួយៗ។ ចំណុចទាំងនេះត្រូវបានរៀបចំជាផ្នែកៗ ដើម្បីជួយឱ្យអ្នកជំនាញគ្លីនិកចេះសម្គាល់ដឹងពីការអភិវឌ្ឍដាច់ដោយឡែកពីគេ ក៏ដូចជាការអភិវឌ្ឍដែលមានទំនាក់ទំនងជាមួយគ្នា។ តារាងដែលបង្ហាញពីគ្រប់ផ្នែកទាំងអស់នៃការអភិវឌ្ឍនៅអាយុនីមួយៗ អាចរកបាននៅក្នុងអត្ថបទរបស់ Vaughan (អត្ថបទអំណានដែលត្រូវបានស្នើឡើង)។ ចំណុចដៅនៃការអភិវឌ្ឍបំណិនដោះស្រាយបញ្ហា និងបំណិនភាសា អាចជួយសម្រួលឱ្យគេកំណត់ដឹងទាន់ពេលវេលាពីកង្វះបំណិនដែលពាក់ព័ន្ធនឹងបញ្ញាស្មារតី។ បំណិនសម្របខ្លួន (ឧទាហរណ៍ បំណិនពាក់ព័ន្ធនឹងការញ៉ាំអាហារ ការស្លៀកពាក់ ការចូលបន្ទប់ទឹកដោយខ្លួនឯង) ជាធម្មតាត្រូវបានបញ្ចូលទៅក្នុងផ្នែកបំណិនចលនាតូច។ ទោះជាយ៉ាងណាក៏ដោយ ដោយសារតែចំណុចទាំងនេះទទួលរងឥទ្ធិពលពីបរិស្ថាននៅក្នុងសង្គម យើងបានបញ្ចូលវាទៅក្នុង "ផ្នែកចិត្តសង្គម"។ បញ្ជីដែលបង្ហាញពីចំណុចដៅនៃការអភិវឌ្ឍដែលពាក់ព័ន្ធនឹងអារម្មណ៍ និងការចុះក្នុងសង្គម ក៏ត្រូវបានបញ្ចូលទៅក្នុងផ្នែកនេះផងដែរ។ ផ្ទុយទៅនឹងចំណុចនៃការអភិវឌ្ឍខាងចលនា និងខាងបញ្ញាស្មារតី ឥរិយាបថចិត្តសង្គមទទួលរងឥទ្ធិពលបន្ថែម ដោយសារកត្តាខាងក្រៅ ដែលធ្វើឱ្យគេមិនអាចកំណត់ពីឥរិយាបថទាំងនេះឱ្យបានច្បាស់។




ការអភិវឌ្ឍបំណិនចលនា តាមរយៈការពិនិត្យមើលលំដាប់លំដោយនៃការអភិវឌ្ឍរបស់ទារក ដែលគេអាចព្យាករដឹងបាន៖

- ការគ្រប់គ្រងក្បាល និងដៃជើង៖ ទារកអាចលើក និងងាកក្បាលទៅរកប្រភពភ្លោច
- ក្រឡាប់៖ ទារកក្រឡាប់ចុះឡើងពីពោះទៅខ្នង និងពីខ្នងមកពោះ នៅអាយុប្រមាណ ៤ ទៅ ៥ខែ

- អង្គុយត្រង់ខ្លួន៖ ពង្រឹងសាច់ដុំខ្នង និងក នៅអាយុចន្លោះពី ៤ ទៅ ៦ខែ
- ប្រឹងងើបអង្គុយ
- វារ
- លូន៖ ចេញពីកន្លែងអង្គុយ ទារកប្រឹងលូននៅលើកម្រាលឥដ្ឋដោយប្រើដៃ និងជើង និងរំកិលគូទរបស់ពួកគេ
- វារដោយប្រើដៃ និងជង្គង់
- ក្រោកឈរដោយមានអ្វីមួយទប់ (សង្ការិម ឬមនុស្សពេញវ័យ)
- ដើរដោយមានគេជួយទប់
- ឈរដោយខ្លួនឯង
- ដើរដោយខ្លួនឯង

**ជួយថែទាំ និងជួយខ្ញុំឱ្យលូតលាស់ពីពេលកើត ដល់អាយុ១៨ខែ**




ប្រភព៖ Infant and Toddlers (1st edition) Watson, Watson, Wilson, Crowther (2000)

## ឧបសម្ព័ន្ធទី២ ៖ ជំហាននៃការអភិវឌ្ឍកុមារ/កុមារតូច

### ជំហាននៃការអភិវឌ្ឍកុមារ (អាយុ ១៨-៣៦ ខែ)

កុមារអាយុ ១៨ខែ ចេះបំណិនដូចខាងក្រោម៖

#### សង្គម

- ចូលរួមនៅក្នុងការលេងជាមួយនឹងមនុស្សពេញវ័យ បងប្អូន និងមិត្តភក្តិដែលខ្លួនធ្លាប់ស្គាល់
- ធ្វើតាមការណែនាំងាយៗ

#### អារម្មណ៍

- បង្ហាញពីសេចក្តីស្រឡាញ់ចំពោះមនុស្ស សត្វចិញ្ចឹម ឬប្រដាប់លេង
- ចាប់ផ្តើមដឹងថាប្រតិកម្មអារម្មណ៍របស់អ្នកដទៃទៀតអាចខុសពីប្រតិកម្មអារម្មណ៍របស់ខ្លួន
- ចាប់ផ្តើមបង្ហាញសញ្ញាពីការយល់ចិត្ត
- រកគេលួង នៅពេលមិនសប្បាយចិត្ត

#### ភាសា

- ចេះវាក្យស័ព្ទបន្ថែមជាបន្តបន្ទាប់
- អាចនិយាយពាក្យចាប់ពី ២០ ម៉ាត់ឡើងទៅ
- ពាក្យពេចន៍មិនចាំបាច់ត្រូវតែច្បាស់នោះឡើយ
- ចូលចិត្តស្តាប់គេអាន និងមើលសៀវភៅងាយៗជាមួយនឹងអ្នកថែទាំ
- ព្យាយាមទាញការចាប់អារម្មណ៍ពីអ្នកឱ្យអ្វីមួយដែលគេចាប់អារម្មណ៍

#### បញ្ញាស្មារតី

- ប្រើប្រាស់វត្ថុជាឧបករណ៍
- ចងចាំមនុស្ស ទីកន្លែង វត្ថុ និងសកម្មភាពច្បាស់ជាងមុន
- អាចតម្រៀបវត្ថុទៅជាប្រភេទតែមួយ (ឧទាហរណ៍ តាមពណ៌ ឬតាមរាង)
- រករូបភាពនៅក្នុងសៀវភៅ "បង្ហាញរូបទារកឱ្យខ្ញុំឃើញ"
- លេងបែបប្រឌិតជាមួយនិងប្រដាប់លេង និងរូបភាព

#### ចលនា

##### ចលនាធំ

- ដើរឡើងជណ្តើរពីរបីកាំដោយកាន់ដៃរបស់អ្នក
- ដើរដោយខ្លួនឯង
- ដើរញាប់ជើងដោយជំហានខ្លីៗ ចលនាលោតកញ្ជ្រោល
- អង្គុយចុះដើម្បីយកប្រដាប់លេង និងក្រោកឈរដោយមិនដួល
- ដើរថយក្រោយពីរបីជំហានដោយមិនមានគេទប់
- ទាត់បាល់

##### ចលនាតូច

- លេងវត្ថុតូចៗដោយអាចសម្របសម្រួលកាយវិការរបស់ខ្លួនបានល្អជាងមុន
- បើកសៀវភៅបានពីរបីទំព័រក្នុងមួយលើក
- គូសពីលើមកក្រោម និងពីក្រោមឡើងលើ ដោយប្រើខ្មៅដៃ
- បើកដបចាក់អ្វីមួយចេញពីដប
- ដោះសម្លៀកបំពាក់ដោយខ្លួនឯង
- បើកថតទូ

កុមារអាយុ **២៤ ខែ អាច៖**

### សង្គម

- ចេះធ្វើតាមឥរិយាបថរបស់អ្នកដទៃជាពិសេស មនុស្សពេញវ័យ និងកុមារដែលមានអាយុច្រើនជាង
